ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ការបាត់បង់ស្ថាបត្យករដ៏ល្បី ហ្សាហា ហាឌីត

◆ ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩៥ ខែមីនា ឆ្នាំ២០១៦

# ស្វែងរកការពិត

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩៥ ខែមីនា ឆ្នាំ២០១៦

## មាតិកា

◆ ការបាត់បង់ស្ថាបត្យករដ៏ល្បី ហ្សាហា ហាឌីត ..................................១

**ផ្នែកឯកសារ**

◆ កែវ សេង ហៅ សារឿន សមាជិកកងពល៨០១ ........................៤

◆ មនោសញ្ចេតនា ..................................................................១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ "បើរស់យើងនឹងត្រឡប់មកស្រុកកំណើតវិញ" ................................២០

◆ រស់នៅលើភ្នំរយៈពេល១៣ឆ្នាំ ព្រោះតែសង្គ្រាម ............................២៤

◆ ជីវិត សាក់រូណា នៅក្នុងរបបខ្មែរក្រហម ....................................២៦

◆ ខ្ញុំមិនខ្លាចខ្មែរក្រហមទេ ..........................................................២៨

◆ សំណាងហើយដែលនៅមានជីវិត .................................................៣០

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហំ បាលី .........................៣២

◆ អាថ៌កំបាំងរបស់ ប៉ុល ពត .......................................................៣៩

**ផ្នែកច្បាប់**

◆ មន្ទីរសន្តិសុខអូរកន្សែង ...........................................................៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ........................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ......................................................................៥៦



ប្លង់របស់វិទ្យាស្ថានស្លឹករឹត គូរដោយស្ថាបត្យករ ហ្សាហា ហាឌីត

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ :*** *ហូ ថុនា, សុក គឹមសី, សុខ វណ្ណៈ, ហួត ប៊ុនគង់, សាំង ថុង, អេង កុកថាយ, ទេព ម៉េងឃាន, លី សុខឃាង, ប៉ុក ប៊ុនសូម៉ាដ* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *ទាវ សារៈមុន្និ* ***អ្នកបកប្រែ :*** *សុភ័ក្ត្រ ភាណា* ***និពន្ធនាយកទូទៅ :*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក :*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ :*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ :*** *ឆេង វើង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការបាត់បង់ស្ថាបត្យករដ៏ល្បី ហ្សាហា ហាឌីត

អ្នកស្រី ហ្សាហា ហាឌីត (Zaha Hadid) គឺជាជនជាតិអង់គ្លេសដើមកំណើតអ៊ីរ៉ាក់ ។ អ្នកស្រីកើតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥០ នៅទីក្រុងបាដាដ ។ លោកស្រីបានសិក្សាមុខវិជ្ជាគណិតវិទ្យា នៅសាកលវិទ្យាល័យបេរ៉ូត ប្រទេសអ៊ីរ៉ាក់ មុននឹងទៅបន្តការសិក្សាផ្នែកស្ថាបត្យកម្ម នៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស នៅឆ្នាំ១៩៧២ ។ បន្ទាប់មក អ្នកស្រីបានបម្រើការងារជាសាស្ត្រាចារ្យរហូតដល់ទសវត្សរ៍ឆ្នាំ៨០ ទើបអ្នកស្រីបង្កើតក្រុមហ៊ុន (Zaha Hadid) ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ ។ តាមរយៈក្រុមហ៊ុននេះ អ្នកស្រីបានធ្វើការងារ រចនាប្លង់ និងសាងសង់អគារល្បីៗនៅជុំវិញពិភពលោក រហូតដល់អ្នកស្រីទទួលបានពានរង្វាន់ពីចក្រភពអង់គ្លេសជាស្ត្រីផ្ទើមទីមួយក្នុងវិស័យស្ថាបត្យកម្ម ។ អ្នកស្រី ហ្សាហា ហាឌីត បានស្លាប់ដោយជំងឺគាំងបេះដូង នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៦ ដោយអ្នកស្រីបានបន្សល់ទុកស្នាដៃចង់ចាំជាច្រើន រួមទាំង ប្លង់វិទ្យាស្ថានស្លឹករឹត នៅក្នុងប្រទេសកម្ពុជាផងដែរ ។

ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់អ្នកដែលធ្លាប់បានស្គាល់អ្នកស្រី និងស្នាដៃរបស់អ្នកស្រី ៖

◆ *លីម យ៉ុងហួត និស្សិតផ្នែកស្ថាបត្យកម្ម នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

ខ្ញុំពិតជាមានការសោកស្តាយចំពោះដំណឹងមរណភាពរបស់លោកស្រី ហ្សាហា ហាឌីត ដែលជាស្ថាបត្យការិនីទីមួយដែលបានទទួលពានរង្វាន់ **Pritzker Prize** និងជាអ្នកដែលបានបង្កើតស្ថាបត្យកម្មជាសកលបែបសហសម័យ ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវឥទ្ធិពលរបស់ស្ថាបត្យកម្មក្នុងការអភិវឌ្ឍន៍នានា ។ លើសពីនេះ លោកស្រីគឺជាបុគ្គលមួយរូបដែលអាចជំរុញលើកទឹកចិត្ត និងជានិមិត្តរូប



*លោក ឆាង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និយាយទៅកាន់ភ្ញៀវអំពីប្លង់វិទ្យាស្ថានស្លឹក ដែលគូរដោយស្ថាបត្យករ ហ្សាហា ហាឌីត នៅវិចិត្រសាលរបស់ក្រុមក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤*

សម្រាប់សិស្សានុសិស្ស និងស្ថាបត្យករវ័យក្មេងជាច្រើនលើសកលលោក ដែលក្នុងនោះរួមមានទាំងរូបខ្ញុំផងដែរ ។ ខ្ញុំបានស្គាល់លោកស្រីតាមរយៈស្នាដៃជាច្រើនរបស់គាត់ដែលមានលក្ខណៈទន់ភ្លន់ និងមានទម្រង់លំនាំតាមធម្មជាតិប្លែកៗ ដែលជាអត្តសញ្ញាណស្ថាបត្យកម្មរបស់លោកស្រី ។ ខ្ញុំស្គាល់លោកស្រីតាមរយៈសំណង់ស្ថាបត្យកម្មមួយរបស់លោកស្រីនៅភ្នំពេញ គឺវិទ្យាស្ថានស្លឹករឹត ដែលជាវិទ្យាស្ថានបង្រៀនអំពីរបបប្រល័យពូជសាសន៍ និងជាសារមន្ទីរនៃការចងចាំរបស់កម្ពុជា ។ ជាចុងក្រោយ ខ្ញុំសូមសម្តែងនូវការសោកស្តាយចំពោះការស្លាប់របស់លោកស្រីដែលជាបុគ្គលឆ្នើម និងល្បីល្បាញមួយរូបក្នុងវិស័យស្ថាបត្យកម្ម ។

◆ *យ៉េង សេរីរ័ត្ន និស្សិតឆ្នាំទី៤ ផ្នែកស្ថាបត្យកម្ម នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

*Zaha Hadid* គឺជាស្ថាបត្យករស្រីដ៏អស្ចារ្យ ជនជាតិអ៊ីរ៉ាក់-អង់គ្លេសមួយរូប ដែលពិភពលោកស្ងើចសរសើរ ។ កាលពីខែកុម្ភៈ ដើម្បីឆ្នាំ២០១៦ នេះគាត់បានក្លាយជាស្ត្រីដំបូងតែមួយគត់ ដែលបានទទួលមេដាយមាស *RIBA (Royal Institute of British Architects)* នៅទីក្រុងឡុងដ៍ ហើយក៏ជាស្ត្រីទីមួយដែលបានទទួលពានរង្វាន់ *Pritzker Architecture Prize* កាលពីឆ្នាំ២០០៤ ។ ស្នាដៃរបស់គាត់មានពាសពេញពិភពលោក ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងស្ថាបត្យកម្មសហសម័យសតវត្សរ៍ទី២១ នេះ ។ ក្នុងនោះប្រទេសកម្ពុជាក៏មានគម្រោងប្លង់វិទ្យាស្ថានស្លឹករឹត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរចនាប្លង់ដោយ *Zaha Hadid Architects* និងក្រុមការងាររបស់គាត់ដែរ ។

ខ្ញុំបានស្គាល់អំពី *Zaha Hadid* ចាប់តាំងពីរៀនថ្នាក់ឆ្នាំ២ ផ្នែកស្ថាបត្យកម្ម នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។ ដំបូងឡើយខ្ញុំបានឃើញប្រព័ន្ធការងាររបស់គាត់តាមអ៊ីនធឺណិតដែលការងារនោះមានឥទ្ធិពលយ៉ាងខ្លាំងមកលើទស្សនៈរបស់ខ្ញុំក្នុងវិស័យស្ថាបត្យកម្ម និងតុបតែងលម្អក្នុងសម័យទំនើប ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ជាវីរនារី ដែលមានឆន្ទៈ និងចក្ខុវិស័យខ្ពស់ក្នុងការជំរុញទឹកចិត្ត ការបណ្តុះគំនិត និងការយកឈ្នះឧបសគ្គក្នុងវិស័យ


លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ពិភាក្សាជាមួយអ្នកស្រី ហ្សាហា ហាឌីត ប្រធានក្រុមហ៊ុន ហ្សាហា ហាឌីត អំពីប្លង់ និងការសាងសង់វិទ្យាស្ថានស្លឹករឹត នៅប្រទេសកម្ពុជា នៅវិចិត្រសាលរបស់ក្រុមហ៊ុន ក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤

នេះសម្រាប់ស្ថាបត្យករជំនាន់ក្រោយ ជាពិសេស ស្ថាបត្យករដែលជាស្ត្រីភេទ ។

ក្រោយពីដឹងថា Zaha Hadid នៅកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០១៤ នាងខ្ញុំបានដាក់ពាក្យធ្វើការស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលើគម្រោងសាងសង់វិទ្យាស្ថានស្លឹករឹត និងគម្រោងសិក្សា Phnom Penh Master Plan ២០២៥ ។ ពេលនោះ ជាពេលវេលាមួយដែលនាងខ្ញុំមិននឹកស្មានដល់ថា ខ្ញុំអាចឈានមួយជំហានទៅកាន់តែជិតជាមួយក្រុមការងាររបស់គាត់ ។ វាពិតជាអស្ចារ្យដែលបានស្គាល់ក្រុមការងារស្ថាបត្យករជំនាញជាច្រើនដូចជា Daewha Kang, Brian Dale, Markus Zimmer និង បានទទួលយកការចែករំលែកបទពិសោធន៍របស់ពួកគាត់ រួមទាំងលោក ពូ ឆាំង យុ អំពីដំណើរការការងារគម្រោងសាងសង់វិទ្យាស្ថានស្លឹករឹត និងទទួលបានការឲ្យយោបល់លើការងារផ្ទាល់ខ្លួននៅសាលាថែមទៀតផង ។ ពួកគាត់តែងតែប្រាប់ជារឿយៗអំពីដំណើរការនៅ Zaha Hadid Office នៅទីក្រុងឡុងដ៍ ។ ខ្ញុំតែងស្រមៃ និងរំពឹងទុកថា ថ្ងៃណាមួយខ្ញុំនឹងមានឱកាសឃើញ Zaha Hadid ដោយផ្ទាល់ ។

តាមរយៈ BBC News ដែលចុះផ្សាយកាលពីម្សិលមិញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ អំពីការស្លាប់របស់ស្ថាបត្យករឆ្នើម Zaha Hadid ពិតជាធ្វើឲ្យខ្ញុំតក់ស្លុត និងសោកស្តាយយ៉ាងខ្លាំង ចំពោះការបាត់បង់ដ៏ធំធេងរបស់ពិភពលោក ។ គាត់ជាស្ត្រីទីមួយដែលបានផ្លាស់ប្តូរ និងបានចូលរួមចំណែកដែលមិនអាចកាត់ថ្លៃបានលើវិស័យស្ថាបត្យកម្ម ។ ការខិតខំប្រឹងប្រែងរបស់គាត់នឹងនៅជាប់ក្នុងចិត្តរបស់ស្ថាបត្យករគ្រប់រូប និងគ្រប់គ្នាក្នុងសាកលលោក ។

នាងខ្ញុំសូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំនេះ ជាមួយគ្រួសារ និងក្រុមការងាររបស់គាត់ទាំងអស់ ។ សូមឲ្យវិញ្ញាណក្ខន្ធរបស់គាត់បានទៅដល់សុគតិភព ។

◆ *ស៊ីង ប៊ុននី និស្សិតផ្នែកស្ថាបត្យកម្មនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

នាងខ្ញុំបានស្គាល់លោកស្រី ហ្សាហា ហាឌីត (Zaha Hadid) ដែលជាស្ថាបត្យករស្រីមានសញ្ជាតិអង់គ្លេសដើមកំណើតអ៊ីរ៉ាក់ តាមរយៈសាស្ត្រាចារ្យ និងមិត្តរួមថ្នាក់ដែលតែងតែកោតសរសើរគាត់ ។ បន្ទាប់មក នាងខ្ញុំបានធ្វើការសិក្សាបន្ថែមទៅលើស្នាដៃរបស់លោកស្រី ។ ឧទាហរណ៍ Guang Zhou Opera House, Heyda Aliyev Museum និង វិទ្យាស្ថានស្លឹករឹត នៅប្រទេសកម្ពុជាយើងផ្ទាល់ ។ លោកស្រីជាស្ថាបត្យករស្រីដំបូងគេបង្អស់ដែលត្រូវបានសាធារណជនទទួលស្គាល់នូវស្នាដៃ និងកិត្យានុភាពដ៏អស្ចារ្យនៃភាពវាងវៃពោរពេញទៅដោយគំនិតច្នៃប្រឌិត និងទ្រឹស្តីល្អៗជាច្រើនដែលបានជះឥទ្ធិពលមកលើស្ថាបត្យករជំនាន់ក្រោយ ។ លោកស្រី ហ្សាហា ហាឌីត ជាស្ថាបត្យករស្រីដែលមានវ័យក្មេងជាងគេក្នុងចំណោមស្ថាបត្យករដ៏ទៃទៀត និងជាមនុស្សស្រីដំបូងគេបង្អស់ដែលទទួលបានពានរង្វាន់ The Pritzker ក្នុងឆ្នាំ២០០៤ និងពានរង្វាន់ផ្សេងៗទៀតរហូតមកដល់ខែកុម្ភៈ ឆ្នាំ២០១៦នេះ ។ លោកស្រីជាវីរនារីដំបូងដែលទទួលពានរង្វាន់ The Royal Gold Medal ។

ប៉ុន្តែអ្វីដែលគួរឲ្យសោកស្តាយបំផុតនោះគឺ លោកស្រីបានចែកឋានទៅហើយកាលពីម្សិលមិញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ នេះ ដោយសារគាំងបេះដូងភ្លាមៗនៅក្នុងមន្ទីរពេទ្យ នៅសហរដ្ឋអាមេរិក ។

នាងខ្ញុំមិនចង់ជឿទេថា ដំណឹងនេះជាការពិត ។ វាពិតជារឿងដែលពិបាកនឹងទទួលយក និងមានការតក់ស្លុតសម្រាប់ខ្ញុំ និងមហាជនដែលតែងតែគោរព និងស្រឡាញ់គាត់ ។ នាងខ្ញុំសូមចូលរួមសោកស្តាយក្នុងការបាត់បង់វត្តមានរបស់លោកស្រី ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm • ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# កែវ សេង ហៅ សារឿន សមាជិកកងពល៨០១

*ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J ០ ០ ៨៩១*

កែវ សេង ហៅ សារឿន ភេទប្រុស មានស្រុកកំណើតនៅភូមិក្ដុងអាយ ឃុំតាសាល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ មុនអង្គការចាប់ សេង មានតួនាទីជាសមាជិកកងពល៨០១ ។ សេង ត្រូវបានអង្គការចោទថា បានធ្វើសកម្មភាពកសាងកម្លាំង និងទាក់ទងជាមួយវៀតណាម ប្រឆាំងនឹងអង្គការបដិវត្តន៍ ។ ខាងក្រោមនេះ ជាសេចក្ដីសង្ខេបចម្លើយសារភាព របស់ កែវ សេង ហៅ សារឿនៈ

កាលឆ្នាំ១៩៦៤ ខ្ញុំមានអាយុ១៩ឆ្នាំ ខ្ញុំបានទទួលការអប់រំពីឈ្មោះ អ៊ូច អតីតទាហានកម្ពុជាក្រោមដែលបានជំរុញខ្ញុំឲ្យស្អប់ និងប្រឆាំងរបបខ្មែរក្រហម ដោយអប់រំខ្ញុំថា នៅថ្ងៃមុខ បើមានខ្មែរក្រហមត្រង់ណា គឺវេទនាត្រង់នោះហើយ បើខ្មែរក្រហមឈ្នះ ច្បាស់ជាអស់សេរីភាព ហើយប្រជាជនក្រីក្រត្រូវបង្ខំឲ្យធ្វើតាមគេទាំងអស់ ។ ក្រោយពីអប់រំខ្ញុំជាបន្តបន្ទាប់មក អ៊ូច បានចាត់តាំងខ្ញុំឲ្យដើរបំផុសប្រជាជនឲ្យខ្លាច និងស្អប់ខ្មែរក្រហម បន្ទាប់មក អ៊ូច បានបញ្ចូលខ្ញុំជាខ្មែរសេរី ហើយអ្នកទទួលស្គាល់ខ្ញុំគឺមេឃុំ សៅ ដែលមានការទាក់ទងជាមួយនឹង អ៊ូច ។ កម្លាំងខ្មែរសេរីដែលធ្វើសកម្មភាពជាមួយនឹងខ្ញុំក្រោមបញ្ជារបស់ អ៊ូច ហើយសមាសភាពខ្មែរសេរីដែលទាក់ទងកាលនោះមានឈ្មោះ ខាត់ថង, អ៊ីឌី, ស៊ុន, ដួក, ខ្វាន់ស៊ុន, អ៊ុន និងសួន ឈ្មោះទាំងនេះនៅក្រោមបញ្ជាការរបស់ អ៊ូច និងមេឃុំ សៅ ។

ឆ្នាំ១៩៦៥ អ៊ូច បានចាត់តាំងខ្ញុំឲ្យទាក់ទងក្រុមរបស់គាត់នៅតំបន់គិរីរម្យដែលមាន ឈ្មោះ ម៉ឺន, សុក និង ជុំ ។ ការទាក់ទងគឺត្រូវកសាងកម្លាំង និងពិនិត្យមើលមូលដ្ឋានបដិវត្តន៍នៅជើងភ្នំគិរីរម្យ ។ ឆ្នាំ១៩៦៦ អ៊ូច បានទៅធ្វើជាទាហាននៅក្រុងកំពង់ស្ពឺវិញ ពេលនោះ អ៊ូច បានចាត់តាំងឲ្យឈ្មោះ ទូច ចំរើន អតីតទាហាននៅកម្ពុជាក្រោមដែលជាប្អូនរបស់គាត់មកគ្រប់គ្រងខ្សែបន្តទៅទៀត ។ ឆ្នាំ១៩៦៧ ខ្ញុំបានទទួលការអប់រំពីកម្មាភិបាលបដិវត្តន៍ពីរនាក់ទៀតឈ្មោះ សំ និង ឌី ។ ក្រោយមកទៀត ទូច ចំរើន បានចាត់តាំងខ្ញុំ ខ្វាន់ស៊ុន និង ដួក ឲ្យចូលបង្កប់នៅក្នុងខ្សែបដិវត្តន៍នៅភូមិក្ដុងអាយ រហូតដល់ឆ្នាំ១៩៦៨ បក្សរៀបចំវាយបន្ទាយតាប្រើង ពេល



ជនរងគ្រោះនៅអតីតមន្ទីរសន្តិសុខ ប្អូកកួលស្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ - ១៩៧៩

នោះខ្ញុំបានយកផែនការរបស់បក្សទៅរាយការណ៍ឲ្យឈ្មោះ ទូច ចំរើន និងសក្តិ៣ ផុន នៅបន្ទាយតាប្រើងធ្វើឲ្យបក្សកម្ទេចខ្ទាំង មិនបានពីព្រោះទាហានបានដឹងខ្លួនមុនក៏រត់ចេញអស់ ក្រោយពី ទូច ចំរើន និងស័ក្តិ៣ ផុន រត់ទៅអស់ខ្ញុំក៏ដាច់ការទាក់ទងជាមួយនឹង ទូច ចំរើន រហូត ។

ចុងឆ្នាំដដែលនេះ បក្សបានដកកម្លាំងតស៊ូចូលព្រៃភ្នំ ខ្ញុំក៏ត្រូវទៅនៅភ្នំប្រមុះស្នា ប៉ុន្តែ ឈ្មោះ ដួក និង ខ្វាន់ស៊ិន នៅព្រៃក្រោយភូមិហើយនៅទាក់ទងជាមួយនឹងមេឃុំ សៅ ដដែល ។ ខ្ញុំបាននៅភ្នំប្រមុះស្នា បានមួយរយៈទើបបក្សចាត់តាំងខ្ញុំឲ្យមកបំផុសចលនាប្រជាជនប្រឆាំងខ្មាំងវិញនៅភូមិខ្ញុំដដែល ។ រយៈពេលនោះខ្ញុំបានទាក់ទងជាមួយនឹងខ្មែរចាស់មានឈ្មោះ ដួក, ខ្វាន់ស៊ិន និង អែម ពយ, ថង, ជ័យ, អ៊ុនឌី និង ស៊ិន ឲ្យធ្វើសកម្មភាពបំផុសប្រជាជនប្រឆាំងនឹងបដិវត្តន៍មួងទៀត ។ បន្ទាប់ពីនេះ បក្សបានដកខ្ញុំឲ្យចូលមកព្រៃវិញ ហើយខ្ញុំបានភ្ជាប់ការទាក់ទងជាមួយខ្មែរសេរីម្នាក់ឈ្មោះ មីន ដែលបានចូលបង្កប់ក្នុងជួរបដិវត្តន៍តាំងពីឆ្នាំ១៩៦៨ ។ ការជួបគ្នានេះគ្រាន់តែសួរពីសកម្មភាពដែលបានកសាងកន្លងមក ។ ឆ្នាំ១៩៦៩ ខ្ញុំបានដាច់ខ្សែទាក់ទងជាមួយ មីន ដោយអង្គការបានដក មីន ទៅធ្វើការនៅមូលដ្ឋានគិរីរម្យ កាលនោះខ្ញុំទៅធ្វើការក្នុងឃុំតាសាល ហើយខ្ញុំបានបន្តការទាក់ទងជាមួយឈ្មោះ អែម, ពយ, ខាត់ថង, ស៊ិន, អ៊ុន, សួន និង អ៊ុឌី ។ ឈ្មោះអ្នកទាំងអស់នេះ គឺនៅក្រៅជួរបដិវត្តន៍ ហើយបន្ទាប់មកទៀតខ្ញុំបានភ្ជាប់ខ្សែចាស់ដែលបង្កប់នៅក្នុងជួរបដិវត្តន៍មានឈ្មោះ ខ្វាន់ស៊ិន និង ដួក ។ ក្រោយមកទៀតខ្ញុំ និងបក្ខពួកខាងលើនេះបានមកទទួលផែនការពីមេឃុំ សៅ នៅភូមិប្រកដូវ ឃុំតាសាល ដែលមានខ្លឹមសារ ដូចជា បន្តការទាក់ទងជាមួយខ្សែខ្មែរសេរី ធ្វើសកម្មភាពក្នុងជួរបដិវត្តន៍ ក្តាប់សភាពការណ៍បដិវត្តន៍ដើម្បីរាយការណ៍ឲ្យមេឃុំ សៅ ។ សកម្មភាពខ្ញុំ និងបក្ខពួក ក្រោយបានទទួលផែនការរួចរាល់ហើយ ខ្ញុំបានរាយការណ៍ប្រាប់មេឃុំ សៅ ឲ្យយកទាហានមកចាប់ប្រជាជនបីនាក់នៅភូមិក្នុងអាយ ព្រមទាំងឲ្យយកទាហានត្រៀមស្កាត់ផ្លូវនីរសារទាក់ទងពីសង្កែជ្រុំ មកភ្នំបាយសំណុំ កុំឲ្យទាក់ទងគ្នាបាន ។ ពាក់កណ្តាលឆ្នាំដដែល ខ្ញុំបានធ្វើកងឈ្លបមាននាទីជាប្រធានអនុសេនាតូចរបស់ភាគនិរតី ៦ ឈ្មោះ ស៊ិន និង ដួក ជាគណៈឃុំ តាសាល ចំណែកឈ្មោះ មីន ប្រធានកងតូច សកម្មភាពខ្ញុំ និងបក្ខពួកបានរាយការណ៍ពីមូលដ្ឋានបដិវត្តន៍ទៅមេឃុំ សៅ ហើយខ្សែរបស់ខ្ញុំបានទៅកម្ទេចកម្លាំងបដិវត្តន៍របួសពីរនាក់ ។

ពាក់កណ្តាលឆ្នាំ១៩៧០ បងលេខាភូមិភាគនិរតី បានចាត់តាំងខ្ញុំទៅហៅឈ្មោះ មីន និង សាវ៉ាត ពីកោះកុងមកកំពង់ឆ្នាំង ។ ពេលដែលខ្ញុំទៅដល់ មីន ក៏បានខទ្មេសនាមឲ្យស្គាល់ឈ្មោះ គី អតីតទាហាន ។ ក្រោយមកទៀត ខ្ញុំ មីន និង សាវ៉ាត មានផែនការបំផ្លាញមន្ទីរស្រុកថ្មបាំង ដោយចាត់តាំងឲ្យ គី ទៅទាក់ទងទាហានបន្ទាយថ្មបាំង មកព័ទ្ធមន្ទីរស្រុក ។ លទ្ធផល ខ្មាំងដុតមន្ទីរអស់ ប៉ុន្តែមនុស្សគ្មានគ្រោះថ្នាក់ឡើយ ។ ពេលធ្វើសកម្មភាពនៅស្រុកថ្មបាំងហើយ ខ្ញុំក៏បាននាំ មីន និង សាវ៉ាត មកឃុំស្រែអណ្តូង ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មកជួបតា ម៉ុក លេខាភូមិភាគនិរតី ហើយ មីន និង សាវ៉ាត មករៀននយោបាយ នៅភូមិអញ្ចើជិត ស្រុកកំពង់ត្រឡាចក្រោម ។ ពេលនោះ មីន បានណែនាំខ្ញុំឲ្យស្គាល់ខ្សែ សេ.អ៊ីអា បីនាក់មានឈ្មោះ សាយ, សាន និង ប៉ុច នាទីគណៈសាលាបច្ចេកទេសភូមិភាគនិរតីទាំងបីនាក់ បច្ចុប្បន្នក្តាប់មិនបាន ។ បន្ទាប់មកឈ្មោះ មីន បានបញ្ចូលខ្ញុំជាភ្នាក់ងារ សេ.អ៊ី.អា តែម្តង ហើយអ្នកទទួលស្គាល់ខ្ញុំគឺឈ្មោះ សាយ, សាន និង ប៉ុច ។ ភារកិច្ចដែលខ្ញុំត្រូវធ្វើគឺកសាងកម្លាំង សេ.អ៊ី.អា បង្កប់ក្នុងជួរបដិវត្តន៍ និងបំផ្លាញបដិវត្តន៍តាមគ្រប់រូបភាព ។

ខែវិច្ឆិកា ឆ្នាំ១៩៧០ អង្គការបានចាត់តាំង មីន និង សាវ៉ាត ឲ្យទៅនៅស្រុកភ្នំស្រួច ចំពោះខ្ញុំវិញអង្គការបានចាត់តាំងឲ្យមកនៅតំបន់១៥ មាននាទីជាលេខាកងធំរបស់តំបន់១៥ ។ ដោយស្របតាមការចាត់តាំងរបស់អង្គការ ខ្ញុំ សាយ និង គី បានទាក់ទងភ្ជាប់ជាមួយខ្សែ សេ.អ៊ី.អា ដែលមានឈ្មោះ សោ, ម៉ និង សុខុម អតីតមកពីភូមិភាគខាងជើងទាំងបីនាក់ បច្ចុប្បន្នក្តាប់មិនបាន ។ ក្រោយមកទៀត អង្គការបានរៀបចំកងតំបន់១៥ មកជាកងវរសេនាតូច១៣ របស់ភាគពិសេសប្រចាំតំបន់១៥ ដែលពេលនោះ សោ បានឡើងជាមេបញ្ជាការ វរសេនាតូចតំបន់១៣ ឈ្មោះ ម៉ ជាអនុសេនាធំក្នុងវរសេនាតូចតំបន់១៣ ឈ្មោះ សុខុម ជាអនុសេនាធំ ក្នុងវរសេតូច តំបន់១៣ ។ កាលណោះ ខ្ញុំបានភ្ជាប់ខ្សែទាក់ទងជាមួយឈ្មោះអ្នកទាំងបីនាក់ខាងលើ ហើយក្រោយមកទៀតឈ្មោះ

សោ ម៉ន និង សុខុម បានធ្វើសកម្មភាពកសាងកម្លាំងប្រឆាំងបដិវត្តន៍
មានឈ្មោះ ថន អតីតទាហាន ឈ្មោះ ធីវ សកម្មភាពក្តាប់មិនបាន
និងឈ្មោះ សាន នាទីបញ្ជាការអនុសេនាធំ តំបន់១៥ ។ ឆ្នាំ១៩៧១
សោ បាននាំខ្ញុំទៅជួបឈ្មោះ សឿន នាទីសមាជិកតំបន់១៥ ទទួល
ភ័ស្តុភា នៅភូមិដីកពាង ជាមេដឹកនាំខ្មែរ សេ.អុី.អា និងបន្ទាប់មក
បក្ខពួករបស់ខ្ញុំបានទទួលផែនការពី សឿន និង សោ ឲ្យបន្តសកម្មភាព
ពង្រីកកម្លាំងក្នុងជួរយោធា បំផុសប្រជាជនឲ្យរត់ទៅរកខ្មាំង ទាក់ទង
ទាហានឲ្យមកកម្ទេចមូលដ្ឋានបដិវត្តន៍ និងកៀរប្រជាជន ។ ការងារ
ដែលត្រូវធ្វើបន្តទៅទៀតគឺ សឿន បានចាត់តាំងឈ្មោះ សារឿន គឺ
និង ថន ឲ្យទៅទាក់ទងជាមួយឈ្មោះ សាន ដើម្បីសហការបំផុស
ប្រជាជននៅភូមិគោរអស់ដប់គ្រួសារឲ្យរត់ទៅបន្ទាយត្រពាំងត្នោត ។
ក្រៅពីនេះ ទាក់ទងស័ក្តិ២ ភិន នៅបន្ទាយត្រពាំងត្នោត នាំទាហាន
មកកៀរប្រជាជនអស់ពីភូមិ គឺភូមិកោះដេស និងភូមិស្នួលខ្ពស់ ក្នុង
ឃុំចាន់តាសែន ។ ឆ្នាំ១៩៧២ អង្គការបានដក សារឿន មកសមរភូមិ
ស្រុកកណ្តាលស្ទឹង តំបន់១៥ មុនពេលមក ឈ្មោះ សឿន និង សោ
បានទាក់ទងជាប់ខ្មែរ សេ.អុី.អា ដែលមានឈ្មោះ សោម នាទីលេខា
ស្រុកកណ្តាលស្ទឹង បច្ចុប្បន្នសមាជិកសេនាធិការ ដើម្បីធ្វើសកម្មភាព
កសាងកម្លាំង និងបំផុសប្រជាជនឲ្យប្រឆាំងនឹងរដ្ឋអំណាចបដិវត្តន៍ ។
តាមរយៈ សោម និង សារឿន បានទាក់ទងជាមួយខ្មែរ សេ.អុី.អា
របស់គាត់បានម្នាក់ទៀតគឺឈ្មោះ ស៊ិន នាទីបញ្ជាការអនុសេនាធំ
ទ័ពស្រុកកណ្តាលស្ទឹង ហើយគាត់បានកសាងកម្លាំង សេ.អុី.អា បាន
ពីរនាក់ទៀតមានឈ្មោះ ទុយ និង បាន ។ ក្រោយមកទៀត សោម
បានចាត់តាំងឈ្មោះ សឿន និង ស៊ិន ឲ្យទាក់ទងជាមួយឈ្មោះ ផល
ដើម្បីធ្វើសកម្មភាពបំផុសប្រជាជននៅឃុំអាលាំងកែត និងឃុំ
កកោះ ធ្វើឲ្យមានបាតុកម្មដោយមានដំបង និងកាំបិតប្រឆាំងជាមួយ
រដ្ឋអំណាចភូមិឃុំ ដើម្បីទាមទារឲ្យអង្គការបង្កើតផ្សាររលក់ដូរវិញ ។

ឆ្នាំ១៩៧៣ សោម បានចាត់តាំងខ្ញុំ និង ផល ឲ្យទៅទាក់ទង
ជាមួយខ្មែររបស់គាត់ពីរនាក់ទៀត មានឈ្មោះ សឿង និង មុំ ដើម្បី
ធ្វើសកម្មភាពបំផុសចលនាប្រជាជនឲ្យធ្វើបាតុកម្មប្រឆាំងរបប
សមូហភាព ។ ក្រោយពេលបាតុកម្មហើយ ក្រុមបក្ខពួកខ្ញុំបានទៅ
រាយការណ៍ប្រាប់ សោម អំពីបាតុកម្មនេះ ហើយ សោម ក៏បាន
ចាត់តាំងឲ្យបក្ខពួកខ្ញុំធ្វើសកម្មភាពបំផ្លាញមន្ទីរពេទ្យស្នាក់ការរបស់
ភាគ ។ ពេលក្រុមខ្ញុំកំពុងត្រៀមក្នុងសមរភូមិ ស្របនឹងសភាពខ្មាំង
បុកខ្លាំង សារឿន បានបញ្ជាឲ្យដកទ័ពរត់តម្រង់ក្បែរមន្ទីរពេទ្យ ។
ពេលយន្តហោះកំពុងហោះតាមទ័ពដែលរត់ សារឿន បានចាត់តាំង
ឲ្យក្រុមខ្ញុំរត់តាមក្រោយ ។ ពេលទ័ពមកដល់មន្ទីរពេទ្យឲ្យផ្លោងគ្រាប់
ដាក់មន្ទីរពេទ្យ ក្នុងចម្ងាយ៦០ម៉ែត្រ ដោយបន្ទំធ្វើជាគ្រាប់ផ្លោង
របស់ខ្មាំង ធ្វើឲ្យពេទ្យរងរបួសពីរនាក់ និងស្លាប់គណៈឃុំម្នាក់ ។
ឆ្នាំ១៩៧៤ ក្រុមបក្ខពួកខ្ញុំបានមកវាយនៅផ្លូវលេខ២១ សង្កាត់ទន្លេ
បាសាក់ កាលនោះ សោម ហៅ ខ្ញុំ សំអុន, ផល, ស៊ិន, តូនីម, ម៉ៅ
ទៅប្រជុំនៅព្រែកតូច ។ ពេលនោះមានខ្មែរក្បត់នៅតំបន់២៥
ចូលរួមមានឈ្មោះ សុក, សារឹម, ម៉ង់, ម៉ាន់, ឌុក, ស្រេង, សុត និង
សឿន ក្រោយពីប្រជុំចប់ សោម បានខទ្ទេសនាមឲ្យស្គាល់ខ្មែរក្បត់
ទាំងអស់នេះ ។ ខែមិថុនា ក្នុងឆ្នាំដដែល ខ្ញុំបានឡើងជាលេខាវរ
សេនាធំ១៥៣ ហើយបន្ទាប់មក អង្គការប្រកាសលេខកង១១ ។
ក្រោយពេលប្រកាសរួច អង្គការបានដកវរសេនាធំ១៥៣ និង១៥២
មកវាយនៅខាងជើងភ្នំពេញ ។ សោម បានណែនាំឲ្យបក្ខពួកទាំង
អស់បន្តសកម្មភាពបំផ្លាញកម្លាំងបដិវត្តន៍ និងសម្ភាររបស់បក្សបន្ត
ទៅទៀត ។

ចុងឆ្នាំ១៩៧៤ ខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះ វ៉ៅ អតីត
កសិករ បច្ចុប្បន្នលេខាកងធំវរសេនាតូច៨១៣ វរសេនាធំ៨១
កងពល៨០១ ។ ខែមីនា ឆ្នាំ១៩៧៥ ខ្ញុំបានចាត់តាំងឲ្យ ស៊ិន នឿន
និង វ៉ៅ បំផ្លាញគ្រាប់អាកា១៥ឡាំង គ្រាប់បេ៤១ ១៦គ្រាប់
គ្រាប់៦០ម ៣០គ្រាប់ ដោយឲ្យយកទៅទម្លាក់ចោលក្នុងស្ទឹង
កំបុត នៅពេលយប់ ហើយរាយការណ៍ថាបាញ់អស់ដើម្បីរារាំង
ផែនការរបស់បក្សវាយផ្តាច់ភ្នំពេញ ។

## សកម្មភាពក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥

សោម បានហៅក្រុមបក្ខពួកខ្ញុំ មកប្រជុំនៅខាងជើងរោង
ចក្រកែវ ហើយសមាសភាពដែលចូលរួមប្រជុំមានឈ្មោះ ស៊ិន
តូនីម, សាវ៉ន, សឿន, ឌុក និង ស៊ុនហេង ខ្លឹមសារនៃការប្រជុំគឺ
ត្រួតពិនិត្យកម្លាំង ប្រមូលអាវុធគ្រាប់លាក់ទុកសម្រាប់វាយបក្ស
វិច្ឆេទកម្មបំផ្លាញសម្ភាររដ្ឋដោយបោកគ្រាប់បែកក្នុងផ្ទះថ្ម ដុតផ្ទះ
ដោយបន្ទំថាជាទាហាន បង្កប់ក្នុងក្រុងធ្វើសកម្មភាព ក្រោយទទួល
ផែនការរួចរាល់ហើយ ខ្ញុំបានចាត់តាំងឲ្យឈ្មោះ នឿន, ឈឺន, ទុយ,

សំបុក និង សឿន ឲ្យលួចដុតផ្ទះនៅផ្លូវកម្ពុជាក្រោមឆេះផ្ទះថ្មពីរខ្នង និងផ្ទះឈើពីរខ្នង ។

ខែមករា ឆ្នាំ១៩៧៦ ក្រុមខ្ញុំបានចាកចេញទៅខេត្តរតនគិរី ពេលនោះខ្ញុំ និង សំអុន បានភ្ជាប់ខ្សែជាមួយឈ្មោះ យ៉ា ក្រោយមកទៀត យ៉ា ក៏បានខទ្ទេសនាមក្រុមខ្ញុំឲ្យស្គាល់ខ្សែរបស់គាត់ប្រាំនាក់ទៀតមានឈ្មោះ គឹមអាន អនុលេខាតំបន់១០៧ ភី ណោ អនុលេខាតំបន់១០១ ភូមិភាគឦសាន ហោះ អនុលេខាស្រុកបរកែវ ឡាំង អនុលេខាស្រុកអណ្ដូងមាស និង សូវ៉ាង អនុលេខាស្រុកកុកឡាក់តំបន់១០១ ។ បន្ទាប់មក ឈ្មោះ គឹមអាន នាំខ្ញុំ និង សំអុន ទៅជួបបង្ហាញឲ្យស្គាល់ខ្សែដើម្បីទាក់ទងគ្នាបានងាយស្រួល ។

ដើមខែមេសា ឆ្នាំដដែលឈ្មោះ យ៉ា បានចុះមកមន្ទីររបស់សារឿន នៅបរកែវ ហើយ យ៉ា បានឲ្យ សំអុន ទៅហៅឈ្មោះ គឹមអាន និងគណៈស្រុក សូវ៉ាង និង ហោះ មកប្រជុំ ដែលមានខ្លឹមសារដូចជា ដកយោធាចេញពីផ្លូវ១៩ មកទល់ភ្នំ៥០០ ដើម្បីឲ្យយួនលួចចូលមកនៅភ្នំ៥០០ មិនឲ្យបាញ់ជាមួយនឹងយួនដោយឲ្យឈ្មោះ សារឿន ណែនាំទ័ពកុំឲ្យបាញ់គ្នាជាមួយយួន ។ ក្រោយពី គឹមអាន ដកកងតំបន់ចេញពីផ្លូវ១៩ មកនៅអូតាងចម្ងាយពីព្រំដែន៣០គីឡូម៉ែត្រ កងតំបន់១០៧ ក៏ទៅនៅលំដាត់ ហើយឈ្មោះ យ៉ា បានចាត់តាំងឈ្មោះ សារឿន, សំអុន, គឹមអាន ទៅទាក់ទងជនជាតិយួនម្នាក់ឈ្មោះ ថាច់ វ៉ាន់ នាទីបញ្ជាការកងពលតូចបន្ទាយលេខ២៣ ចម្ងាយពីព្រំដែនកម្ពុជា២គីឡូម៉ែត្រជាប់ផ្លូវលេខ១៩ ។ ខ្លឹមសារនៃការទាក់ទងគឺ ឲ្យយួនចូលមកពិនិត្យភូមិសាស្ត្រភ្នំ៥០០ និងភ្នំ១០២០ ស្នើឲ្យយួនជួយគ្រាប់ដើម្បីទុកត្រៀមផែនការ ។ ប្រាំថ្ងៃក្រោយមកក្រុមខ្ញុំបានធ្វើសកម្មភាពដឹកអង្ករពីរឡានចំនួន២០បាវ និងជ្រូក២០ក្បាលដើម្បីយកទៅឲ្យឈ្មោះ ថាច់ វ៉ាន់ នៅបន្ទាយលេខ២៣ ។ ពេលត្រឡប់មកវិញ ក្រុមខ្ញុំបានដឹកគ្រាប់អាកាចំនួន២០កេស មកលាក់នៅភូមិស្នួត ឃុំប៉ក់ ស្រុកបរកែវ ដោយប្រគល់ឲ្យ គឹមអាន អ្នកទុកដាក់ដើម្បីត្រៀមផែនការ ។

ខែឧសភា ឆ្នាំដដែល សារឿន និង សំអុន ពង្រីកកម្លាំងបានបួននាក់បន្ថែមទៀត មានឈ្មោះ ចិន្ដា, ចន្ថា, មឿន និង អែម ឈ្មោះទាំងបួននាក់នេះសុទ្ធតែខូចសីលធម៌ជាមួយនឹងនារីជនជាតិ ។ ក្រៅពីនេះខ្ញុំបានបញ្ចូលកម្លាំងរបស់ខ្ញុំដែលអប់រំបាន ហើយចាត់តាំងឲ្យធ្វើសកម្មភាពតាំងពីឆ្នាំ១៩៧៤ ។ ខែសីហា រយៈឆ្នាំដដែលខ្ញុំបានដាក់ផែនការឲ្យ សារីម ពង្រីកកម្លាំង និងបំផ្លាញកម្លាំងបដិវត្តន៍ដោយប្រើបច្ចេកទេសពេទ្យលួចបំពុល ហើយឲ្យ សារីម ទាក់ទងជាមួយឈ្មោះ សាន និង អាន ដើម្បីធ្វើសកម្មភាពដែលមានរយៈពេលកន្លះខែ លទ្ធផលគឺ កម្មាភិបាល និងយុទ្ធជនស្លាប់ជាង៣០នាក់ ។ បន្ទាប់មកទៀត ខ្ញុំបានហៅបក្ខពួកមកប្រជុំនៅមន្ទីរកងមាស សមាសភាពមានឈ្មោះ សរឿន, ប្រ, ស៊ិន, ធី និង ឆន ហើយខ្លឹមសារគឺ ពិនិត្យពីកម្លាំងក្បត់របស់ខ្ញុំនៅកងពល៨០១ រៀបចំកម្លាំងត្រៀមកម្ទេចកងពល៨០១ និងលាក់គ្រាប់១០៥ ដើម្បីត្រៀមវាយបដិវត្តន៍ ។ ក្រៅពីនេះ ខ្ញុំនិងបក្ខពួកខាងលើនេះ បានធ្វើចលនាប្រជាជននៅភូមិតេន ស្រុកបកែវរត់ទៅស្រុកយួន១០គ្រួសារ និងចាត់តាំងឲ្យឈ្មោះ ស៊ិន, សំបុក និង ណាក់ ធ្វើចលនាឲ្យប្រជាជននៅសៀមប៉ាង៣០គ្រួសាររត់ទៅលាវ ។ ទន្ទឹមនឹងនេះខ្ញុំ និងបក្ខពួកធ្វើចលនាយុទ្ធជនក្នុងអង្គភាពឲ្យរត់ទៅផ្ទះជាបន្តបន្ទាប់ ។

ចុងឆ្នាំ១៩៧៦ សារឿន និងខ្ញុំមានជំងឺបានមកសម្រាកនៅមន្ទីរពេទ្យ «ព-៩៨» ហើយខ្ញុំក៏បានជួប តូនឹម ដែលកាលនោះ តូនឹម បានធ្វើជាឆ្មួតបោកចានបោកឆ្នាំង ។ ខែកុម្ភៈ ឆ្នាំ១៩៧៧ ពេលខ្ញុំកំពុងដេកពេទ្យនៅជាន់ទី២ សោម និង ប៉ាង បានឡើងមកជួបខ្ញុំ ពេលនោះ និងបានប្រាប់ពីផែនការរបស់ខ្លួនដែលចាត់តាំងឲ្យ តូនឹម ធ្វើជាឆ្មួតនោះគឺ ដើម្បីក្ដាប់សភាពការណ៍ក្នុងមន្ទីរពេទ្យ កសាងកម្លាំងក្នុងពេទ្យ និងធ្វើវិទ្ធង្សនកម្មផ្សេងៗក្នុងមន្ទីរពេទ្យ ។ បន្ទាប់មកខ្ញុំ សារឿន និង តូនឹម នាំគ្នាចេញពីមន្ទីរពេទ្យ «ព-៩៨» ហើយបានហៅបក្ខពួកមកប្រជុំដែលមានខ្លឹមសារដូចជា ផ្សព្វផ្សាយពីសភាពការណ៍បក្សចាប់ខ្សែក្បត់នៅ «ព-៩៨» ជាបន្តបន្ទាប់ ដូច្នេះបក្ខពួកទាំងអស់ត្រូវប្រុងប្រយ័ត្នគ្រប់សកម្មភាព និងបំផ្លាញបក្សគ្រប់ផ្នែកតាមមុខសញ្ញានីមួយៗ ដើម្បីបង្វែងដានកុំឲ្យបក្សចាប់អារម្មណ៍ពីកន្លែងមួយៗ និងផែនការវាយមន្ទីរ «ស-២១» ដើម្បីរំដោះខ្សែដែលជាប់គុក ។ ក្រោយពីប្រជុំលើកផែនការចប់ អង្គប្រជុំក៏ត្រូវបានរំសាយ ឯខ្ញុំនឹងបក្ខពួកក៏បានជិះម៉ូតូមកមន្ទីរពេទ្យ «ព-៩៨» វិញ ។ ដល់ស្អែកឡើងពេទ្យក៏បញ្ជូនខ្ញុំ និង សារឿន មកមន្ទីរពេទ្យ «១៧ មេសា» អស់រយៈ៨ទៅ៩ថ្ងៃ ទើបអង្គការចាប់ខ្លួនខ្ញុំបាននៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៧ ។ **ហួ ថុនា**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសារ ចាប់ពីខែមេសា ដល់ ខែធ្នូ ឆ្នាំ២០១៦
















*កាលបរិច្ឆេទបញ្ចាំងៈ រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង១០ៈ០០ព្រឹក និង ម៉ោង៥ៈ១៥ រសៀល*

*ទីតាំងៈ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ*

លោក ម៉ែន ពិចិត្រ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ទូរស័ព្ទលេខ ០២៣ ២១៨ ០០៩
អ៊ីម៉ែល: truthmpechet@dccam.org
គេហទំព័រ: www.dccam.org l www.cambodiasri.org

**ខែមេសា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែមេសា វេលាម៉ោង ១ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «គុកឥតជញ្ជាំង» ដោយទូរទស្សន៍ ជាតិកម្ពុជា (៩៥ នាទី)

◆ ថ្ងៃទី៨ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ការផ្សារសម្ងាត់នៅមន្ទីរស-២១» ដោយ ដេវីត អូកូហ្វុណា (David Okuefuna) (៣០ នាទី)

◆ ថ្ងៃទី២២ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ឋាននរក៩ជាន់» ដោយ Cinema Dept. FPD ក្នុងឆ្នាំ១៩៨៧ (១៣១.២៨នាទី)

◆ ថ្ងៃទី២៩ ខែមេសា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ប្រាសាទអង្គរវត្តដែលកំបាំង» ដោយ Discover Magazine ក្នុងឆ្នាំ១៩៩៩ (៣០.១៥ នាទី)

**ខែឧសភា ឆ្នាំ២០១៦**

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា : ការស្លាប់ និង ការចាប់កំណើត» ដោយ Germany ក្នុងឆ្នាំ១៩៨០ (៩០ នាទី)

◆ ថ្ងៃទី២០ ខែឧសភា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «អគ្គការ» ដោយ Germany ក្នុងឆ្នាំ ១៩៨១ (៩០ នាទី)

**ខែមិថុនា ឆ្នាំ២០១៦**

◆ ថ្ងៃទី៣ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «សង្គ្រាមក្នុងព្រៃ» ដោយ Germany ក្នុងឆ្នាំ ១៩៨៣ (៩០ នាទី)

◆ ថ្ងៃទី១០ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «រវាងសន្តិភាព និងយុត្តិធម៌ : រឿងកន្ទួងហួសទៅសូមឲ្យកន្ទួងហួសទៅចុះ» ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) ក្នុងឆ្នាំ១៩៩៩ (៣៧នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលាម៉ោង ១០ ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង «ជីវិ២ (ជីវិជនភៀសខ្លួន) » ដោយ រិទ្ធី ប៉ាន់ ក្នុងឆ្នាំ១៩៨៩ (៦០ នាទី)

◆ ថ្ងៃទី១៧ ខែមិថុនា វេលា ម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត : ការសម្លាប់» ដោយ ភីធើ ហើខំ (Peter Hercombe) (៥១ នាទី)

**ខែកក្កដា ឆ្នាំ២០១៦**

◆ ថ្ងៃទី១ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សាក្សីកម្ពុជា» បណ្ណសាររបស់ ដេវីត ហក (David Hawk Archives) (១១១.៧នាទី)

◆ ថ្ងៃទី៨ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «សកម្មភាពគោរពវិញ្ញាណក្ខន្ធនៅបូជនីយដ្ឋានជើងឯក» ដោយ FPD ក្នុងឆ្នាំ១៩៩៨

◆ ថ្ងៃទី១៥ ខែកក្កដា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ព្រះអាទិទេពចុងក្រោយ» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១១៨នាទី)

◆ ថ្ងៃទី២២ ខែកក្កដា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «តំបន់អន្លង់វែង (តាម៉ុក)» ដោយ ជេមស៍ ជើរ៉ាន (James Gerrand) (១៧៤.៥៧នាទី)

◆ ថ្ងៃទី២៩ ខែកក្កដា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «កម្ពុជា ៣បូក៤ ឆ្នាំទីសូន្យ និងឆ្នាំទី១» ក្នុងឆ្នាំ១៩៧៩ (១៥៦នាទី)

**ខែសីហា ឆ្នាំ២០១៦**

◆ ថ្ងៃទី៥ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ស្រមោលអតីតកាល : រឿងចំនួនបួនដែលនិយាយអំពីការផ្សះផ្សា» ដោយ Express TV (១២០នាទី)

◆ ថ្ងៃទី១២ ខែសីហា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ :១៥ រសៀល បញ្ចាំងរឿង «ស្រមោលរបស់ ប៉ុល ពត» ដោយ អាមេនដា ផែក (Amanda Pike) ក្នុងឆ្នាំ២០០២ (២៥នាទី)

◆ ថ្ងៃទី១៩ ខែសីហា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ក្ដីសង្ឃឹមដ៏តិចតួចចេញពីវាលពិឃាត» ដោយ ធារ៉ា ដេលហ្កាដូ (Tiara Delgado) (៣៨នាទី)

◆ ថ្ងៃទី២៦ ខែសីហា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ទម្លាយភាពស្ងប់ស្ងាត់» ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា (៦៩នាទី)

**ខែកញ្ញា ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែកញ្ញា វេលាម៉ោង១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «បទសម្ភាសន៍ជាមួយ ប៉ុល ពត» ដោយ ភីធើ ហ្វ្រូបឺក (Peter Froberg) ក្នុងឆ្នាំ២០០៤ (៥១នាទី)

◆ ថ្ងៃទី៩ ខែកញ្ញា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «ប៉ុល ពត : ដំណើរទៅកាន់វាលពិឃាត» ដោយ ជេន ចនស្តុន (Jane Johnston) (៥០នាទី)

◆ ថ្ងៃទី១៦ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «យុត្តិធម៌ដែលបានពន្យារពេល និងយុត្តិធម៌ដែលបានបដិសេធ (ការកាត់ទោសមេដឹកនាំខ្មែរក្រហម)» ក្នុងឆ្នាំ២០០៥ (៥៤.២៤នាទី)

◆ ថ្ងៃទី២៣ ខែកញ្ញា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង «រឿងរ៉ាវពីទឹកដីកម្ពុជាក្រោម» (៧០នាទី)

**ខែតុលា ឆ្នាំ២០១៦**

◆ ថ្ងៃទី៧ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "នៅក្រោយជញ្ជាំងមន្ទីរស-២១" ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៧ (៣០ នាទី)

◆ ថ្ងៃទី១៨ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ដំណើរទៅកាន់វាលពិឃាត" ដោយ ជេន ចនស្តុន (Jane Jonhston) (៥០ នាទី)

◆ ថ្ងៃទី២១ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ដល់ពេលស្វែងរកយុត្តិធម៌" ដោយ KMF Films ក្នុងឆ្នាំ២០០៧ (៤០ នាទី)

◆ ថ្ងៃទី២៨ ខែតុលា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "មើលទៅមុខ មើលទៅក្រោយ" ដោយ DMC ក្នុងឆ្នាំ២០០៧ (៥២.៣០ នាទី)

**ខែវិច្ឆិកា ឆ្នាំ២០១៦**

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការរាំទៅរកការស្លាប់ : សត្វស្វា មន្តអាគម និងភាពរិលរល់របស់កម្ពុជា" ដោយ ចេនេត ហ្គាតនើ (Janet Gardner) ក្នុងឆ្នាំ២០១០ (៥៦ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ការកាត់ទោស ប៉ុល ពត នៅអន្លង់វែង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧" ដោយ ឡុង សារិន ក្នុងឆ្នាំ ១៩៩៧ (៤៣.៣០ នាទី)

◆ ថ្ងៃទី៤ ខែវិច្ឆិកា វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "៣ឆ្នាំ ៨ខែ ២០ថ្ងៃ" ដោយ រ៉ូសេន សេដណាតា (Roshane Saidnattar) ក្នុងឆ្នាំ២០០៩ (៩៨.០៦ នាទី)

◆ ថ្ងៃទី២៥ ខែវិច្ឆិកា វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ក្មេងសម្រាប់ដាក់លក់" ដោយ NBC TV ក្នុងឆ្នាំ២០០៤ (៤៣ នាទី)

**ខែធ្នូ ឆ្នាំ២០១៦**

◆ ថ្ងៃទី២ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "វិប្បដិសារី" ក្នុងឆ្នាំ២០០៨ (Royal Archives)

◆ ថ្ងៃទី៩ ខែធ្នូ វេលាម៉ោង១០ព្រឹក និង ម៉ោង៥ : ១៥ រសៀល បញ្ចាំងរឿង "កងទ័ពខ្មែរក្រហម" ដោយ ព្រូណូ ការ៉ាតេ (Bruno Carette) និង សៀន មេត្តា (Sien Meta) ក្នុងឆ្នាំ ២០០៧ (៩៥ នាទី)

◆ ថ្ងៃទី១៦ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ពេលព្រះអាទិត្យអស្តង្គត" ដោយ ព្រះបាទ នរោត្តម សីហនុ

◆ ថ្ងៃទី២៣ ខែធ្នូ វេលាម៉ោង ១០ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "កុំស្មានបងភ្លេច : ខ្មែរបាត់បង់តន្ត្រីរ៉ក់" ដោយ ចន ពីរ៉ូស៊ី (Jonh Pirozzi) (១០៧ នាទី)

◆ ថ្ងៃទី៣០ ខែធ្នូ វេលាម៉ោង ១០ ព្រឹក និង ម៉ោង ៥ : ១៥ រសៀល បញ្ចាំងរឿង "ក្បង់ទឹកទន្លេ" ដោយ កល្យាណី ម៉ម ក្នុងឆ្នាំ២០១២ (៨៣ នាទី)

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truththida.s@dccam.org ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthmpechet@dccam.org ។

**◆ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# មនោសញ្ចេតនា

*ដកស្រង់ចេញពីឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ១០ ខែតុលា ឆ្នាំ១៩៧៥ (D២១៣៨៤)*

ជនបដិវត្តន៍ ជនកុម្មុយនីស្ត ជាមនុស្សដែលមានមនោសញ្ចេតនាខ្ពង់ខ្ពស់បំផុត ស្មោះត្រង់បំផុត និងល្អបរិសុទ្ធបំផុតចំពោះក្រុមគ្រួសារ ប្រពន្ធកូន ប្តីសី ម៉ែ បងប្អូន ក៏ដូចជាចំពោះប្រជាជនកម្ពុជាទាំងមូលដែរ ។ តែមនោសញ្ចេតនានេះ ជាមនោសញ្ចេតនាបដិវត្តន៍ ដែលផ្សារភ្ជាប់ទៅនឹងវាសនាប្រទេសជាតិ និងប្រជាជនទាំងមូល និងផ្សារភ្ជាប់ទៅនឹងវណ្ណៈក្រីក្រទាំងស្រុង ។ ដូច្នេះ មិនមែនជាមនោសញ្ចេតនាបុគ្គលសួនតួចង្អៀតចង្អល់ នៅជុំវិញតែអាត្មាខ្លួនប៉ុណ្ណោះទេ ។

## ដប់ឆ្នាំក្រោយឃ្លាតចាកពីភូមិកំណើត

បាត់ដឹង ជាទីប្រជុំជនផ្សារតូចមួយ និងជាដំណាក់ផ្លូវរថភ្លើងមុនដំបូងបំផុត ដែលចេញពីភ្នំពេញទៅបាត់ដំបង ។ ក្នុងសម័យសង្គ្រាមឈ្លានពានដ៏កំណាចឃោរឃៅរបស់ចក្រពត្តិអាមេរិក និងបរិវារជាងប្រាំឆ្នាំកន្លងទៅនេះ បាត់ដឹងបានស្ថិតនៅជាសមរភូមិដែលក្តៅបំផុតគ្រប់ពេលវេលា ហើយព្រមជាមួយនេះ បាត់ដឹងក៏បានក្លាយទៅជាគំនរផេះផង់ ដែលជានិមិត្តរូបនៃមហាវិនាសកម្មរបស់សង្គ្រាមឈ្លានពានដ៏កំណាចឃោរឃៅនេះដែរ ។

ក្រោយរំដោះទូទាំងប្រទេស ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនបាត់ដឹង ក៏បានវិលត្រឡប់មកកាន់ភូមិកំណើតរបស់ខ្លួនវិញ ។ ក្រោមការដឹកនាំ និងជួយឧបត្ថម្ភជុំជ្រើមគ្រប់បែបយ៉ាងទាំងខាងស្មារតី ទាំងខាងសម្ភារ ទាំងខាងនយោបាយ បងប្អូនកសិករយើងនៅបាត់ដឹង បានរួបរួមសាមគ្គីគ្នាចាត់តាំងជាសហករណ៍ផលិតកម្ម ហើយប្រយុទ្ធបោសសម្អាតស្លាកស្នាមសង្គ្រាម ប្រយុទ្ធរៀបចំស្រុកភូមិជាថ្មីឡើងវិញ និងប្រយុទ្ធបង្កបង្កើនផលឲ្យទាន់រដូវ ដើម្បីឧបត្ថម្ភខ្លួនផង និងរួមចំណែកស្តាសេដ្ឋកិច្ច កសាង និងការពារប្រទេសផង ។

ពេលដែលបងប្អូនកសិករយើងត្រឡប់មកដល់ភូមិកំណើតរបស់ខ្លួនវិញ ឃើញតែគំនរផេះ គំនរធ្យូង និងដង្គត់ដើមសសរផ្ទះខ្មៅរលេ ឃើញដើមឈើ ដំណាំដំណោចវិនាសហិនហោចអស់គ្មានសល់ ។ បងប្អូនកសិករយើងមានការក្រេវក្រោធជាខ្លាំង ហើយចងគំនុំជាមួយអាចោរចក្រពត្តិអាមេរិក និងពួកអាចោរក្បត់ជាតិ លន់ នល់ - សិរិ មតៈ - សឺង ង៉ុកថាញ់ - ចេង ហេង - អ៊ិន តាំ - ឡុង បូរេត - សុស្តែន ដែលជាឆ្កែបម្រើជាប់ថ្លៃរបស់វាអស់មួយជីវិតរហូតដល់តកូនតចៅទៀត ។ បងប្អូនប្តេជ្ញាប្រែក្លាយកំហឹង និងការឈឺចាប់ទាំងនេះ ឲ្យទៅជាកម្លាំងប្រយុទ្ធខ្លាំងក្លា ដើម្បីកសាងស្រុកភូមិរបស់បងប្អូនឡើងវិញ ឲ្យល្អស្អាត និងសម្បូរសប្បាយលើសដើម និងជំរុញចលនាបង្កបង្កើនផលឲ្យផុសផុលខ្លាំងក្លាបំផុត ដើម្បីឧបត្ថម្ភខ្លួនស្តាសេដ្ឋកិច្ចកសាងប្រទេសឲ្យចម្រើនលូតលាស់ខ្លាំងក្លា សម្បូរសប្បាយបានឆាប់រហ័ស ។ គ្រាន់តែត្រឡប់មកដល់ស្រុកភូមិវិញភ្លាម បងប្អូនបានរៀបចំចាត់ចែងកម្លាំង វាយសម្រុកធ្វើការងារទាំងយប់ទាំងថ្ងៃ ។ ក្រុមខ្លះនាំគ្នាសង់ផ្ទះចែកគ្នានៅ ក្រុមខ្លះរៀបចំបោសសម្អាតកាកសំណល់សង្គ្រាមឈ្លានពាន រើកកាយចោលនូវកម្ទេចកម្ទីជាអំបែងគ្រាប់បែក សំបកគ្រាប់កាំភ្លើងធំ-តូច និងកម្ទេចកម្ទីអាវុធយុទ្ធភណ្ឌផ្សេងៗរបស់ខ្មាំង ដែលចោលរាយប៉ាយពាសពេញដីពាសពេញស្រែ ។ បងប្អូនខ្លះទៀតក៏វាយសម្រុកលើកភ្លឺស្រែតាមរបៀបថ្មី គឺរំលាយស្រែតូចៗចូលគ្នាអស់ ហើយលើកភ្លឺថ្មីធំៗ ត្រង់ភ្លឺង កាត់ជាក្រឡាខាត់ខ្វែង ដើម្បីទប់ទឹកភ្លៀងឲ្យដក់ជាប់នៅក្នុងស្រែផង ចំណេញផ្ទៃដីស្រែបានច្រើនជាងមុនផង និងអំណោយដល់ការភ្ជួររាស់ជាសមូហភាពដែលប្រើនង្គ័លនាស់មួងៗរាប់សិបគ្រឿងផង ។ បងប្អូនខ្លះទៀតនាំគ្នាលើកទំនប់នៅកន្លែងដីទំនាបដែលទឹកទន្លេឡើងដល់ ដើម្បីទប់ទឹកទន្លេក្នុងរដូវសម្រកកុំឲ្យហូរចាក់ទៅក្នុងទន្លេវិញអស់ដោយឥតប្រយោជន៍ ។ បងប្អូនខ្លះទៀត នាំគ្នាជីកប្រឡាយតូចមធ្យមតភ្ជាប់មកស្រែដើម្បីបង្ហូរទឹកបញ្ចេញបញ្ចូលស្រែ ។ បងប្អូននាំគ្នាវាយសម្រុកធ្វើការងារទាំងនេះ សស្រោកសស្រាំទាំងយប់ទាំងថ្ងៃ ដូចកាលសម័យសង្គ្រាមបដិវត្តន៍ ដែលបងប្អូន

ប្រយុទ្ធវាយកម្ទេចខ្មាំងដូច្នោះដែរ ។ ដូច្នេះហើយ បានជាប្រាំខែក្រោយរំដោះ បាត់ដឹងដែលជាទីរហោឋាន ពោរពេញទៅដោយវិនាសកម្មគ្រប់ប្រកល្លក បានប្រែក្លាយទៅជាស្រុកភូមិថ្មីមួយយ៉ាងស្រស់បំព្រង ដែលពោរពេញទៅដោយជីវិត និងសកម្មភាពរស់រវើក និងមមាញឹកគ្រប់ពេលវេលា ។ ផ្ទះតូចៗ តែស្អាតបាត សមរម្យជាច្រើនខ្នងតម្រៀបជួរគ្នាត្រង់ភ្លឹងដោយសណ្ដាប់ធ្នាប់ ។ នៅគ្រប់ភូមិជុំវិញផ្ទះ គេឃើញមានដំឡូង ល្ហុង និងបន្លែបង្ការផ្សេងៗ ចាប់ផ្ដើមមានជីវិតដុះលូតលាស់ជាបន្តបន្ទាប់ ។ នៅតាមវាលស្រែ សន្ទូងកំពុងតែលាស់ស្លឹកថ្មីខៀវខ្ចីពាសពេញផ្ទៃទាំងអស់ ។ តាមស្រែ តាមប្រឡាយ និងទំនប់ដែលបងប្អូនទើបរៀបចំថ្មី ក៏មានទឹកភ្លៀងដក់ពាសពេញ ។ ដូច្នេះហើយ បានជាឆ្នាំនេះទោះបីមានការយឺតយ៉ាវបន្តិចក៏ដោយ ទោះបីនៅប៉ែកខាងពាយ័ព្យភ្នំពេញ មិនសូវមានភ្លៀងធ្លាក់ក៏ដោយ ក៏បងប្អូនកសិករយើងនៅបាត់ដឹង វាយសម្រុកធ្វើស្រែបានអស់ដី និងទាន់ពេលវេលា ។ ឥឡូវស្រូវរបស់បងប្អូនកំពុងបែកគុម្ពត្រគុំត្រគោលល្អណាស់ ធ្វើឲ្យបងប្អូនកសិករយើង ដែលជាម្ចាស់ពិតប្រាកដ មានការរំភើបរីករាយ មានក្ដីសង្ឃឹម និងជំនឿជឿជាក់លើអនាគតដ៏ភ្លឺស្វាងរបស់ស្រុកភូមិខ្លួន ក៏ដូចអនាគតត្រចះត្រចង់របស់ប្រទេសជាតិកម្ពុជាសម័យថ្មីដែរ ។

ថ្ងៃមួយ នៅពេលល្ងាច ក្រោយពីរួចរាល់ពីការងារស្រែ និងការងារផ្សេងៗ និងក្រោយពីហូបបាយរួចរាល់ហើយ សមាជិកសហករណ៍បាត់ដឹង បានមកមូលមីរជួបជុំគ្នា ដើម្បីប្រជុំជីវភាពតាមទម្លាប់ជាប្រក្រតីរបស់សហករណ៍ ។ ពេលនោះ ស្រាប់តែឃើញយុទ្ធជនកងទ័ពនៃកងកម្លាំងប្រដាប់អាវុធបដិវត្តន៍យើងម្នាក់ ស្ពាយបាឡូនៅលើខ្នងដើរចូលមកក្នុងភូមិ មិត្តយើងសម្លឹងមើលនាយអាយដោយក្ដីរំភើបរីករាយផង និងដោយសភាពស្រងូតស្រងាត់ផងហាក់ដូចជានឹកឃើញដល់អនុស្សាវរីយ៍កម្សត់អ្វីមួយ ។ ឃើញដូច្នោះ ពូប្រធានសហករណ៍ ក៏ស្ទុះចេញពីអង្គប្រជុំ មកចាប់ដៃសួរសុខទុក្ខ និងទទួលយុទ្ធជនកងទ័ពបដិវត្តន៍យើង ដោយរាក់ទាក់កក់ក្ដៅជាទីបំផុត ។ ដោយពេលនោះ ថ្ងៃលិចព្រលប់ព្រាលៗហើយ ពូប្រធានសហករណ៍ ក៏អញ្ជើញមិត្តយុទ្ធជនកងទ័ពបដិវត្តន៍យើង ចូលសំណាក់នៅភូមិនេះសិន ហើយក៏សាកសួរដំណើរដើមទង តើមិត្តយើងមានភារកិច្ចទៅណាមកណា ។ ពេលនោះ ប្រជាជនស្រី-ប្រុសចាស់-ក្មេង នៅក្នុងសហករណ៍ទាំងអស់ ក៏បានមកសាកសួរសុខទុក្ខមិត្តយើងដែរ ។ មិត្តយើងក៏ចាប់ផ្ដើមនិយាយរ៉ាយរ៉ាប់ជម្រាបពូប្រធានភូមិ ដូចតទៅ ៈ

«ខ្ញុំគ្មានភារកិច្ចអីទេ ។ ខ្ញុំមកបាត់ដឹងនេះ គឺដើម្បីមកលេងភូមិកំណើតរបស់ខ្ញុំ ក្រោយដែលបានឃ្លាតចាកចេញអស់រយៈជាងដប់ឆ្នាំមកហើយ» ។

ឮពាក្យសំដីទាំងនេះភ្លាម បងប្អូនកសិករយើងទាំងប្រុសស្រីចាស់ក្មេង នាំគ្នាភាំងរកនឹក តើមិត្តហ្នឹងជានរណា? ។ មិត្តយើងក៏និយាយរ៉ាយរ៉ាប់ជាបន្តទៀត ៈ «ខ្ញុំឈ្មោះ ភិន មានដើមកំណើតនៅភូមិបាត់ដឹងនេះឯង ឪពុកម្ដាយខ្ញុំ ជាកសិករនៅបាត់ដឹងនេះឈ្មោះ សុខ និង យឹម ។ ខ្ញុំមកនេះ គឺដើម្បីមកលេងសាកសួរសុខទុក្ខឪពុកម្ដាយខ្ញុំ តែមិនដឹងជាគាត់រស់ ឬស្លាប់អស់ទៅហើយទេ ព្រោះភូមិ និងផ្ទះរបស់គាត់ ឃើញត្រូវគ្រាប់បែកឆេះខ្ទេចខ្ទីអស់ទៅហើយ ។ តើ មីងមា បងប្អូន ដែលទើបអញ្ជើញមកកសាងភូមិនេះឡើងវិញ មានធ្លាប់ស្គាល់ ធ្លាប់ឮឈ្មោះនេះដែរឬទេ?

ពេលនោះ អ៊ំចាស់ៗទាំងអស់ក៏លាន់មាត់ថា «អើ! ក្មួយ ភិនទេឬ?» ។ សំឡេងខ្សៀវខ្សា ក៏ផុះចេញឡើងពីក្នុងចំណោមបងប្អូនកសិករយើង ដែលបានមកចោមរោមសួរសុខទុក្ខមិត្ត ។ ភ្លើងចន្លុះពីរបី ដែលតាមធម្មតាគេទុកអុជបំភ្លឺ តែពេលមានការចាំបាច់ប៉ុណ្ណោះ ក៏ត្រូវបានអុជបំភ្លឺឡើងព្រោងព្រាត ។ នៅពេលដែលគេយកភ្លើងចន្លុះមកបំភ្លឺមើលមុខមិត្តភិន បានច្បាស់លាស់ អ៊ំស្រីម្នាក់មាឌស្គមស្តើង សម្បុរខ្មៅ សក់ស្កូវសសំព្រោងអស់ទៅហើយ ក៏បានស្ទុះមកឱបរឹតមិត្តភិន ដោយទឹកភ្នែកហូរជោគជាំថ្ពាល់ ហើយបន្លឺវាចារថា ៈ «កូនភិន! កូនភិន!» មិនដាច់ពីមាត់ ។ អ៊ំហូរទឹកភ្នែកសុភមង្គលដោយមិនដឹងខ្លួន ។ អ៊ំរំភើបញាប់ញ័រ និងត្រេកអរក្រៃលែង ដោយបានជួបមុខកូនប្រុសសម្លាញ់របស់អ៊ំ ដែលអ៊ំនឹកស្មានថាស្លាប់បាត់យូរយាណាស់ទៅហើយ ។ អ៊ំរកពាក្យអ្វីមកនិយាយជាមួយកូនពុំបានឡើយ ព្រោះបំពង់កអ៊ំឡើងអួលណែន បេះដូងអ៊ំបុកខ្លាំងៗញាប់រន្ថើន ។ អារម្មណ៍អ៊ំ រំភើបរីករាយឡើងស្រាយខ្លួនហាក់បីដូចជាកំពុងស្ថិតនៅក្នុងភាពយល់សប្ដិល្អមួយ ។ អ៊ំសម្លឹងមើលមុខកូនមិនដាក់ភ្នែកសោះ ហើយបន្លឺវាចារដដែលៗថា «កូនភិន! កូន ភិន!» តែប៉ុណ្ណោះ ។ ចំណែកឯបងប្អូនកសិករឯទៀត

ទាំងអស់ ដែលឃើញព្រឹត្តិការណ៍នេះ ក៏មានការរំភើបឥតខបមាដែរ ។ បងប្អូនទាំងអស់គ្នារលីងរលោងទឹកភ្នែកដោយមិនដឹងខ្លួន ។

មិត្ត ភិន នៅចំពោះមុខព្រឹត្តិការណ៍ដ៏សែនរំភើបនេះ ក៏ហាក់ដូចជាភាំងអស់មួយសន្ទុះដែរ រួចមិត្តក៏ចាប់ផ្តើមនិយាយមុនគេ ដោយទឹកមុខញញឹមញញែមពោរពេញទៅដោយមនោសញ្ចេតនាបដិវត្តន៍ជ្រាលជ្រៅបំផុត ។

«យី ! មីងមា បងប្អូនទាំងអស់គ្នា សុទ្ធសឹងជាអ្នកភូមិចាស់យើងទាំងអស់គ្នាទេតើ! យី ! ម៉ែខុសប្លែកពីមុនច្រើនណាស់ ! ដប់ឆ្នាំកន្លងផុតទៅ ម៉ែចាស់ច្រើន ខ្ញុំមើលម៉ែសឹងតែមិនស្គាល់ ! »

មិត្តយើងក៏បន្តសាកសួរសុខទុក្ខពីក្រុមគ្រួសារ សាកសួរសុខទុក្ខពីប្រជាជនភូមិបាត់ដឹងយើងទាំងអស់ ។ បងប្អូនប្រជាជនយើង និងពូប្រធានសហករណ៍ ក៏បាននិយាយរ៉ាយរ៉ាប់អំពីសុខទុក្ខ អំពីជីវភាព អំពីការតស៊ូរបស់ប្រជាជនយើង ក្នុងភូមិបាត់ដឹងក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ ជម្រាបមិត្តយ៉ាងហូរហែក្បោះក្បាយទាំងអស់គ្នា ។ តាមរយៈការនិយាយសារស័ព្ទរបស់អ៊ំ យឹម ជាម្តាយមិត្ត មិត្តក៏បានដឹងដំណឹងអំពីគ្រួសារមិត្តទាំងអស់ ។ គឺឪពុកមិត្តត្រូវខ្មាំងបាញ់សម្លាប់នៅដើមឆ្នាំ១៩៧២ ក្នុងពេលដែលគ្រួសារមិត្ត និងបងប្អូនកសិករយើងមួយចំនួនច្រើនទៀត នាំគ្នារត់ចូលទៅតំបន់រំដោះ ។ ប្អូនប្រុសមិត្តបីនាក់ បានចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ ហើយក្នុងនេះមានពីរនាក់ ត្រូវពលីជីវិតលើសមរភូមិភ្នំបាសិតក្នុងឆ្នាំ១៩៧៤ ។ ប្អូនស្រីមិត្តពីរនាក់ទៀត ក៏បានចូលបម្រើការងារក្នុងជួរបដិវត្តន៍ហើយដែរ ។ ប្អូនស្រីទីមួយជាយុទ្ធនារីក្នុងកងទ័ពនារី ។ ប្អូនស្រីទីពីរ ធ្វើពេទ្យបដិវត្តន៍ ហើយសព្វថ្ងៃព្ចថា មកបម្រើការងារនៅផ្ទះពេទ្យ ១៧ មេសា ឯក្រុងភ្នំពេញ ។ ដូច្នេះ ម្តាយមិត្តនៅតែម្នាក់ឯងគត់ជាមួយនឹងប្រជាជនក្នុងភូមិក្នុងសហករណ៍បាត់ដឹង ។

មិត្តក៏សួរទៅម្តាយថា «បើដូច្នោះ សព្វថ្ងៃម៉ែនៅតែម្នាក់ឯងហើយ! » ។ តើម៉ែមានការលំបាក ស្រួលយ៉ាងណាខ្លះ ក្នុងជីវភាពប្រចាំថ្ងៃ? »

អ៊ំយឹម ឆ្លើយតបកូនវិញ ដោយទឹកមុខញញឹមពព្រាយពោរពេញទៅដោយមោទនភាពបដិវត្តន៍ខ្ពង់ខ្ពស់បំផុត ។

« កូនកុំព្រួយ ! ម៉ែសព្វថ្ងៃរស់នៅសប្បាយរីករាយ ថ្លៃថ្នូរ និងមានកិត្តិយសខ្ពង់ខ្ពស់ណាស់! ក្នុងឋានៈម្តាយជាមាតាយុទ្ធជនបដិវត្តន៍ ដែលបានលះបង់កូនប្រុសកូនស្រីជាទីស្នេហាបណ្តូលចិត្តទាំងអស់ឲ្យចូលបម្រើបដិវត្តន៍ រួមចំណែកវាយកម្ទេចខ្មាំង រំដោះប្រទេស រំដោះប្រជាជន និងរំដោះវណ្ណៈកសិករក្រីក្រយើងនេះ ម្តាយត្រូវបានអង្គការ និងបងប្អូនប្រជាជនយើងជួយឧបត្ថម្ភទាំងខាងស្មារតី ទាំងខាងសម្ភារជាប់ជានិច្ច ។ ឥឡូវពេលត្រឡប់មករស់នៅក្នុងស្រុកភូមិដើមវិញ ដោយការជួយឧបត្ថម្ភផ្តួងផ្តើមអំពីអង្គការម៉ែ ព្រមទាំងប្រជាជនភូមិយើងទាំងអស់ ក៏បានចូលជាសមាជិកសហករណ៍ផលិតកម្មទាំងអស់គ្នាហើយ ។ មានសហករណ៍ផលិតកម្ម គឺកសិករក្រីក្រយើងរស់ ហើយរស់ដោយសុខស្រួល ក្នុងកិត្តិយសថ្លៃថ្នូរ និងមានការធានាអះអាងមួយរយភាគរយផង ។ ម៉ែគ្មានកូនចៅនៅជិតខ្លួនមែន តែកូនចៅរបស់សមាជិកសហករណ៍ទាំងអស់ ជាកូនចៅរបស់ម៉ែ ។ គ្រប់ភារកិច្ចការបង្កបង្កើនផលក្តី សង្គមកិច្ចក្តី សុខាភិបាលក្តី ការរស់នៅស៊ីចុក ស្លៀកពាក់ប្រចាំថ្ងៃក្តី គឺសមូហភាពនៅក្នុងសហករណ៍ដោះស្រាយទាំងអស់ ។ ខ្លួនម៉ែទោះបីចាស់ហើយកម្លាំងខ្សោយពុំអាចធ្វើការងារធ្ងន់ដូចគេបាន ក៏ម៉ែមានភារកិច្ចស្រាលៗនៅភូមិ រួមចំណែកក្នុងការកសាងពង្រឹងពង្រីកសហករណ៍យើង ទៅតាមលទ្ធភាពរបស់ម៉ែដែរ ។ សហករណ៍ក៏ឧបត្ថម្ភចិញ្ចឹមម៉ែវិញឲ្យបានសមរម្យគ្រប់គ្រាន់តាមសេចក្តីត្រូវការ»

រួចអ៊ំ យឹម ក៏សាកសួរសុខទុក្ខកូនវិញ សាកសួរអំពីដំណើរជីវភាពរបស់កូនក្នុងរយៈដប់ឆ្នាំ ដែលព្រាត់ប្រាស់គ្នាកន្លងទៅនេះ ។ ពេលនោះ អ៊ំយឹម ក៏រំឭកដំណាលរឿងដ៏ចម្លែកមួយប្រាប់កូន ហើយដែលនៅជាអាថ៌កំបាំងចំពោះរូបអ៊ំ រហូតដល់សព្វថ្ងៃនេះ ។ អ៊ំនិយាយថា ៖

«កាលពីឆ្នាំ១៩៦៨ ខ្មាំងនៅភ្នំពេញ បានមកនាំម៉ែទៅកន្លែងគិញពិសេស ហើយនាំទៅជួបនឹងយុវជនម្នាក់ ដែលវាចាប់ពីកំពង់ចាមមក ហើយដែលវាវាយដំប្រំធាក់ឡើងជាំ ហើមស្តុលពេញខ្លួនប្រាណ ពេញមុខមាត់អស់ទៅហើយ ។ ទៅដល់វាចង្អុលប្រាប់ម៉ែថា យុវជននោះជារូបកូន ហើយវានិយាយថា បើយុវជននោះ ជារូមកូនម៉ែពិតប្រាកដមែន វានឹងដោះលែងប្រគល់មកឲ្យម៉ែវិញភ្លាមមួយរំពេច ។ ពេលម៉ែចូលទៅជួបនឹងយុវជននោះ ទោះបីជាមានមុខមាត់បែកជាំខ្មៅរលួ អស់ហើយក្តី ក៏ម៉ែមើលទៅឃើញច្បាស់ថា

ជារូបកូនមែន ។ ម៉ែស្ទុះទៅឱបយុវជនកម្សត់នោះយំ ហើយហៅថា កូនៗ!» តែយុវជននោះបានបេះដៃម៉ែចេញ ហើយនិយាយបដិសេធយ៉ាងដាច់អហង្ការថា គេមិនមែនជាកូនរបស់ម៉ែទេ គេមិនដែលស្គាល់ម៉ែទេ ។ គេថាឪពុកម្តាយគេស្លាប់អស់ទៅហើយ គេជាកូនកំព្រាអនាថាតែម្នាក់ឯងគត់ ។ ម៉ែក៏ថយមកអង្គុយសម្លឹងយុវជននោះ ដោយមនោសញ្ចេតនាអាណិតអាសូរក្រៃលែង ហើយម៉ែគិតក្នុងចិត្តថា ប្រហែលជាម៉ែមានការភាន់ច្រឡំមែនហើយ ។ តែទោះបីមិនមែនជារូបកូនក៏ដោយចុះ ក៏ម៉ែសុខចិត្តទទួលធ្វើជាកូនបង្កើតរបស់ម៉ែដែរ ដើម្បីឲ្យខ្មាំងដោះលែងយុវជននោះ ឲ្យរួចចាកផុតពីទុក្ខទោស និងទារុណកម្មសព្វបែបយ៉ាង ។ ម៉ែក៏អង្វរកយុវជននោះឲ្យសុខចិត្តឆ្លើយទទួលថាជាកូនម៉ែមែន ម៉ែធានារ៉ាប់រងចិញ្ចឹមគេទាំងអស់ ។ តែទោះបីម៉ែយំស្រែក ម៉ែអង្វរកយ៉ាងណា ក៏យុវជននោះនៅតែបដិសេធដាច់អហង្ការថា គេមិនមែនកូនចៅម៉ែទេ ថាគេមិនដែលស្គាល់ម៉ែទេ ។ ទីចុងបំផុត យុវជននោះអង្គុយបែរខ្នងដាក់ម៉ែ មិនទាំងខ្ជីនិយាយស្តីរកម៉ែមួយម៉ាត់ផង ។ ដោយចាញ់ចំណេះ ទាល់គំនិត ម៉ែក៏ដើរចេញពីបន្ទប់ឃុំឃាំងនោះមកវិញ ហើយនិយាយទាំងបន្ទុំចិត្តប្រាប់ខ្មាំងថា យុវជននោះ មិនមែនជាកូនរបស់ម៉ែទេ ម៉ែពុំដែលស្គាល់គេទេ ។ រួចម៉ែក៏វិលត្រឡប់មកផ្ទះវិញ ទាំងក្តីសោកសៅក្នុងចិត្ត ទាំងនឹកចម្លែកក្នុងចិត្តមិនអស់មិនហើយ មិនជ្រះស្រឡះ ។ រហូតដល់សព្វថ្ងៃនេះ ម៉ែចេះតែនឹកគិតមមៃជាប់ តើវាសនារបស់យុវជននោះទៅជាយ៉ាងម៉េចទៅហើយ? » ។

មិត្ត ភិន ស្តាប់ម្តាយនិយាយរឿងរ៉ាវដ៏ជាទីអាថ៌កំបាំងនេះ ដោយធ្វើទឹកមុខញញឹមៗ ។ មិត្តឆ្លើយកំប្លែងលេងជាមួយម្តាយវិញថា «ចុះឥឡូវ ម៉ែឃើញកូនរស់ហើយតើ ម្តេចក៏ម៉ែនៅគិតព្រួយសង្ស័យអីទៀត?»

អុំ យឹម ឆ្លើយតបកូនវិញដោយទឹកមុខស្រងូតស្រងាត់ «អើ! ម៉ែបានជួបមុខកូន ម៉ែឃើញច្បាស់ថាកូនរស់ ម៉ែសប្បាយរីករាយដូចកើតម្តងទៀត! តែពេលឃើញកូនម៉ែក៏នឹកព្រួចទៅដល់យុវជនកម្សត់នោះ ដែលធ្វើបដិវត្តន៍ដូចកូនដែរ ប៉ុកពារ សំដីសំដៅដូចកូនដែរ តែឥឡូវមិនដឹងជាគ្នាស្លាប់ឬរស់?»

ឃើញម្តាយស្រងូតស្រងាតដូច្នោះ មិត្តភិន ក៏នាំម្តាយនិយាយពីនេះពីនោះឲ្យសប្បាយរីករាយវិញ ។ រួចហើយមិត្តក៏និយាយជំណាលអំពីជីវិតតស៊ូរបស់មិត្ត ក្នុងរយៈពេល១០ឆ្នាំកន្លងទៅដោយត្រួសៗ

## លះបង់អ្វីៗទាំងអស់ ដើម្បីបដិវត្តន៍

«តើម៉ែចាំទេ កាលនៅពាក់កណ្តាលឆ្នាំ១៩៦៦ កូនបានសុំលុយម៉ែ២០០រៀល ថាទៅកាត់ខោអាវនៅឯភ្នំពេញ ។ តែតាមពិតកូនមានភារកិច្ចបដិវត្តន៍មួយដែលត្រូវបំពេញ គឺកូនត្រូវដឹកឯកសារសម្ងាត់ពីភ្នំពេញទៅខាងមូលដ្ឋានជនបទក្នុងខេត្តបាត់ដំបង ។ ពេលនោះ កូនជិះឡានពីភ្នំពេញទៅបាត់ដំបងដោយបង្កប់ឯកសារសម្ងាត់នៅបាតកន្ត្រកមៀន ។ ពេលជិះឡានទៅដល់សាលាលេខ៥ ពួកគយនិងពួកប៉េអឹម៨-១០នាក់ ឃាត់ហៅឡានឈ្នួលឈប់ ហើយធ្វើការរុករើ ឆែកឆេរអីវ៉ែអីវ៉ាន់នៅក្នុងឡានទាំងអស់ យ៉ាងតឹងរ៉ឹងបំផុត ។ ពេលនោះ ពួកវាយកចិត្តទុកដាក់ឆែកឆេរជាងគេទៅលើយុវជនដែលធ្វើដំណើរទៅមកឆ្លងខេត្ត ព្រោះកាលសម័យនោះ ចលនាតស៊ូរបស់យុវជនយើង ក្រោមការដឹកនាំ និងបំផុសរបស់បក្សកុម្មុយនីស្តកម្ពុជា មានសន្ទុះផុសផុលខ្លាំងក្លា បោកគ្រាំគ្រេងទៅលើចក្រពត្តិអាមេរិក បរិវារ និងពួកអាក្បត់ជាតិដែលកាន់អំណាចនៅក្នុងប្រទេស ។ ចលនាតស៊ូរបស់យុវជន បានបោកបក់ខ្លាំងក្លានៅក្នុងទីក្រុងភ្នំពេញ ក្នុងរយៈពេលបីឆ្នាំជាប់ជាបន្តបន្ទាប់មកហើយ ហើយក្រោយមកចលនាតស៊ូនេះ ក៏បានរាលដាលឆ្លងទៅខេត្តនានាផ្សេងទៀត» ។

ពេលចាប់ផ្តើមឆែកឆេរឡានភ្លាម ខ្មាំងបានប្រមូលកាតអ្នកជិះលើឡាន យកទៅពិនិត្យទាំងអស់ ហើយទាល់តែវាឆែកឆេររួចបើគ្មានរឿងរ៉ាវអ្វីទេ ទើបវាប្រគល់កាត់នោះមកឲ្យវិញ ។ តែថ្ងៃនោះ អាប៉េអឹមម្នាក់ បានទៅរើក្រឡាប់ចាក់កន្ត្រកមៀនកូន ។ ខិតប័ណ្ណសម្ងាត់ដែលនៅក្រោមកន្ត្រកមៀន ក៏ធ្លាក់ចេញមកក្រៅ ។ ពួកវាក៏ផ្អើលឆោឡោរើសយកខិតប័ណ្ណសម្ងាត់នេះ មកពិនិត្យមើលភ្លាម» ។ គ្រាន់តែឃើញហេតុការណ៍មិនស្រួលភ្លាម កូនក៏គេចខ្លួនបាត់មួយរំពេច មិនបណ្តោយឲ្យខ្មាំងចាប់បានឡើយ ។ កូនស្រាតខោអាវចោលឈ្នោលយកញុកក្នុងចេតិយវត្តមួយនៅជិតនោះ ។ កូនដកយកតែលុយ២០០រៀល ដែលម៉ែឲ្យទៅពីផ្ទះទុកតែខោខ្លីមួយ ហើយយកក្រមារស្លៀករុំពីលើខ្លួនទទេ បន្លំធ្វើដូចជាបងប្អូនកសិករយើងនៅម្តុំនោះ រួចហើយកូនដើរកាត់ព្រៃតម្រង់មកខាងឃុំពាម ដែលជាមូលដ្ឋានបដិវត្តន៍ចាស់ ដើម្បីរកខ្សែទាក់ទងជម្រាបទៅខាងអង្គការនៅ

ក្រុងភ្នំពេញវិញ ។ មួយយប់មួយថ្ងៃទើបកូនដើរមកដល់ឃុំពាម ហើយក៏បានរកទាក់ទងខ្មែរសម្ងាត់បដិវត្តន៍ឃើញដូចប្រាថ្នា ។ ពេលនោះ អង្គការមតិថា រូបកូនត្រូវបែកហើយ ពុំអាចត្រឡប់ទៅផ្ទះវិញបាន ហើយក៏ពុំអាចនៅធ្វើសកម្មភាពចំហក្នុងទីក្រុងភ្នំពេញនេះ និងម្តុំខាងជើង និងពាយ័ព្យភ្នំពេញបានទៀតឡើយ ។ ក្រោយពីរស់នៅសម្ងាត់តែក្នុងផ្ទះអស់រយៈមួយអាទិត្យ បក្សក៏បានសម្រេចឲ្យកូនទៅជួយការងារនៅឯខាងភូមិភាគបូព៌ា ក្នុងខេត្តកំពង់ចាមវិញ ព្រោះទៅខាងនោះ វាឆ្ងាយពីទឹកន្លែងបែក ហើយក៏គ្មានអ្នកណាស្គាល់កូនផង ។

ក្រោយមក កូនក៏បានមករស់នៅជាមួយគ្រួសារកសិករក្រមួយ ក្នុងស្រុកមេមត់ខេត្តកំពង់ចាម ដោយលើកពាក្យស្មោកថា ជាប្អូនធម៌របស់បងម្ចាស់ផ្ទះ ។ ទាំងបងម្ចាស់ផ្ទះ ទាំងប្រជាជនយើងនៅម្តុំនោះទាំងអស់គ្នា ដឹងស្គាល់រូបខ្ញុំត្រឹមតែថា ជាកូនកំព្រីកំព្រាគ្មានឪពុកម្តាយ គ្មានបងប្អូនទេ ។ ដោយធ្លាប់ទៅមករកស៊ីស្គាល់គ្នានៅផ្សារសួង រូបខ្ញុំ និងបងម្ចាស់ផ្ទះនោះ ក៏សុំគ្នាធ្វើជាបងធម៌ប្អូនធម៌ទៅ ។ ដោយរបររកស៊ីនៅផ្សារសួងវាកាន់តែតឹងតែងលំបាកពេក ខ្ញុំក៏ទៅរស់នៅជាមួយបងធម៌ឯមេមត់ដើម្បីជួយធ្វើស្រែចម្ការ និងរកស៊ីធាក់រ៉ឺម៉កផង ។ តែតាមការពិត ផ្ទះបងធម៌ខ្ញុំនេះ ជាដំណាក់និរសារបដិវត្តន៍ ហើយរូបខ្ញុំនេះ មានភារៈជានិរសារសម្រាប់នាំសំបុត្រស្នាម ឬឯកសារផ្សេង និងជូនផ្លូវកម្មាភិបាលយើងដើរហើរឆ្លងកាត់តំបន់ខ្មាំងទៅធ្វើការពីមូលដ្ឋានមួយទៅមូលដ្ឋានមួយទៀត ។ កូនបានបំពេញភារកិច្ចបដិវត្តន៍នេះ សម្រេចជោគជ័យជាបន្តបន្ទាប់ ពុំដែលមានរឿងហេតុ ឬបែកការសម្ងាត់អ្វីឡើយ» ។

រហូតមកដល់ឆ្នាំ១៩៦៨ សភាពការណ៍មានការតឹងតែងជាខ្លាំង មិត្តយើងមួយចំនួនធំដែលបែក ឬដែលខ្មាំងសង្ស័យបាននាំគ្នារត់ចូលព្រៃធ្វើការតស៊ូអាវុធ ។ ចំណែកកូនដែលមិនទាន់បែកបក្សបានសម្រេចឲ្យនៅភូមិដដែល ដោយបន្តភារកិច្ចធ្វើជាស្ពានតភ្ជាប់មូលដ្ឋានទីប្រជុំជនផ្សារនានា ទៅនឹងការដឹកនាំនៅក្នុងព្រៃ ។ ពេលនោះ ខ្មាំងធ្វើការបង្ក្រាបរាតត្បាតជាខ្លាំង នៅគ្រប់ច្រកល្ហកទាំងអស់ ទាំងនៅទីប្រជុំជនផ្សារ ក៏ដូចនៅទីជនបទចុងកាត់មាត់ញកដែរ ។ ខ្មាំងបានអនុវត្តនយោបាយហ្វាស៊ីសភាវូបនីយកម្ម នៅតាមមូលដ្ឋានបដិវត្តន៍ចាស់ៗនានា ដោយចាប់ខ្មែរ សម្លាប់ខ្មែរ ដុតខ្មែរ បំផ្លាញខ្ទេច ។ ពេលនោះ មិនចាំបាច់មានភ័ស្តុតាងអ្វីទេ គ្រាន់តែវាសង្ស័យក៏វាចាប់ដែរ ។ ខ្មាំងវានិយាយថា សុខចិត្តចាប់ខុស១០០ កុំឲ្យតែរួចពួកអា "ខ្មែរក្រហមម្នាក់" ។

កូនបន្តបំពេញភារកិច្ចជាស្ពានបដិវត្តន៍នេះ បានជាប់រហូតដល់ពាក់កណ្តាលឆ្នាំ១៩៦៨ ។ ថ្ងៃមួយ កូនកំពុងតែធាក់រ៉ឺម៉កទទេត្រឡប់មកពីផ្សារមេមត់វិញ ដើម្បីមកផ្ទះហូបបាយ ក៏ស្រាប់តែពួកអាទាហានស្ទាក់ចាប់កណ្តាលផ្លូវ ដោយគ្មានបានដឹងរឿងហេតុ ឬមានហេតុភេទអ្វីជាមុនឡើយ ។ វាឆែកឆេរ រុករើលើខ្លួនប្រាណកូន ក៏ពុំឃើញមានភ័ស្តុតាងអ្វី រុះរើក្នុងរ៉ឺម៉កកូន ក៏ពុំឃើញអ្វី ។ តែខ្មាំងនៅតែចាប់កូនយកទៅបន្ទាយវា ។ វាចោទប្រកាន់កូនថា ជាភ្នាក់ងារ "ខ្មែរក្រហម" ជាអ្នកដឹកជញ្ជូនស្បៀងផ្តល់ឲ្យពួក "ខ្មែរក្រហម" នៅក្នុងព្រៃ កូនបានបដិសេធពាក្យចោទប្រកាន់ទាំងអស់នេះរបស់ខ្មាំងដាច់អហង្ការ ព្រោះកូនដឹងច្បាស់ថា ខ្មាំងចាប់នេះ ដោយគ្រាន់តែសង្ស័យទេ ហើយម្យ៉ាងទៀត ខ្មាំងគ្មានភ័ស្តុតាងអ្វីទាំងអស់ដើម្បីចោទប្រកាន់កូន ក៏ដូចក្នុងការចាប់រូបកូនដែរ ។

## បិតនៅចំពោះមុខទបាយកលខ្មាំង

ក្រោយមក ខ្មាំងបានបញ្ជូនរូបកូនមកក្រុងកំពង់ចាម ។ នៅទីនេះ ទោះបីខ្មាំងសម្លុត គំរាម ធ្វើទារុណកម្មលើរាងកាយយ៉ាងណាក៏កូននៅតែឆ្លើយបដិសេធ ដូចតែកាលនៅមេមត់ដែរ ។ ដោយទាល់ចំណេះ សួរមិនបានការអី ហើយរកភ័ស្តុតាងអីក៏ពុំឃើញ ខ្មាំងក៏រៀបចំសំណុំលិខិត និងថតរូបបញ្ជូនមកភ្នំពេញ ប្រុងនឹងដោះលែងរូបកូនទៅវិញ ។ វាក៏បាននិយាយប្រាប់កូនថា ប្រហែលមួយអាទិត្យទៀត នឹងត្រូវរួចខ្លួនហើយ ។ ស្រាប់តែបួនថ្ងៃក្រោយមក កូនកំពុងតែដើរលេងនៅក្នុងទីធ្លាគុក អាគិញម្នាក់ដើរតម្រង់មករកកូន ហើយយកកាតដែលបិទរូបថតខ្ញុំនោះ មកសួរកូនថា «តើអាឯងស្គាល់ទេ កាតនេះជារបស់អាឯងឬ?» គ្រាន់តែក្រឡេកឃើញកាតនោះភ្លាមកូនភ្ញាក់ព្រើត ហើយស្គាល់ច្បាស់ថា ជាកាតរបស់កូន ដែលខ្មាំងយកនៅសាលាលេខ៥ កាលពីឆ្នាំ១៩៦៦ ។ តែរំពេចភ្លាមនោះ កូននឹកឃើញថា ខ្មាំងវាគ្រាន់តែសង្ស័យទេ វាគ្មានភ័ស្តុតាងអី នឹងសង្កត់កូនឲ្យទទួលថារូបនោះជារូបកូនឡើយ ។ ដូច្នោះ កូនក៏ឆ្លើយបដិសេធវិញភ្លាមថា មិនមែនទេ មិនស្គាល់ទេ ខ្ញុំជាអ្នកស្រុកទន្លេបិទ ហើយកំព្រាឪពុកម្តាយតាំងពីតូចៗមក ។

តែស្អែកឡើង ខ្មាំងបានចាប់បញ្ជូនរូបកូនមកក្រុងភ្នំពេញទៀត ។ មកដល់កន្លែងគិញពិសេសក្រុងភ្នំពេញ ខ្មាំងបានធ្វើទារុណកម្មមកលើរាងកាយកូនយ៉ាងព្រៃផ្សៃ ហួស៊ីសបំផុត អស់រយៈបីយប់បីថ្ងៃជាប់ គាបបង្ខំឲ្យរូបកូនទទួលសារភាពថា កាតនេះជាកាតរបស់កូនមែន ។ តែទោះបីយ៉ាងណា កូននៅតែឆ្លើយបដិសេធជាប់រហូតដូចដើម ។

ស្រាប់តែថ្ងៃទីបួន ឃើញខ្មាំងនាំម៉ែចូលមកក្នុងបន្ទប់ឃុំឃាំងកូន ។ កូនភ្ញាក់ព្រើត! តាមមនោសញ្ចេតនាស្រឡាញ់ទឹករពុកម្តាយ កូនស្ទើរស្ទុះមកឱបរឹតម្តាយភ្លាម ។ តែរំពេចភ្លាមនោះ កូននឹកឃើញដល់ខបាយកលខ្មាំង ។ កូនយល់ច្បាស់ថា ខ្មាំងធ្វើនេះ គឺដើម្បីផ្ចាញ់ផ្ចាលកូន និងដើម្បីចាប់ភ័ស្តុតាងឲ្យបានពិតប្រាកដ ហើយបើកូនស្គាល់ម៉ែមែននោះ ខ្មាំងនឹងបានភ័ស្តុតាងពិតប្រាកដថារូបកូននេះជាជនបដិវត្តន៍មែន ។ ដូច្នេះ រូបកូនក៏នឹងត្រូវវាកម្ទេច ហើយខ្សែទាក់ទងជាមួយកូន នៅឯមេមត់ទាំងអស់ ក៏នឹងត្រូវខ្មាំងកម្ទេច ។ ដូច្នេះ នឹងមានការអន្តរាយខូចខាតច្រើនដល់បដិវត្តន៍យើង ។ គិតឃើញដល់រឿងនេះ កូនក៏ខំទប់ចិត្តភ្លាមមិនឲ្យរំភើបញាប់ញ័រនៅចំពោះមុខទឹកភ្នែកម្តាយ ឬពាក្យអង្វររបស់ម្តាយឡើយ ។ កូនឆ្លើយបដិសេធដាច់អហង្ការ មិនព្រមទទួលស្គាល់ម្តាយ ហើយក៏មិនព្រមនិយាយស្តីរកម្តាយទៀត» ។

ដល់ត្រឹមនេះ មិត្តសម្លឹងមើលមុខម្តាយ ហើយនិយាយក្រម៉ាចលេងជាមួយម្តាយថា «កូននេះហើយ ដែលជាយុវជនកម្សត់របស់ម៉ែកាលណោះ!» ។

អ៊ំយឹម ក៏ស្ទុះមកចាប់ដៃកូនទាំងរលីងរលោងទឹកភ្នែក ហាក់បីដូចជាស្ថិតនៅចំពោះមុខព្រឹត្តិការណ៍កាលពីឆ្នាំ១៩៦៨ ហើយក៏បានបន្លឺវាចាដោយរំភើបញាប់ញ័រ នឹងគ្រេកអរក្រៃលែងថា «ឱ! កូននេះហើយ! កូនម្តាយមែនឬ! កូនបានរស់វិញហើយ! ម្តាយមិនស្មានថាកូននៅរស់ទេ! ម្តាយគ្មានសង្ឃឹមថាបានជួបមុខកូនវិញទេ ! ចុះរឿងរ៉ាវតមកទៀត វាយ៉ាងម៉េចខ្លះ? »

មិត្តភិន ក៏ចាប់ផ្តើមនិយាយបន្តទៀត «ក្រោយពេលដែលម៉ែចេញផុតពីបន្ទប់ឃុំឃាំងកូន ខ្មាំងក៏បានមកចាប់កូន យកទៅវាយសួរចម្លើយសាជាថ្មីទៀត» តែកូននៅតែឆ្លើយបដិសេធដូចពេលមុនៗទៀត ។ ខ្មាំងចាញ់ចំណេះ ទាល់គំនិត ហើយដោយរកគ្មានឃើញភ័ស្តុតាងអ្វីទាំងអស់ វាក៏បញ្ជូនកូនទៅឃុំទុកនៅគុកព្រៃស ។ ចុងឆ្នាំ១៩៦៩ ខ្មាំងក៏បានដោះលែងកូនពីគុកព្រៃសមកវិញ ដើម្បីពិនិត្យតាមដានសកម្មភាពកូន និងតាមស្រាវជ្រាវរាវរកខ្សែសម្ងាត់ផ្សេងទៀត ដែលមកទាក់ទងជាមួយកូន» ។

គ្រាន់តែបានចេញផុតពីគុកព្រៃសភ្លាម ខ្សែអង្គការបក្សក្នុងទីក្រុងភ្នំពេញ ក៏បានមកទាក់ទងនាំយករូបកូន បញ្ជូនឲ្យទៅនៅធ្វើការឯមូលដ្ឋានក្នុងព្រៃពាយ័ព្យទិសភ្លាម ហើយតាំងពីពេលនោះ រហូតមកដល់សព្វថ្ងៃនេះ កូនក៏បានចូលបម្រើកងទ័ពបដិវត្តន៍យើង រួមធ្វើការប្រយុទ្ធវាយកម្ទេចខ្មាំង ជាប់រហូតដល់ពេលរំដោះមាតុប្រទេសកម្ពុជាជាទីស្នេហារបស់យើងរាល់គ្នា បានទាំងស្រុង» ។

មកដល់ត្រឹមនេះ ប្រជាជនយើង ដែលបានអង្គុយស្តាប់រឿងរ៉ាវនេះ តាំងពីដើមដល់ចប់ ក៏បាននិយាយដោយក្តីក្រេវក្រោធថា «អាខ្មាំងវាបានជិះជាន់សង្កត់សង្កិន ធ្វើបាប កាប់សម្លាប់បងប្អូនឈាមកសិករយើងអស់ច្រើនណាស់ ធ្វើឲ្យយើងរស់នៅរងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា និរាសព្រាត់ប្រាសគ្រួសារ រត់ចោលស្រុកចោលភូមិ ចោលផ្ទះសម្បែង គ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា ។ រឿងរ៉ាវទាំងនេះ យើងត្រូវចងចាំជារៀងរហូត ហើយតទៅអនាគតទៀត ក៏ត្រូវអប់រំកូនចៅយើង ឲ្យចងគំនុំចំពោះខ្មាំងសត្រូវតពូជតពង្សទៅទៀត ។ ឥឡូវដោយសារគុណបក្ស គុណបដិវត្តន៍កម្ពុជា ស្រុកយើងមានសុខសន្តិភាពឡើងវិញហើយ ក្មួយក៏បានមកជុំ និងគ្រួសារញាតិមិត្តជិតឆ្ងាយទាំងអស់គ្នាវិញហើយ កសិករក្រីក្រយើង ក៏បានវិលត្រឡប់មកស្រុកភូមិកំណើតខ្លួនវិញ រស់នៅធ្វើការងាររកស៊ី ដោយសុខសាន្ត មានកិត្តិយសថ្លៃថ្នូរុងរឿង ក្នុងឋានៈខ្លួនជាម្ចាស់ប្រទេស ម្ចាស់ទឹកដី និងម្ចាស់ភូមិករ ស្រែចម្ការរបស់ខ្លួនយ៉ាងពិតប្រាកដ ។ យើងទាំងអស់គ្នា ត្រូវតែប្តេជ្ញាចិត្តធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងអស់ជាបន្តទៀតដើម្បីការពារប្រទេសជាតិយើង ការពាររដ្ឋអំណាចបដិវត្តន៍យើងសព្វថ្ងៃនេះ ឲ្យបានស្ថិតស្ថេរគង់វង្ស និងកាន់តែរឹងប៉ឹងឡើងជារៀងរហូតទៅ ។ សហករណ៍យើង ប្តេជ្ញានឹងខិតខំវាយសម្រុកធ្វើស្រែឲ្យបានផលស្រូវច្រើនខ្ពស់បំផុត ដើម្បីរួមចំណែកជាមួយក្មួយៗកងទ័ព និងបងប្អូនកម្មករ កសិករយើងទូទាំងប្រទេសកសាងកម្ពុជាថ្មី ឲ្យបានខ្លាំងក្លា សម្បូរសប្បាយ និងថ្កុំថ្កើន រុងរឿងយ៉ាងឆាប់រហ័សបំផុត ។ **ឆេង ម៉េង**

# «បើរស់យើងនឹងត្រឡប់មកស្រុកកំណើតវិញ»



សុត វណ្ណា រៀបរាប់អំពីប្រវត្តិរបស់គាត់ក្នុងអំឡុងរបបខ្មែរក្រហម នៅសាលាគរុកោសល្យភូមិ និងវិក្រឹតការ ខេត្តកណ្តាល ដែលគាត់កំពុងធ្វើការ ។

ខាងក្រោមនេះគឺជាសាច់រឿងរបស់ សុត វណ្ណា មានអាយុ ៦២ឆ្នាំ ដែលជាបុគ្គលិកជាប់កិច្ចសន្យារបស់ក្រសួងអប់រំយុវជន និងកីឡា ធ្វើការនៅសាលាគរុកោសល្យភូមិ និងវិក្រឹតការខេត្តកណ្តាលរយៈពេលជាង២៣ឆ្នាំមកហើយ ។ រៀងរាល់ថ្ងៃ គាត់ធ្វើការងារខាងអនាម័យ ថែទាំបន្ទប់រៀន សម្អាតទីធ្លាសាលា ស្រោចផ្កា រៀបចំឧបករណ៍សម្រាប់ពេលប្រជុំ និងការងារផ្សេងៗទៀតទៅតាមការចាត់តាំងរបស់នាយកសាលា ។ ខ្ញុំបានទៅជួបគាត់ដោយចៃដន្យ នៅពេលដែលគាត់កំពុងអង្គុយលើថ្មសួនច្បាររង់ចាំរៀបចំអាហារសម្រន់សម្រាប់លោកគ្រូ-អ្នកគ្រូចំនួន១០០នាក់ ដែលមកចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-៧៩" ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វណ្ណា ជាមនុស្សស្ងប់ស្ងាត់ ដូច្នេះហើយទើបមិនសូវមានអ្នកចាប់អារម្មណ៍មកជជែក ឬសាកសួរពីប្រវត្តិរបស់គាត់ ។ ប៉ុន្តែ នៅពេលដែលខ្ញុំលើកឡើង និងសួរនាំគាត់ពីរបបខ្មែរក្រហម ទើបគាត់រៀបរាប់ប្រាប់ខ្ញុំថា គាត់ស្រុកកំណើតនៅភូមិប្រគាត ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ។ កាលពីសង្គមរាស្ត្រនិយម ឪពុកគាត់ (ដួង សុត) គឺជាគ្រូបង្រៀននៅសាលាពហុបច្ចេកទេស (តិចណូ) និង សាលាដែក នៅខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ចំណែកម្តាយរបស់គាត់ជាមេផ្ទះ ។ គ្រួសាររបស់ វណ្ណា ដែលមានសមាជិក៩នាក់ រួមទាំងឪពុកម្តាយបានផ្លាស់មករស់នៅផ្ទះនៅម្តុំបឹងត្របែក ក្រុងភ្នំពេញ តាំងពី វណ្ណា នៅតូចម៉្លេះ ។ បន្ទាប់មក បងស្រីបង្កើតរបស់ វណ្ណា ដែលមានប្តីធ្វើជាប៉ូលីស បានយក វណ្ណា ទៅរស់នៅជាមួយ និងឲ្យគាត់ជួយមើលថែទាំក្មួយ (កូនបងស្រីរបស់ វណ្ណា) នៅម្តុំពោធិ៍ចិនតុង ។ តែពេលនោះដោយបារម្ភខ្លាច វណ្ណា ដែលទើបមានអាយុ១១ឆ្នាំ មិនបានរៀនសូត្រ ទើបឪពុករបស់ វណ្ណា ទៅយក វណ្ណា មករស់នៅជាមួយវិញ រួចចុះឈ្មោះ វណ្ណា ឲ្យចូលរៀននៅសាលាឯកជនពុតឆាយ ។

នៅឆ្នាំ១៩៧៤ នៅពេល វណ្ណា មានអាយុ១៥ឆ្នាំ ឪពុកម្តាយរបស់គាត់រៀបចំឲ្យគាត់មានប្តីដែលធ្វើជាទាហាននៅបន្ទាយម្តុំផ្សារស៊ីលិប ផ្នែកអូរដេ (បើកប្រាក់ខែ) ឲ្យបុគ្គលិកក្នុងសម័យសាធារណរដ្ឋខ្មែរ ។ នៅពេលសង្គ្រាមផុះឡើងកាន់តែខ្លាំងមានទាហានលន់នល់កាន់តែច្រើនបានមកសុំប្តីរបស់ វណ្ណា ដើម្បីរក្សាឈ្មោះទុកដោយមិនទៅបំពេញភារកិច្ច ដោយប្រគល់ប្រាក់ខែរបស់គេមកឲ្យប្តីគាត់ និងមួយចំនួនទៀតបានយកថ្នាំពេទ្យ ដូចជា ថ្នាំប៉េនីស៊ីលីន (ឬហៅថា ត្រីបតូ) មកជូនប្តីរបស់គាត់ថែមទៀតផង ។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលមកបណ្តេញក្រុមគ្រួសាររបស់ វណ្ណា ចេញពីផ្ទះ ។ វណ្ណា និងក្រុមគ្រួសារទាំងមូលបានធ្វើដំណើររយៈពេលបីថ្ងៃ តែឆ្លងមិនផុតពីក្បាលថ្នល់ ទើបនាំគ្នាត្រឡប់មកផ្ទះវិញ ។ សម័យនោះ ឪពុកម្តាយរបស់ វណ្ណា បានចិញ្ចឹមជ្រូក និងមាន់ទាជាច្រើន ប៉ុន្តែមិនដែលសម្លាប់សត្វទាំងនេះទេ ព្រោះគាត់ទាំងពីរនាក់ជាអ្នកកាន់សីល៍ ។ ឃើញដូច្នេះ បងៗរបស់ វណ្ណា បានសុំឪពុករបស់គាត់ធ្វើជ្រូកមាន់ទាទាំងនោះ ដើម្បីប្រឡាក់ និងធ្វើផ្អកទុកជាស្បៀងហូបតាមផ្លូវ ។ បន្ទាប់ពីធ្វើរួច យោធាខ្មែរក្រហមបានចូលមកគំរាម និងបណ្តេញគ្រួសារ វណ្ណា ឲ្យចេញពីផ្ទះជាលើកទីពីរ ។ ពេលនោះ វណ្ណា និងប្តី មិនបានយករបស់របរជាប់នឹងខ្លួនច្រើនទេ គឺយកបានតែថ្នាំពេទ្យដែលទាហានលន់នល់យកមកឲ្យ ដាក់នៅតាមខ្លួនប៉ុណ្ណោះ ។ ក្រុមគ្រួសារ

របស់ វណ្ណា បានធ្វើដំណើរឆ្លងស្ពានព្រះមុនីវង្ស និងទៅស្នាក់នៅស្រុកកៀនស្វាយអស់រយៈពេលជាច្រើនខែ ទើបនាំគ្នាធ្វើដំណើរប្រេបតាមមាត់ទន្លេបាសាក់ រួចហើយក៏ឆ្លងទៅស្រុកកំណើតនៅឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវវិញ ។

ក្រុមគ្រួសារ វណ្ណា បានទៅស្នាក់នៅផ្ទះនៅភូមិចាស់ គឺភូមិប្រគាតរបស់យាយតាគាត់ ។ ដោយសារសមាជិកគ្រួសារច្រើន ឪពុករបស់ វណ្ណា បានដើររកឈើ និងស្លឹកមកសាងសង់បន្ថែមផ្ទះចាស់ដើម្បីស្នាក់នៅបណ្តោះអាសន្ន ។ នៅពេលទៅដល់ដំបូងគ្រួសារ វណ្ណា មិនមានការលំបាកខ្លាំងទេ ព្រោះគាត់មានសាច់ញាតិជាអ្នកមូលដ្ឋាន ហើយពូរបស់គាត់ម្នាក់ឈ្មោះ ទុយ ជាប្រធានសហករណ៍ឃុំចំប៉ី ។ ម្យ៉ាងទៀត វណ្ណា បានយកថ្នាំប៉េនីស៊ីលីន (ត្រីបតូ) របស់គាត់ទៅដោះដូរអង្ករជាមួយអ្នកមូលដ្ឋានយកមកដាំហូប ដោយថ្នាំត្រីបតូមួយដបដូរបានអង្ករចំនួនដប់ពីរកំប៉ុង ។

ក្រោយមក ខ្មែរក្រហមបានបំបែក វណ្ណា និងប្តីរបស់គាត់ពីឪពុកម្តាយឲ្យទៅរស់នៅក្នុងវត្តមួយដែលមានចម្ងាយប្រមាណបីគីឡូម៉ែត្រពីភូមិប្រគាត ព្រោះប្តីគាត់ជាអតីតទាហាន លន់ នល់ ។ ក្រៅពីប្តីរបស់ វណ្ណា ខ្មែរក្រហមក៏បានប្រមូលអ្នកដែលមានប្រវត្តិរូបជាប៉ូលីស និងទាហានមកស្នាក់នៅវត្តនេះដែរ ។ នៅទីនោះ វណ្ណា និង ប្តី ត្រូវអង្គការបែងចែកដីឲ្យធ្វើស្រែ និងមានប្រធានកងម្នាក់ឈ្មោះ បាវ អ្នកមើលការខុសត្រូវ ។ បាវ គឺជាមិត្តភក្តិរបស់ វណ្ណា និងធ្លាប់រស់នៅភ្នំពេញដូច វណ្ណា ដែរ តែ បាវ បានត្រឡប់មកភូមិ និងបានចូលចលនាបដិវត្តន៍ខ្មែរក្រហមតាំងពីមុនរំដោះឆ្នាំ១៩៧៥ ម្ល៉េះ ។ នៅពេលនោះ ពូរបស់ វណ្ណា ឈ្មោះ ទុយ ប្រធានសហករណ៍ឃុំប៉ី ក៏ខស្សព្រាហ៍មកសួរសុខទុក្ខ វណ្ណា ដែរ ហើយតែងតែផ្តែផ្តាំ បាវ ឲ្យជួយមើលការខុសត្រូវ និងយកអាសារ វណ្ណា ទៀតផង ។

នៅក្នុងអំឡុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានមកកត់ឈ្មោះប្រជាជនថ្មី (ប្រជាជន ១៧ មេសា) ដើម្បីរៀបចំជម្លៀសឲ្យទៅរស់នៅខេត្តផ្សេង ។ ពូដូច្នេះ វណ្ណា និងប្តីរបស់គាត់ក៏ទៅចុះឈ្មោះ



សាលាគរុកោសល្យ និងវិក្រិត្យការភូមិភាគ ខេត្តកណ្តាល ដែល វណ្ណា កំពុងធ្វើការ និងស្នាក់នៅជាមួយកូនរបស់កូនគាត់ចំនួន៣នាក់

ដែរ ដោយមានប្រធានកងឈ្មោះ បាវ ជាអ្នករៀបចំ ប៉ុន្តែត្រូវពូរបស់គាត់ឈ្មោះ ទុយ មកទាន់ ហើយ ប្រាប់ វណ្ណា និងប្តីឲ្យត្រឡប់មកផ្ទះវិញ ។ ពូរបស់ វណ្ណា បានផ្តែផ្តាំ វណ្ណា និងប្តី ឲ្យខិតខំធ្វើការទៅតាមការចាត់តាំង និងបានប្រាប់ប្រធានកងឈ្មោះ បាវ ថា គាត់ទាំងពីរនាក់នេះ (វណ្ណា និងប្តី) មិនមានឈ្មោះដើម្បីជម្លៀសចេញពីភូមិនេះទេ (ព្រោះប្រហែលជាពូគាត់ដឹងមុនថា អ្នកដែលអង្គការជម្លៀសចេញទាំងអស់គឺជាមុខសញ្ញារបស់អង្គការយកទៅលត់ដំ) ។

មួយរយៈក្រោយមក ដោយសាររបស់ប្តី វណ្ណា ខ្លាចអង្គការតាមដាន និងសម្លាប់ ទើបពិភាក្សាជាមួយ វណ្ណា ដើម្បីរៀបចំគម្រោងគេចចេញពីភូមិ ។ ប្តីរបស់ វណ្ណា បាននិយាយប្រាប់ វណ្ណា ថា «បើយើងគង់នឹងស្លាប់ដូច្នេះយើងត្រូវតែចេញ ហើយបើខ្ញុំនៅរស់ ប្អូនឯង (វណ្ណា) នៅរស់ត្រូវត្រឡប់មកផ្ទះវិញ ព្រោះជាភូមិកំណើតរបស់យើង» ។ គាត់ទាំងពីរនាក់បានលួចឡើងជិះរថយន្តយោធាខ្មែរក្រហមដែលមកដឹកប្រជាជនពីក្នុងភូមិជាលើកទីពីរ ដោយក្រាបក្នុងឃ្លុបរថយន្តខាងក្រោយ ដើម្បីបាំងកុំឲ្យពូរបស់គាត់ និងប្រធានកងឈ្មោះ បាវ មើលឃើញ ។

វណ្ណា បានជិះរថយន្តយោធាខ្មែរក្រហមទៅឈប់នៅខេត្តពោធិ៍សាត់ ។ នៅទីនោះ វណ្ណា បានជួបជុំគ្រួសារអ៊ំស្រីរបស់គាត់មួយគ្រួសារ និងគ្រួសារបងថ្លៃ ។ រយៈពេលបីថ្ងៃក្រោយមក ទើប វណ្ណា និងបងប្អូនរបស់គាត់ឡើងជិះរថភ្លើងបន្តទៅខេត្តបាត់ដំបង ។ វណ្ណា បានបែកពីគ្រួសារអ៊ំស្រី និងបងថ្លៃ នៅពេលរថភ្លើងទៅឈប់នៅស្រុកមោងឫស្សី ។ ខ្មែរក្រហមបានបែងចែកឲ្យ វណ្ណា និងប្តី ទៅរស់នៅសហករណ៍ឃុំសែ ។ រយៈពេលមួយខែដំបូង វណ្ណា និងប្តីរបស់គាត់មានអាហារហូបគ្រប់គ្រាន់ ព្រោះនៅក្នុងភូមិសម្បូរត្រី ផ្លែក្រូច និងផ្លែឈើជាច្រើនមុខទៀត ហើយប្រជាជនអាចបេះហូបបាន ។

ក្រោយមក វណ្ណា បានជួបបងប្អូនជីដូនមួយរបស់គាត់ម្នាក់ឈ្មោះ ផុន ធ្វើជាទាហាន (រួមជាមួយកូនប្រុសរបស់គាត់ម្នាក់) ដែលទៅតាមរកប្រពន្ធដែលបែកគ្នាពេលជម្លៀស និងបានមករស់នៅផ្ទះជាមួយ វណ្ណា ដោយគ្រាន់តែយកបន្ទះសង្កសីមកខណ្ឌប៉ុណ្ណោះ ។ គ្រួសាររបស់ វណ្ណា បានទទួលរបបអង្ករពីអង្គការទៅតាមចំនួនសមាជិកក្នុងគ្រួសារ ។ មួយរយៈក្រោយមក ទើបអង្គការបែងចែកប្រជាជនឲ្យចុះទៅធ្វើការ និងឲ្យទៅហូបបាយនៅរោងបាយរួម ហើយនៅពេលខ្វះខាតខ្លាំង ប្រធានកងឲ្យប្រជាជនចេញដើររកអាហារហូបដោយខ្លួនឯង ។ ប៉ុន្តែមិនមាននរណាម្នាក់រកអាហារបានហូបទេ ព្រោះក្នុងភូមិលែងមានត្រីសាច់ និងផ្លែឈើសេសសល់ដូចកាលមកដល់ពីដំបូងទៀតហើយ ។ នៅពេលនោះ វណ្ណា ធ្វើការនៅកងនារីដកស្ទូង ចំណែកប្តីគាត់ធ្វើការនៅក្នុងកងលើកទំនប់ប្រឡាយ ។ ក្រោយពីធ្វើការរួច ប្តី វណ្ណា បានទៅរែកទឹកយកមកប្រើប្រាស់ក្នុងផ្ទះ ស្រាប់តែគាត់ដួលបណ្តាលឲ្យគ្រេចដៃ និងហើមយ៉ាងធំ ។ ប្តីរបស់ វណ្ណា ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅវះកាត់នៅមន្ទីរពេទ្យមោងឫស្សីមួយរយៈ ទើបអនុញ្ញាតឲ្យត្រឡប់មកផ្ទះ ប៉ុន្តែប្តីគាត់មិនអាចចេញទៅធ្វើបានដូចមុនបានទេ ។ នៅខណៈនោះ វណ្ណា ដែលអង្គការបានដកមកកងកិនអង្ករតែងតែលួចលាក់អង្ករមកទុកឲ្យប្តីគាត់ដាំហូប ។ ប៉ុន្តែដោយសារប្តីរបស់គាត់ឃ្លានខ្លាំងពេក និងហូបមិនតម ទើបធ្វើឲ្យជំងឺហើមកាន់តែធ្ងន់ធ្ងរឡើងឃើញដូច្នេះ វណ្ណា សូមឲ្យប្តីគាត់ឲ្យទៅព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបង ។ ប៉ុន្តែប្តីគាត់បានបដិសេធ ព្រោះខ្លាចបែកគ្នា តែដោយសារមានការអង្វរកពី វណ្ណា ជាច្រើនលើកទើបប្តីគាត់យល់ព្រមទៅព្យាបាល ហើយក៏បែកគ្នារហូតមក ។ ចំណែកបងជីដូនមួយឈ្មោះ ផុន (នៅផ្ទះជាប់គ្នា) ដោយសារឃ្លានខ្លាំងពេក បានយកខ្សែកទៅដូរយកអង្ករពីប្រជាជន ក៏ត្រូវឈ្លបតាមទាន់ និងរាយការណ៍ទៅយោធាឃុំ ។ នៅយប់បន្ទាប់ យោធាបីនាក់បានមកចាប់បងជីដូនមួយរបស់ វណ្ណា និង វណ្ណា ដោយចោទថា វណ្ណៈនាយទុន ។ ឈ្លបបានចាប់ចងស្លាបសេកបងជីដូនមួយរបស់គាត់ទៅក្រោយ ចំណែក វណ្ណា យោធាយកក្រមាមកចងដៃម្ខាង រួចបណ្តើរទៅវាលស្រែដែលមានចម្ងាយប្រមាណពីររយម៉ែត្រពីផ្ទះ ។ យោធាបានវាយទាត់ធាក់បងជីដូនមួយរបស់ វណ្ណា ចំណែក វណ្ណា ឈ្លបមិនបានវាយធ្វើបាបទេ ព្រោះប្រធានកង ឈ្មោះ មឿន ជាអ្នកធានាអះអាងពីភាពស្អាតស្អំរបស់ វណ្ណា ។ ក្រោយពីវាយធ្វើទារុណកម្ម និងព្រមានរួច ទើបយោធាដោះលែង វណ្ណា និងបងជីដូនមួយគាត់ឲ្យមកផ្ទះវិញ ។ ប៉ុន្តែបងជីដូនមួយរបស់គាត់ត្រូវធ្វើការផាររច្រើនជាងមុន រហូតដល់របួសម្រាមជើងនៅពេលចេញទៅកាប់ខស ។ ថ្ងៃមួយ ដោយឃើញបងជីដូមួយ និងកូនអត់ឃ្លានខ្លាំងពេក វណ្ណា

បានលួចយកអង្ករពីរកំប៉ុងឲ្យបង ។ ក្រោយពីទទួលអង្ករហើយ នៅពេលយប់ បងជីដូនមួយ វណ្ណា បានបបរអង្ករនោះទាំងអស់ ហូបជាមួយកូនប្រុស ។ រហូតដល់ព្រឹកឡើង ពេល វណ្ណា ទៅដាស់ បងជីដូនមួយរបស់គាត់ឲ្យក្រោកទៅធ្វើការ ទើបដឹងថាគាត់ស្លាប់ ដោយមិនមានស្លៀកសម្លៀកបំពាក់ ។ ឃើញដូច្នេះ វណ្ណា បានយក ក្រមាគ្របពីលើ និងយកដែកកេះរបស់បងជីដូនមួយគាត់រក្សាទុក និងប្រើប្រាស់បន្តទៀត ព្រោះដែកកេះមានតម្លៃណាស់នៅក្នុង សម័យនេះ ។ បន្ទាប់មក ទើប វណ្ណា រាយការណ៍ទៅឃុំ រហូតដល់ ម៉ោង ៣ រសៀលទើបឈ្លបមកសែងសាកសពបងជីដូនគាត់ទៅកប់ ចំណែកកូនប្រុសគាត់ត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅកងកុមារ ។

ក្រោយពីបាត់ប្តី និងបងជីដូនមួយ អង្គការកត់ឈ្មោះ វណ្ណា នៅក្នុងកងនៅលីវ និងឲ្យគាត់ទៅរស់នៅជាមួយគ្រួសារចាមដែល មានសមាជិកបីនាក់បងប្អូននៅក្នុងកងរកត្រី ដើម្បីឲ្យ វណ្ណា ជួយ ស្រាយមងដែលជំពាក់ (ព្រោះកាលពីនៅតូចគាត់ធ្លាប់ស្រាយ អំបោះឲ្យម្តាយរបស់គាត់ដែលត្បាញក្រមា និងសំពត់នៅផ្ទះ) ។ វណ្ណា រស់នៅជាមួយគ្រួសារចាម រហូតដល់ប្រជាជនក្នុងភូមិមួយ ចំនួនយល់ច្រឡំថា វណ្ណា ជាជនជាតិចាមទៀតផង ។ ក្រោយមក ដោយសង្កេតឃើញថា វណ្ណា មិនចេះនេសាទ អង្គការឲ្យគាត់មក កងកិនអង្ករ និងចុងភៅវិញ ។ នៅពេលដាំបាយម្តង វណ្ណា តែងតែ លួចដាក់អង្ករបន្ថែម ដើម្បីបានបាយច្រើនយកមកចែកឲ្យប្រជា ជននៅតាមកង ។ បន្ទាប់ពីដាំរួច វណ្ណា ត្រូវដួសបាយដាក់ក្នុងធុង រួចយកទៅចែកឲ្យប្រជាជនដែលមានជំងឺដែលចេញទៅធ្វើការមិន រួចនៅតាមផ្ទះទៀត ។ ថ្ងៃមួយ វណ្ណា បានទៅចែកបាយឲ្យអ្នក ជំងឺម្នាក់ឈ្មោះ យ៉ាត មកពីស្រុកកៀនស្វាយដែលកូន និងប្តីស្លាប់ ចោលអស់ដូចរាល់ដង ។ ពេលទៅដល់ផ្ទះ វណ្ណា ក៏ស្រែកហៅ ឈ្មោះ យ៉ាត! ប៉ុន្តែ មិនឆ្លើយតប ។ ដោយងឿងឆ្ងល់គាត់ក៏ឡើង ទៅមើលលើផ្ទះ ឃើញ យ៉ាត ស្លាប់ដោយផ្អែកនឹងសសរផ្ទះ ។ ក្រៅពី យ៉ាត ក៏មានអ្នកជំងឺស្លាប់ជាបន្តបន្ទាប់ដែរ ដោយសារអត់ អាហារ និងគ្មានថ្នាំព្យាបាល ។

បន្ទាប់ពីធ្វើការងារនៅកងចុងភៅមួយរយៈ អង្គការចាត់ តាំង វណ្ណា ឲ្យទៅច្រូតស្រូវនៅជិតភ្នំធិបតី ក្នុងស្រុកគាស់ក្រឡ ដែលមានចម្ងាយប្រមាណ៦០គីឡូម៉ែតពីភូមិ ដោយមានយាយ មឿង ជាប្រធានកង, ឈ្មោះ សិត ជាអ្នកនាំផ្លូវ និងឈ្មោះ ស្មឿង ជាយោធា ដឹកនាំទៅ ។ នៅទីនោះ អង្គការបានសាងសង់រោងវែង ប្រកស្បូវសម្រាប់ឲ្យកងនារីច្រូតស្រូវស្នាក់នៅ ។ កងរបស់ វណ្ណា ត្រូវច្រូតស្រូវដាក់គរនៅវាល រួចនាំគ្នាទូលយកមកទុកនៅរោង ។ នៅពេលបានស្រូវច្រើន ទើបប្រធានកង យាយ មឿង ហៅរទេះ គោមកដឹកយកទៅដាក់នៅក្នុងភូមិម្តង រួចចាត់តាំងឲ្យកងចាស់ៗ ក្រងសម្រាប់ប្រក់ផ្ទះ ។ ការងាររបស់ វណ្ណា នៅពេលនោះមិនសូវ លំបាកខ្លាំងទេ ចំណែករបបអាហារ គាត់ហូបបានគ្រប់គ្រាន់ ព្រម ទាំងមានបីចេងសម្រាប់បង់មូប និងមានស្ករត្នោតធ្វើបង្អែមហូប ទៀតផង ។

បន្ទាប់ពីធ្វើការងាររួច វណ្ណា និងកងច្រូតអាចដើរបេះ ផ្លែក្រឡោមក្តុក (មានពណ៌ខៀវ និង រូបរាងដូចផ្លែប៉ោម) យកមក ស្ងោរហូបទៀត ។ មានថ្ងៃខ្លះ យោធាខ្មែរក្រហមឈ្មោះ តាស្មឿង រកឃ្មុំបាន ក៏យកមកប្រគល់ឲ្យ វណ្ណា ស្ងោរលាយជាមួយស្លឹកព្រិច (សម្លឃ្មុំ និងស្លឹកព្រិច) ហូបថែមទៀត ។ ប៉ុន្តែថ្ងៃមួយ ពេល វណ្ណា ដើរទៅច្រូតស្រូវ ក៏ស្រាប់តែឃើញសាកសពមនុស្សស្លាប់ ដែល ស្ថិតនៅចម្ងាយប្រមាណ២ម៉ែត្រពីកន្លែងគាត់ច្រូត ធ្វើឲ្យគាត់ភិត ភ័យយ៉ាងខ្លាំង ។ ជនរងគ្រោះនោះ ត្រូវឈ្លបខ្មែរក្រហមយកមក វាយចោល ដោយមិនបានកប់នោះទេ ។ ពេលខ្លះទៀត វណ្ណា ឮ សម្រែករបស់ជនរងគ្រោះស្រែកឲ្យជួយគួរឲ្យសង្វេក និងធ្វើឲ្យ គាត់រន្ធត់ តក់ស្លុតយ៉ាងខ្លាំង ។ រហូតដល់រដូវទឹកឡើង ទើប វណ្ណា មានការលំបាកខ្លះ ព្រោះគាត់ត្រូវដេកផ្ទាល់ដី និងមានសត្វពស់ និងកង្កែបជាច្រើនបានវារឡើងមកលើទួលដែលគាត់ស្នាក់នៅ ។

វណ្ណា នៅកងច្រូតស្រូវរហូតដល់កងទ័ពវៀតណាមវាយ ចូលមកនៅឆ្នាំ១៩៧៩ ទើបគាត់ត្រឡប់មករកបងប្អូននៅស្រុក កំណើតវិញ ។ ក្រោយមក គាត់បានមករស់នៅជិតទួលស្លែង និង ប្រកបមុខរបរលក់នំបញ្ចុកដើម្បីរកលុយផ្គត់ផ្គង់ឲ្យប្អូនរៀនសូត្រ ។ នៅឆ្នាំ១៩៨១ ទើប វណ្ណា យកគ្រួសារថ្មី និងមានកូនចំនួន៣នាក់ ។

រហូតដល់ឆ្នាំ១៩៩៧ វណ្ណា បានដាក់ពាក្យចូលបម្រើជា បុគ្គលិកជាប់កិច្ចសន្យានៅក្រសួងអប់រំ និងបានមករស់នៅសាលា គរុកោសល្យ និងវិក្រិត្រការខេត្តកណ្តាល រហូតមកដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# រស់នៅលើភ្នំរយៈពេល១៣ឆ្នាំ ព្រោះតែសង្គ្រាម

ប្រទេសកម្ពុជាបានឆ្លងកាត់ភ្លើងសង្គ្រាមជាច្រើនទសវត្សរ៍ ធ្វើឲ្យប្រជាជនរងគ្រោះ និងជួបការលំបាកវេទនាជាច្រើន ។ ទន្ទឹមនឹងនេះ របបខ្មែរក្រហមក៏បានធ្វើឲ្យប្រជាជនបាត់បង់ជីវិតដែរ ។ ជាក់ស្តែង តាមរយៈការចុះមកធ្វើកម្មសិក្សាចំនួនបីថ្ងៃនៅស្រុកអន្លង់វែង ខ្ញុំបានជួបជនរងគ្រោះពីរបបខ្មែរក្រហមម្នាក់គឺអ្នកមីង ឆាំ ឡុង ដែលបានរៀបរាប់រឿងនេះប្រាប់ខ្ញុំ ។

ឆាំ ឡុង អាយុ៦០ឆ្នាំ មានស្រុកកំណើតនៅភូមិថ្មល់ដាច់ ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ ឡុង មានបងប្អូនចំនួន៥នាក់ ក្នុងនោះមានប្រុស ១នាក់ និងស្រី៤នាក់ ហើយគាត់ជាកូនទី២ ។ សព្វថ្ងៃ ឡុង មានកូនចំនួន៨នាក់ គឺប្រុសចំនួន២នាក់ និងស្រី៦នាក់ ។


ឆាំ ឡុង ជាមួយនឹងប្តីនៅផ្ទះ នៅភូមិត្រពាំងប្រិយ ឃុំទឹកជុំ ស្រុកអន្លង់វែង

កាលពីរបបសាធារណរដ្ឋខ្មែរ (របប លន់ នល់) ក្នុងអំឡុងឆ្នាំ១៩៧១ ឡុង ត្រូវបានខ្មែរក្រហមជម្លៀសពីស្រុកកំណើតឲ្យទៅរស់នៅភូមិផ្សេង ។ ការជម្លៀសដោយបង្ខំនេះ បានធ្វើឲ្យគាត់បែកបាក់ពីឪពុកម្តាយ និងបងប្អូនប្រុសស្រី រហូតបានមករស់នៅភូមិទឹកជុំ ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដល់សព្វថ្ងៃនេះ ។ ការរស់នៅកាលពីសម័យនោះ ឡុង ត្រូវប្រឈមនឹងការបាត់បង់ជីវិតដោយសារតែការទម្លាក់គ្រាប់បែកពីយន្តហោះអាមេរិកាំង ។ ជារៀងរាល់ថ្ងៃ ឡុង ត្រូវគេចខ្លួន នៅពេលសំឡេងយន្តហោះមកដល់ ។ គាត់បានបញ្ជាក់ថា មានមនុស្សមិនតិចទេ ដែលបានស្លាប់ដោយសារគេចចូលរណ្តៅត្រង់សេមិនទាន់ ។ ចំណែកគាត់មានសំណាងណាស់ ។

នៅក្នុងរបបខ្មែរក្រហម ដែលមានរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ ឡុង មានតួនាទីជាកសិករ ដែលត្រូវធ្វើការជាក្រុមជាមួយប្រជាជន៦ទៀតនៅចម្ការ និងវាលស្រែ ។ ជារៀងរាល់ថ្ងៃ ឡុង ត្រូវធ្វើការ៨ម៉ោង គឺព្រឹកចាប់ពីម៉ោង៧ ដល់ម៉ោង១១ និងពេលរសៀល ចាប់ពីម៉ោង២ ដល់ម៉ោង៥ល្ងាច ។ ទោះយ៉ាងណាត្រង់ចំណុចនេះ ឡុង បានឲ្យដឹងថា គាត់ហាក់នៅមានភាពធូរស្រាលជាងប្រជាជនកម្ពុជា នៅតំបន់ផ្សេងទៀតដែលត្រូវបង្ខំឲ្យធ្វើការលើសពី១០ម៉ោង (ច្រើនជាងគាត់) និងមានពេលខ្លះត្រូវធ្វើការនៅពេលយប់ថែមទៀត ។ ការងារជាប្រចាំរបស់ ឡុង នៅពេលនោះ គឺមានដូចជាកាប់ដី ស្ទូងស្រូវ ដាំដំឡូង ដាំពោត កាប់ឆ្ការព្រៃ ហើយនៅពេលដល់រដូវប្រមូលផល គឺគាត់ត្រូវបេះពោត និង ច្រូតស្រូវ ។ ឡុង បានបន្តថា ក្នុងរបបនោះ គាត់ត្រូវរស់នៅដោយភាពភ័យខ្លាច និងមិនមានអាហារបរិភោគគ្រប់គ្រាន់ ។ រាល់ថ្ងៃគាត់ហូបតែបបរ ដោយក្នុងមួយថ្ងៃគាត់ទទួលបានរបបអាហារតែពីរពេលប៉ុណ្ណោះ ។ ដូច្នេះហើយ នៅពេលដែលគាត់ធ្វើការអស់កម្លាំង និងហេវហត់ខ្លាំង គាត់តែងតែលួចហូបដំឡូង នៅពេលដែលអង្គការចាត់តាំងគាត់ឲ្យទៅកាស់ដំឡូង ។ ឡុង មិនបានធូរស្រាលក្នុងអារម្មណ៍ទេក្នុងរបបខ្មែរក្រហម ហើយគាត់តែងមមៃគិតពេលណាដែលគាត់រួចផុតពីរបបនេះ គាត់នឹងត្រឡប់

ទៅជួបជុំបងប្អូនឪពុកម្តាយមិនបាន ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ឡុង សង្ឃឹមថាជីវិតគាត់នឹងបានរស់សុខស្រួល និងបានជួបជុំបងប្អូនឪពុកម្តាយវិញ តែផ្ទុយទៅវិញ គាត់ត្រូវបន្តរស់នៅអន្លង់វែងដែលជាតំបន់ប្រទាញប្រទង់រវាងកងទ័ពខ្មាំងខ្មែរក្រហម និងរដ្ឋាភិបាលក្រុងភ្នំពេញ ។ គាត់ត្រូវបង្ខំចិត្តជម្លៀសខ្លួនទៅរស់នៅលើភ្នំដងរែកជាប់ព្រំដែនថៃ ជាមួយប្រជាជនជាច្រើនគ្រួសារទៀត ។ គាត់បានបន្តថា ជីវិតរស់នៅលំបាកវេទនា នៅពេលដែលគាត់រត់ឡើងភ្នំដែលត្រូវប្រឈមនឹងការអត់ឃ្លាន និងគ្មានទឹកគ្រប់គ្រាន់សម្រាប់ផឹក ។

ការរស់នៅលើភ្នំអស់រយៈពេល១៣ឆ្នាំ បានធ្វើឲ្យជីវិត ឡុង ជួបប្រទះនូវបញ្ហាជាច្រើន គឺនៅពេលណាដែលស្រូវមិនទាន់ទុំ គឺគាត់ប្រឈមការគ្មានបាយហូប ចំណែកឯផ្ទះសម្រាប់ស្នាក់នៅមិនមែនធ្វើពីឈើទេ គឺមានតែតង់កៅស៊ូបណ្តោះអាសន្នប៉ុណ្ណោះ ។ ការរស់នៅលើដងភ្នំរបស់ ឡុង នៅពេលនោះមិនត្រឹមមានជីវភាពលំបាកប៉ុណ្ណោះទេ តែគាត់នៅតែមានភាពភ័យខ្លាច ។ ឡុង បានបន្តទៀតថា ពេលណាដែលឮគ្រាប់ផ្លោងម្តងៗ គាត់បានរត់ចោលផ្ទះសម្បែង ស្រូវ ដំណាំ ដែលគាត់ខិតខំដាំជុំវិញផ្ទះ ។ គាត់បានរត់ដោយមានស្ពាយកូនទៅជាមួយ រួមទាំង ឆ្នាំង ចាន អង្ករ និងគ្មានគោលដៅច្បាស់លាស់ ។ មានប្រជាជនមួយចំនួនបានទៅរស់នៅលើទឹកដីថៃ ។

នៅពេលទៅរស់នៅកន្លែងថ្មី ឡុង ត្រូវកាប់ដីដាំស្រូវ និងដាំដំណាំទុកសម្រាប់ហូបសារជាថ្មី បើមិនដូចច្នេះនឹងគ្មានអាហារហូបឡើយ ។ ការរស់នៅបែបសភាពភ័យខ្លាច និងការរត់ចុះឡើងបែបនេះបានបន្តរហូតដល់ឆ្នាំ១៩៩៣ ។ នៅពេលសភាពការណ៍ (តំបន់អន្លង់វែង) មានភាពស្ងប់ស្ងាត់ ទើប ឡុង សម្រេចចិត្តនាំគ្រួសារចុះមកកសាងជីវភាពរស់នៅថ្មីនៅជើងភ្នំវិញ ព្រោះសង្ឃឹមថា នឹងរស់នៅបានសុខស្រួលជាងនៅលើភ្នំ ។ ប៉ុន្តែ គាត់រស់នៅមិនបានប៉ុន្មានផង គាត់ក៏នាំគ្រួសាររត់ទៅលើភ្នំវិញ ព្រោះមានការវាយប្រយុទ្ធគ្នាជាថ្មីទៀតរវាងកងទ័ពខ្មាំងខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាលភ្នំពេញ ។

ឡុង បាននិយាយទៀតថា រហូតដល់ឆ្នាំ១៩៩៨ ទើបស្គរសំឡេងគ្រាប់បែក គ្រាប់កាំភ្លើង និងការវាយប្រយុទ្ធគ្នានៅក្នុងតំបន់នេះបានបញ្ចប់ ហើយគាត់ក៏ចុះមកមករស់នៅក្នុងភូមិទឹកជុំរហូតមកដល់សព្វថ្ងៃនេះ ។ ការរស់នៅដោយឆ្លងកាត់សង្គ្រាមប្រមាណជាង២០ឆ្នាំរបស់ ឡុង បានធ្វើឲ្យមានផលលំបាកដល់កូនៗ និងមិនបានរៀនសូត្រខ្ពង់ខ្ពស់ ដោយសារតែការរត់លាក់ខ្លួន និងផ្លាស់ប្តូរទីកន្លែងជាញឹកញាប់ ធ្វើឲ្យគាត់គ្មានឱកាសដូចប្រជាជនដទៃ ។ សព្វថ្ងៃ ឡុង ប្រកបរបរធ្វើស្រែតែមួយមុខប៉ុណ្ណោះ ។ តែយ៉ាងណា គាត់មានជីវភាពសមរម្យដើម្បីចិញ្ចឹមគ្រួសារ ។


អូរនៅលើខ្នងភ្នំដងរែក ។ នៅក្នុងសម័យសង្គ្រាមស៊ីវិលយោធាខ្មែរក្រហម និងប្រជាជន បានយកទឹកអូរនេះមកប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងដាំដំណាំ ។

ចុងក្រោយ ឡុង បានសំណូមពរសូមកុំឲ្យកើតមានរបបខ្មែរក្រហមម្តងទៀត គឺគាត់ចង់តែរស់នៅក្នុងភាពស្ងប់ស្ងាត់ គ្មានសង្គ្រាម និងមានសុខសន្តិភាព ព្រោះក្នុងសម័យនោះ គាត់ជួបការលំបាកវេទនាគ្រប់គ្រាន់ហើយ ។

**សុខ គឹមសី**

# ជីវិត សាក់រូណា នៅក្នុងរបបខ្មែរក្រហម


អ៊ុក សាក់រូណា

អ៊ុក សាក់រូណា សព្វថ្ងៃអាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅភូមិយកបាត សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។ សាក់រូណា មានឪពុកឈ្មោះ អ៊ុក ឡូញ ម្តាយឈ្មោះ មាស ថាន មានបងប្អូន៣នាក់ ។ កាលពីសង្គមរាស្ត្រនិយម គ្រួសារ សាក់រូណា មានជីវភាពធូរធារដែលអាចមានលទ្ធភាពបញ្ជូនកូនចៅឲ្យទៅរៀនសូត្រនៅសាលាបានគ្រប់គ្នា ។ កាលពីតូច សាក់រូណា បានចូលរៀននៅសាលាបឋមសិក្សាយកបាត រួចហើយបន្តចូលរៀននៅអនុវិទ្យាល័យព្រែកឯងបានត្រឹមថ្នាក់ទី៥ "ចាស់" ។ រហូតដល់កើតមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ទាំងលោកគ្រូ ទាំងកូនសិស្ស រួមទាំង សាក់រូណា នាំគ្នាឈប់ទៅរៀន ។ លោកគ្រូអ្នកគ្រូខ្លះបានត្រឡប់ទៅស្រុកកំណើតវិញ ។ នៅពេលនោះ ក៏មានលេចឮដាហ្វូហែរថា មានខ្មែរក្រហមចូលមករស់នៅក្នុងភូមិ ហើយមានយុវជនខ្លះបានចូលធ្វើជាយោធាខ្មែរក្រហមតាមការឃោសនាទៀតផង ។

នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានកៀរប្រជាជននៅក្នុងភូមិយកបាត ដែលគ្រប់គ្រងដោយ លន់ នល់ ឲ្យទៅរស់នៅស្រុកស្អាងវិញ ។ គ្រួសារ សាក់រូណា និងប្រជាជនផ្សេងទៀតក៏បានចាកចេញពីស្រុកកំណើតទៅរស់នៅតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ។ ខ្មែរក្រហមបានចាត់តាំងប្រជាជនឲ្យធ្វើស្រែ និងដកស្ទូងរួមគ្នាអស់រយៈពេលជាងពីរឆ្នាំ តែមិនទាន់ឲ្យហូបបាយរួមទេ គឺហូបបាយតាមផ្ទះរៀងៗខ្លួន ។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាចបានរយៈពេលមួយខែ ខ្មែរក្រហមបានរៀបចំប្រជាជនដែលមករស់នៅក្នុងស្រុកស្អាងពីមុនឲ្យត្រឡប់ទៅស្រុកកំណើតវិញ ។ ពេលមកដល់ស្រុកកំណើតវិញ ទើប សាក់រូណា បានដឹង និងបានឃើញរឿងរ៉ាវកើតឡើងក្នុងភូមិរបស់គាត់គឺវត្តធម្មយុត្តិ ។

ខ្មែរក្រហមបានបង្ខំឲ្យព្រះសង្ឃចំនួន១២អង្គនៅក្នុងវត្តសឹកជាបន្ទាន់ ព្រោះអង្គការមិនអនុញ្ញាតឲ្យមានលោកសង្ឃ ការប្រតិបត្តិសាសនាបន្តទៀតទេ គឺត្រូវចុះធ្វើការងារទាំងអស់គ្នាដោយគ្មានអ្នកដេកចាំតែហូប ។ យោធាខ្មែរក្រហម បានយាមការពារវត្តមិនឲ្យប្រជាជនចេញចូល និងយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ។ មុនដំបូង យោធាខ្មែរក្រហមបានលួងលោមព្រះចៅអធិការវត្ត ព្រះនាម កុយ ទិត ដោយបានប្រាប់ថា និមន្តព្រះអង្គចេញពីវត្តទៅរស់នៅស្រុកកោះធំវិញ ព្រោះនៅទីនោះសម្បូរម្ហូបឆាន់ ។ ពេលនោះព្រះចៅអធិការវត្ត មានសង្ឃដីកាតបវិញថា អាត្មាបួសនេះមិនមែនដើម្បីឆាន់ទេ គឺឆាន់តែបន្តិចបន្តួចប៉ុណ្ណោះ តែអាត្មាបួសនេះគឺដើម្បីសាសនា ។ ពេលនោះ យោធាខ្មែរក្រហមមានការខឹងសម្បារយ៉ាងខ្លាំង ហើយដោយព្រះចៅអធិការនៅតែមិនព្រមសឹក ទើបពីរបីថ្ងៃក្រោយមកខ្មែរក្រហមក៏ប្រើជនដៃដល់ពីរបីនាក់ឲ្យទៅចាប់ព្រះចៅអធិការវត្តប្រកចូលបាវ រួចហើយយកដែកក្ងៅរទេះវាយសំពងព្រះអង្គរហូតដល់សុគត ។ បន្ទាប់មក យោធាខ្មែរក្រហមយកសាកសពព្រះអង្គទៅកប់នៅខាងក្រោមកុដិ ។ ប្រជាជនរស់នៅជិតវត្តបានដឹងនូវការប្រព្រឹត្តរបស់ខ្មែរក្រហម និងបានឃើញស្ទើរតែទាំងអស់គ្នា តែគ្មាននរណាហ៊ានជួយព្រះអង្គ ។ នៅខណៈនោះ ក៏មានព្រះសង្ឃមួយអង្គ មានឋានៈជាគ្រូសូត្រស្តាំ ព្រះនាម ទិត សុខុន ដែលបានរៀនដល់ (លីសង់កំប្លេ) រួមជាមួយព្រះសង្ឃ១២អង្គផ្សេងទៀតដែលមិនព្រមសឹក ក៏ត្រូវយោធាខ្មែរក្រហមបង្ខំឲ្យឡើងលើរថយន្តហើយបាត់ខ្លួនរហូតមក ។

នៅអំឡុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានហៅប្រជាជនរស់នៅក្នុងភូមិទាំងអស់មកប្រជុំ លើកលែងតែក្មេងៗ ។ ពេលប្រជុំខ្មែរក្រហមបានប្រាប់ថា "អង្គការឲ្យបងប្អូនធ្វើការងាររួម ហូបបាយរួម នៅក្នុងសហករណ៍គ្មានអ្នកមានគ្មានអ្នកក្រ ទ្រព្យសម្បត្តិដី

ធ្វី គោក្របី មាសប្រាក់ត្រូវរាយការណ៍ប្រាប់អង្គការឲ្យត្រង់ កុំលាក់ទុកសួនតួម្នាក់ឯង ត្រូវដាក់រួមជាសមូហភាពទាំងអស់គ្នា» ។ ខ្មែរក្រហមបានបែងចែកការងារធ្វើស្រែចម្ការនៅតាមវ័យ គឺយុវជនយុវនារីធ្វើការនៅក្នុងកងចល័ត (នៅឆ្ងាយពីភូមិ) វ័យកណ្ដាលដែលមានប្ដី ឬ ប្រពន្ធ ធ្វើស្រែនៅក្នុងសហករណ៍ជិតៗភូមិ ចំណែកយាយៗដែលមានវ័យចាស់ មានតួនាទីមើលក្មេងៗតូច ដែលអាយុពី១ឆ្នាំ ទៅដល់៤ឆ្នាំ ។

នៅពេលនោះ សាក់រូណា ពេញវ័យជាយុវនារី ដូច្នេះខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅលើកទំនប់ ជីកប្រឡាយ នៅវត្តកៀនស្វាយក្នុង ។ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំងគាត់ឲ្យទៅនៅក្នុងកងចល័តស្រុកដែលមានប្រធានឈ្មោះនារី ស្រ៊ាន មានស្រុកកំណើតនៅកោះធំជាអ្នកដឹកនាំនារីរាប់រយនាក់ធ្វើការងារ ។ សាក់រូណានៅធ្វើការនៅស្រែអំពិល ស្រុកកៀនស្វាយ តែអង្គការហាមមិនឲ្យរត់មកផ្ទះទេ ។ មាននារីខ្លះនឹកឪពុកម្ដាយពេក ក៏លួចរត់មកផ្ទះដើម្បីបានជួបឪពុកម្ដាយ តែពេលត្រឡប់ទៅធ្វើការវិញ មិនទាន់ម៉ោងត្រូវប្រធានអង្គកងហៅទៅកសាង ឬធ្វើទារុណកម្ម ។ មានសមាជិកកងខ្លះត្រូវយោធា ខ្មែរក្រហមចាប់បញ្ជូនមកមន្ទីរសន្តិសុខវត្តចំពុះក្អែក ដែលមានឈ្មោះ យាយបូ មកពីភូមិភាគនិរតី ជាកម្មាភិបាលថ្នាក់ស្រុកជាអ្នកគ្រប់គ្រង ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបញ្ជូន សាក់រូណា និងយុវនារីយុវជនរាប់រយនាក់ផ្សេងទៀត ឲ្យទៅធ្វើការងារកងចល័តនៅវត្តអង្គរជ័យ ស្រុកកៀនស្វាយ ។ ពេលទៅដល់ ខ្មែរក្រហមបានសាងសង់រោងសម្រាប់យុវជន និង យុវនារីស្នាក់នៅ ប៉ុន្តែរោងនៅដាច់ឆ្ងាយពីគ្នា និងហាមមិនឲ្យទាក់ទងគ្នា បើមាននរណាហ៊ានណាត់ជួបគ្នាហើយអង្គការឃើញ នឹងចោទថាខុសសីលធម៌ ហើយប្រាកដជាស្លាប់មិនខាន ។ ការងារកងចល័តនៅវត្តអង្គរជ័យធ្ងន់ធ្ងរ តែគ្មានរបបអាហារគ្រប់គ្រាន់ទេ នារីខ្លះមុខជ្រួញ នៅសល់តែស្បែក និងឆ្អឹង ដូចជាមនុស្សចាស់ ។ សាក់រូណា គ្មានអាហារហូបគ្រប់គ្រាន់ បានធ្លាក់ខ្លួនឈឺស្គម ធ្វើការងារនៅក្នុងកងចល័តលែងកើត ទើបខ្មែរក្រហមចាត់តាំងឲ្យទៅឃ្វាលគោវិញ ។ មានថ្ងៃមួយ ពេលស្បៀយពីជំងឺ សាក់រូណា ក៏សម្រេចចិត្តដើរពីការដ្ឋានអង្គរជ័យមកលេងឪពុកម្ដាយនៅផ្ទះ ។ ប៉ុន្តែ សំណាងអាក្រក់ គាត់មិនបានជួបទេ ព្រោះឪពុកម្ដាយគាត់ត្រូវទៅធ្វើការងារនៅតាមការដ្ឋាន ។ ដោយខ្លាចប្រធានកងចោទប្រកាន់ សាក់រូណា ក៏ត្រឡប់មកអង្គភាពវិញ ប៉ុន្តែពេលធ្វើដំណើរមកដល់សាលាស្រុកកៀនស្វាយ យោធាខ្មែរក្រហមបានឃាត់គាត់ ហើយសួរថា «មិត្តនារីឯងដើរទៅណា?» ពេលនោះសាក់រូណា ឆ្លើយថា «ខ្ញុំមកពីលេងផ្ទះ ឥឡូវខ្ញុំត្រឡប់ទៅអង្គភាព» ។ ខណៈនោះ យោធាខ្មែរក្រហមដែលបើកត្រាក់ទ័រដឹកថ្មទៅកាន់ការដ្ឋានអង្គរជ័យដែរ ក៏ហៅ សាក់រូណា ឲ្យឡើងជិះជាមួយ ស្រាប់តែទៅដល់យោធានោះប្រាប់កម្មាភិបាលនៅអង្គភាពថា «គាត់រត់ចោលជួរ» រួចបើកត្រាក់ទ័រចេញទៅបាត់ ។ បន្ទាប់មក ប្រធានកងនារីស្រ៊ាន ហៅ សាក់រូណា មកសួរថា មិត្តនារីឯងរត់ទៅផ្ទះមែនដែរបទេ? ពេលនោះ សាក់រូណា ឆ្លើយថា មិត្តបងខ្ញុំអត់បានរត់ទៅណាទេខ្ញុំទៅដើររកគល់ឈើមកដុតភ្លុកកុំឲ្យមូសខាំគោ ។ ពេលនោះប្រធានអង្គភាពក៏ជឿ ដោយសារ សាក់រូណា ជាអ្នកឃ្វាលគោ តែប្រសិនបើដឹងវិញ ច្បាស់ជាប្រធានកងចាប់ចងគាត់ឲ្យមូសខាំមួយយប់មិនខាន ។ ប្រធានដែលគ្រប់គ្រងនៅការដ្ឋានអង្គរជ័យ ឈ្មោះនារី ម៉ន មានស្រុកកំណើតនៅខេត្តតាកែវ ។ ម៉ន មាន ចរិតកាច ហើយបើមានធ្វើខុស ច្បាស់ជាមិនបានរួចខ្លួនឡើយ ។ ក្រោយមក អង្គការក៏ផ្លាស់នារី ម៉ន និង នារី ស្រ៊ាន ចេញ និងដាក់អ្នកថ្មីមកជំនួស ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា កម្មាភិបាលខ្មែរក្រហមបាននាំគ្នារត់ ហើយនៅតាមផ្លូវសាក់រូណា ឃើញយោធាខ្មែរក្រហមក្មេងៗស្លាប់ដោយសារកងទ័ពវៀតណាមបាញ់ ព្រោះយោធាខ្មែរក្រហមទាំងនោះមិនព្រមបោះកាំភ្លើងចោល ។ សាក់រូណា បានធ្វើដំណើររយៈពេលបីថ្ងៃទើបមកដល់ស្រុកកំណើត និងបានជួបជុំឪពុកម្ដាយបងប្អូនវិញ ។ នៅឆ្នាំ១៩៨២ ដោយមានចំណេះដឹងបន្តិចបន្តួច សាក់រូណា ក៏ស្ម័គ្រចិត្តចូលធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាភូមិរទាំង ។ នៅឆ្នាំ១៩៨៩ ឪពុកម្ដាយបាន រៀបចំឲ្យគាត់មានប្ដី និងមានកូនចំនួនពីរនាក់ (ស្រី១ ប្រុស១) តែក្រោយមកដោយការរស់នៅមិនចុះសម្រុងជាគ្នា គាត់ក៏លែងលះគ្នា ។ សព្វថ្ងៃ សាក់រូណា ឈប់ធ្វើជាគ្រូបង្រៀនហើយ គឺគាត់មកប្រកបរបរបន្តិចបន្តួចនៅផ្ទះវិញហើយឆ្លៀតពេលទំនេរ គាត់ក៏ទៅធ្វើបុណ្យនៅវត្តធម្មយុត្តិដើម្បីកសាងកុសលទៅជាតិមុខទៀត ។ **សុខ ខណ្ណៈ**

# ខ្ញុំមិនខ្លាចខ្មែរក្រហមទេ

ប្រជាជនកម្ពុជាភាគច្រើននៅពេលនិយាយពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម សុទ្ធតែគិតថា ជាសម័យដែលឃោរឃៅ ព្រោះមនុស្សម្នាក់ៗត្រូវរស់នៅយ៉ាងលំបាកវេទនា និងគ្មានសិទ្ធិសេរីភាព ។ ប៉ុន្តែដោយឡែក ពេជ្រ រុន ដែលធ្លាប់បានឆ្លងកាត់ក្នុងសម័យខ្មែរក្រហម មានលក្ខណៈខុសប្លែកពីអ្នកដទៃ ព្រោះគាត់មិនបានជួបនូវទុក្ខវេទនា ការធ្វើទារុណកម្ម ថែមទាំងមានសិទ្ធិសេរីភាពក្នុងការរៀបអាពាហ៍ពិពាហ៍ទៀត ។

ពេជ្រ រុន សព្វថ្ងៃមានអាយុ៥៨ឆ្នាំ មានស្រុកកំណើត នៅភូមិដំណាក់ស្លួល ឃុំស្រែក្នុង ស្រុកជុំគិរី ខេត្តកំពត ហើយបច្ចុប្បន្នរស់នៅភូមិទឹកជុំ ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ រុន មានបងប្អូនចំនួនប្រាំនាក់ (ប្រុសពីរនាក់ ស្រីបីនាក់) ដែលបងប្រុសធំរបស់គាត់បានស្លាប់ក្នុងឆ្នាំ១៩៦៨ និងបងប្រុសទីពីរស្លាប់នៅឆ្នាំ១៩៩៧ ចំណែកបងប្អូនស្រីពីរអ្នកផ្សេងទៀត ម្នាក់រស់នៅឯភ្នំពេញ និងម្នាក់ទៀតនៅពេជ្រនិល ។

នៅក្នុងឆ្នាំ១៩៧៤ មានកម្មាភិបាលបានប្រកាសជ្រើសរើសយុវជនស្ម័គ្រចិត្ត ដើម្បីបម្រើការក្នុងជួរកងទ័ពដើម្បីប្រឆាំងនឹងរបប លន់ នល់ ។ ពេលនោះ រុន ដែលមានអាយុប្រមាណ១៧ឆ្នាំ រួមជាមួយនឹងបងស្រីរបស់គាត់ បានស្ម័គ្រចិត្តចូលរៀនកាត់ដេរនៅអង្គភាពទ័ព ក្នុងខេត្តកំពត ។ ក្រោយពេលកងទ័ពខ្មែរក្រហមច្បាំងឈ្នះកងទ័ព លន់ នល់ គាត់ក៏បានផ្លាស់ប្តូរអង្គភាពកាត់ដេរពីកំពត ទៅតាកែវ រហូតដល់ឆ្នាំ១៩៧៨ ។ រុន បាននិយាយថា អំឡុងពេលនោះ គាត់មានសេរីភាព និងអាចសុំច្បាប់សម្រាកដើម្បីទៅជួបក្រុមគ្រួសារនៅស្រុក ចំណែកអង្គភាពរបស់គ្រួសារគាត់នៅស្រុកក៏បានផ្តល់អាហារដល់គាត់ ក៏ដូចជាកន្លែងស្នាក់នៅដែល



ពេជ្រ រុន ផ្តល់បទសម្ភាសន៍អំពីបទពិសោធន៍នៅក្នុងសម័យខ្មែរក្រហម ដល់ ហួត ប៊ុនគង់ បុគ្គលិកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅផ្ទះរបស់គាត់ ស្ថិតនៅឃុំទឹកជុំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ពេលខ្លះគាត់បានស្នាក់នៅផ្ទះរយៈពេលមួយសប្តាហ៍ទៀតផង ។

រហូតមកដល់ឆ្នាំ១៩៧៨ ពេលកងទ័ពវៀតណាមវាយជាមួយនឹងយោធាខ្មែរក្រហមកាន់តែខ្លាំង រុន ត្រូវបានអង្គការជម្លៀសឲ្យទៅនៅអង្គភាពកាត់ដេរ ខេត្តបាត់ដំបងវិញ ។ អង្គភាពរបស់ រុន មានទីតាំងនៅផ្សារ ឬហៅថាផ្សារកាត់ដេរនៅក្នុងសម័យខ្មែរក្រហម ។

រហូតដល់ឆ្នាំ១៩៨០ ដោយសារយោធាខ្មែរក្រហមមិនអាចទប់ទល់ជាមួយនឹងកងទ័ពវៀតណាមបាន រុន ត្រូវបានមេអង្គភាពផ្លាស់ពីអង្គភាពកាត់ដេរឲ្យទៅនៅកង៨០៨ ក្នុងខេត្តឧត្តរមានជ័យវិញ ។ រុន បានចាកចេញពីខេត្តបាត់ដំបងតាមរយៈរថយន្ត ប៉ុន្តែដោយសារកងទ័ពវៀតណាមបាញ់សំដៅទៅលើរថយន្តរបស់គាត់ខ្លាំងពេក ទើបគាត់ និងកងនារីកាត់ដេរ និងអ្នកជម្លៀសផ្សេងទៀតបង្ខំចិត្តដើរចូលព្រៃ ។ ក្នុងពេលនោះ គាត់ត្រូវបានផ្លាស់ទៅផ្នែកកងនារីដឹកជញ្ជូន ដោយការងាររបស់គាត់ គឺ ទូលអង្ករ និងគ្រាប់រំសេវយកទៅឲ្យកងទ័ពនៅសមរភូមិមុខ ហើយពេលខ្លះគាត់មិនមានបាយហូបរយៈពេលជាច្រើនថ្ងៃទៀតផង ។

មកដល់ឆ្នាំ១៩៨០ ខ្មែរក្រហមក៏បើកច្រកថ្មី (ច្រកចេញចូលទៅប្រទេសថៃ) នៅជើងភ្នំ១០០១ ខ្មែរក្រហមក៏ចាប់ផ្តើមដើរប្រមូលនារីកាត់ដេរឡើងវិញ ដែលមាននារីកាត់ដេរប្រហែលពីប្រាំនាក់ ទៅដប់នាក់ ហើយ រុន ក៏ត្រូវបានជ្រើសរើសក្នុងចំណោមនោះដែរ ដើម្បីដេរខោអាវផ្គត់ផ្គង់ទៅកងទ័ពខ្មែរក្រហមច្បាំងជាមួយវៀតណាម ។

នៅក្នុងឆ្នាំដដែលនោះ ខ្មែរក្រហមបានបើកច្រកថ្មីមួយទៀតនៅជើងភ្នំ១០០៣ ហើយ រុន ក៏ត្រូវបានផ្លាស់ប្តូរទៅនៅទីនោះដើម្បីកាត់ដេរខោអាវឧបត្ថម្ភដល់កងទ័ពកងនារីដឹកជញ្ជូនទៀត ។ នៅក្នុងឆ្នាំ១៩៨៤ ពេជ្រ រុន បានរៀបការជាមួយនឹងប្តីរបស់គាត់ តៅ ណូ ដែលការរៀបអាពាហ៍ពិពាហ៍នេះធ្វើឡើងដោយស្ម័គ្រចិត្ត និងជ្រើសរើសដោយខ្លួនឯងដោយគ្មានការចាប់បង្ខំពីអង្គការឡើយ ។ការរៀបការរបស់ រុនគឺប្រារព្ធធ្វើទៅតាមលក្ខណៈប្រពៃណីខ្មែរ ដោយមានអាចារ្យជាមេបា ប៉ុន្តែមិនបានពេញលេញ និងគ្រប់លក្ខណៈដូចសព្វថ្ងៃទេ ។ បន្ទាប់ពីរៀបការរួច រុន បង្កើតបានកូនបួននាក់ គឺ ទីមួយ) មានឈ្មោះ ណូ ជឿ, ទីពីរ) ណូ ជិន, ទីបី) ណូ វុទ្ធី និងទីបួន) ណូ លីណា ។

នៅឆ្នាំ១៩៩០ រុន បានចុះពីលើភ្នំដងរែក មករស់នៅឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ដែលជាលំនៅដ្ឋានរបស់គាត់សព្វថ្ងៃ ។ នៅពេលមកដល់ដំបូង ក្រុមគ្រួសាររបស់គាត់ និងអ្នកស្រុកអន្លង់វែងទាំងអស់ ត្រូវបាន តាម៉ុក ទទួលចិញ្ចឹម ដោយទទួលបានអង្ករ ត្រីខដែលបើកក្នុងរយៈ១០ថ្ងៃទៅ១៥ថ្ងៃម្តង ដោយមិនគិតពីមនុស្សតូច ឬ ធំទេ ។ មួយរយៈក្រោយមក រុន ក៏ចាប់ផ្តើមប្រកបមុខរបរដោយធ្វើស្រែផ្ទាល់ខ្លួន និង ស្នើសុំកូនជ្រូក និង គោ ពីតាម៉ុក មកចិញ្ចឹម ។ ក្រោយពីគោ និងជ្រូកធំធាត់ គាត់បានយកទៅលក់ឲ្យតាម៉ុក ដើម្បីប្តូរយកប្រាក់មកវិញ ដែលពេលនោះ ការចាយវាយគឺប្រើប្រាស់ប្រាក់បាតដែលជារូបិយប័ណ្ណថៃ ។ រុន បានសន្សំប្រាក់ទុកទិញសម្ភារ អីវ៉ាន់ និងចំណីអាហារពីព្រំប្រទល់ប្រទេសថៃដើម្បីផ្គត់ផ្គង់គ្រួសារ ។ ទោះយ៉ាងណា នៅក្នុងអំឡុងរដូវប្រាំង រុន តែងតែរត់ឡើងលើភ្នំដើម្បីគេចចេញពីការវាយប្រយុទ្ធពីកងទ័ពវៀតណាម ។ នៅក្នុងឆ្នាំ១៩៩៦ យោធាខ្មែរក្រហមបានផ្ទុះសង្គ្រាមជាមួយនឹងកងទ័ពរដ្ឋាភិបាលម្តងទៀត ចំណែកប្តីរបស់ រុន ក៏បានស្លាប់ដោយសារជាន់មីនពេលចល័តទ័ពនៅពេលនោះ ។ រហូតដល់ឆ្នាំ១៩៩៧ នៅពេលកងយោធាខ្មែរក្រហមប្រកាសធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ទើបក្រុមគ្រួសាររបស់គាត់បានរស់នៅដោយសុខសន្តិភាពពេញលេញ ។

ជាចុងក្រោយ រុន បានមានប្រសាសន៍ថា រវាងរបបខ្មែរក្រហម និងសម័យក្រោយពេលសមាហរណកម្ម ការរស់នៅមិនមានភាពខុសគ្នានោះទេ ឧទាហរណ៍ គាត់ធ្វើការនៅក្នុងរបបខ្មែរក្រហមក៏ដើម្បីសម្លៀកបំពាក់ និងម្ហូបអាហារ ចំណែកនៅសម័យនេះ គឺដើម្បីយកប្រាក់មកចាយវាយក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ រុន បានបន្ថែមទៀតថា “គាត់មិនមានអារម្មណ៍ខ្លាចសម័យខ្មែរក្រហមទេ ពីព្រោះគាត់គិតថាឲ្យតែមនុស្សខុសប្រាហ៍ព្យាយាម ទៅដល់ទីណានៅក្នុងសម័យកាលណាក៏មិនខុសគ្នាដែរ” ។ ទស្សនៈយល់ឃើញរបស់ រុន ដែលបានលើកឡើងនេះ គឺមានលក្ខណៈខុសប្លែកពីទស្សនៈរបស់ជនរងគ្រោះដែលធ្លាប់ឆ្លងកាត់ទុក្ខលំបាកក្នុងសម័យខ្មែរក្រហមជាច្រើនទៀត ។

**ហួត ប៊ុនគង់**

# សំណាងហើយដែលនៅមានជីវិត


ទូច ឆិល

ទូច ឆិល មានអាយុ ៦៣ឆ្នាំ រស់នៅភូមិទឹកជុំ ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ឆិល មានស្រុកកំណើតនៅភូមិត្នោត ឃុំដើងរស់ ស្រុកខដុគ្គ ខេត្តកំពង់ស្ពឺ ។ឆិល មានបងប្អូនបង្កើតចំនួនប្រាំនាក់ (ស្រីពីរនាក់ ប្រុសបីនាក់) ហើយគាត់ជាកូនពៅនៅក្នុងគ្រួសារ ។ សព្វថ្ងៃ ឆិល មិនបានប្រកបមុខរបរអ្វីទេ គឺក្រៅអំពីនៅផ្ទះមើលថែរក្សាចៅៗ ព្រោះគាត់ពិការ និងមានជំងឺសរសៃប្រសាទ ។ ឆិល មានប្រពន្ធឈ្មោះ ឆាំង ឡុង អាយុ៦០ឆ្នាំ មុខរបរមេភូមិទឹកជុំ ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងមានកូនចំនួនប្រាំបីនាក់ (ស្រីប្រាំមួយនាក់ ប្រុស២នាក់) ។

ឆិល បានរៀបរាប់ថា នៅក្នុងសម័យសង្គមរាស្ត្រនិយម គាត់រស់នៅជួបជុំក្រុមគ្រួសារ ជាពិសេសបានរស់នៅជាមួយឪពុកម្តាយជាទីស្រឡាញ់ ។ ជីវភាពគ្រួសាររបស់គាត់នៅក្នុងសម័យនោះមានភាពល្អប្រសើរណាស់ ដោយសារនៅក្នុងសង្គមពុំមានចោរលួច ឆក់ប្លន់ គ្មានអំពើពុករលួយ បញ្ហាអសន្តិសុខ គ្មានការជួយដូរ និងប្រើប្រាស់គ្រឿងញៀន ។ លើសពីនេះ ប្រជាពលគ្រប់រូបមានសិទ្ធិសេរីភាពពេញលេញក្នុងការបញ្ចេញមតិយោបល់ផ្សេងៗ ការប្រកបមុខរបរ និងការរស់នៅជាដើម ។

នៅឆ្នាំ១៩៧០ ឆិល ត្រូវបែកពីក្រុមគ្រួសារមកចូលរួមជាមួយបដិវត្តន៍ ។ ការចូលធ្វើយោធាសម័យនោះ គឺមិនមែនដើម្បីរស់នៅសុខស្រួលទេ គឺដើម្បីបុព្វហេតុជាតិមាតុភូមិ ក្នុងការធ្វើសឹកសង្គ្រាមជាមួយទាហានអាមេរិកាំង និង កងទ័ព ធៀវ គី (កងទ័ពវៀតណាមខាងត្បូង) ។ នៅឆ្នាំ១៩៧៣ ជាអកុសល គាត់បានរងរបួសធ្ងន់ដោយសារគាត់ត្រូវបានទាហានអាមេរិកាំងបាញ់គាត់ចំឆ្អឹងខ្នង និងស្មៀតផ្កា ហើយមួយគ្រាប់ទៀត ចំលលាដ៍ក្បាល ។ ឆិល មិននឹកស្មានថា គាត់នៅមានជីវិតរស់នៅរហូតមកទល់សព្វថ្ងៃនេះទេ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ ឆិល ត្រូវបានអង្គភាពបញ្ជូនទៅសម្រាក និងព្យាបាលនៅមន្ទីរពេទ្យរុស្ស៊ី រាជធានីភ្នំពេញ ។ ការព្យាបាលនៅពេលនោះពុំបានជាប់លាប់ និងដិតដល់ទេ ដូច្នេះគាត់ក៏ត្រឡប់មករស់នៅក្នុងអង្គភាពរបស់គាត់នៅភូមប្រវ៉ារាល ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងវិញ ។ ប៉ុន្តែដោយស្ថានភាពជំងឺរបស់គាត់មានសភាពធ្ងន់ធ្ងរ ទើបគាត់ត្រូវធ្វើដំណើរចុះឡើងដើម្បីពិនិត្យ និងព្យាបាលជំងឺរបស់គាត់នៅពេទ្យរុស្ស៊ីបន្តទៀត ។

នៅក្នុងឆ្នាំ១៩៧៩ ដោយសារស្ថានភាពនៅទីក្រុងភ្នំពេញមានភាពច្របូកច្របល់ អង្គការតម្រូវឲ្យប្រជាពលរដ្ឋគ្រប់រូបជម្លៀសខ្លួនចេញពីរាជធានីភ្នំពេញ ដូច្នេះគាត់ក៏បានភៀសខ្លួនពីរាជធានីភ្នំពេញទៅរស់នៅស្រុកសំឡូត ខេត្តបាត់ដំបង ។ ឆិល រស់នៅទីនោះបានរយៈពេលប្រហែលពីរទៅបីខែ តែដោយសារលក្ខខណ្ឌពិបាករស់នៅ គាត់បន្តភៀសខ្លួនទៅស្រុកម៉ាឡៃ និងស្រុកកំរៀង (នៅម្តុំឡែម និង កាប៊ីន) ។ គាត់បានលើកឡើងថា នៅពេលនោះ គាត់មិនដាច់ចិត្តភៀសខ្លួនទៅរស់នៅប្រទេសទីបី (សហរដ្ឋអាមេរិក) ទេ ព្រោះគាត់នឹកឪពុកម្តាយ បងប្អូន និងមិនចង់បែកបាក់ពីក្រុមគ្រួសារ ។ ឆិល បានបញ្ជាក់ទៀតថា គ្រានោះ ស្ថានភាពនៃការរស់នៅពិតជាជួបការលំបាកវេទនាយ៉ាងខ្លាំង ដោយសារអសន្តិសុខ និងគ្មានអាហារបរិភោគ ។ នៅពេលនោះ ដោយសារតែឆិល ធ្លាប់រងរបួសកាលពីសម័យ លន់ នល់ ទើបធ្វើឲ្យស្ថានភាពសុខភាពរបស់គាត់មានការប្រឈមយ៉ាងខ្លាំង ។ គាត់ប្រកាច់ជាញឹកញាប់ និងមានជំងឺសរសៃប្រសាទទៀត ដូច្នេះគាត់ត្រូវទៅជួបគ្រូពេទ្យជាប្រចាំដើម្បីទទួលបានការពិនិត្យ និងតាមដានសុខភាព ។ មិនយូរប៉ុន្មាន ឆិល បានភៀសខ្លួនទៅអារញ្ញ (ប្រទេសថៃ) ។ នៅទីនោះ អង្គការរៀបចំឲ្យគាត់ចេញទៅសហរដ្ឋអាមេរិកទៀត តែគាត់មិនព្រមទៅ ព្រោះ

មិនដាច់ចិត្តចាកចោលបងប្អូន ឪពុកម្តាយ និងប្រទេសរបស់គាត់ ទោះបីគាត់ជួបការលំបាកយ៉ាងណាក៏ដោយ ។

នៅឆ្នាំ១៩៨០ ឆិល បានសម្រេចចិត្តចេញពីតំបន់អារញ្ញ ទៅរស់នៅតំបន់អន្លង់វែង ប៉ុន្តែដោយសារនៅទីនោះមានកងទ័ពវៀតណាម ដូច្នេះ គាត់ក៏បានទៅរស់នៅតំបន់កាប់ឆឹង ក្នុងទឹកដីថៃ និងនៅលើភ្នំដងរែក រហូតដល់ឆ្នាំ១៩៩០ ។ ឆិល បានជួប ឆាំ ឡុង ប្រពន្ធរបស់គាត់សព្វថ្ងៃ និងបានរៀបមង្គលការតាំងពីឆ្នាំ១៩៨០ ។ ការរៀបពិធីមង្គលការរបស់គាត់ទាំងពីរនាក់នៅពេលនោះ គឺរៀបចំឡើងតាមបែបប្រពៃណីទំនៀមទម្លាប់ខ្មែរ ដោយមិនមានការផ្សំផ្គុំដូចរបបខ្មែរក្រហមនោះទេ ។ ប៉ុន្តែ មិនមានតុ និងកៅអីអង្គុយ ដូចសព្វថ្ងៃនេះទេ ។ នៅឆ្នាំ១៩៩១ ឆិល និងប្រពន្ធ ព្រមទាំងកូនរបស់គាត់បួននាក់ បានចុះមករស់នៅអន្លង់វែង និងចាប់យកដីសម្រាប់សាងសង់ផ្ទះសម្បែង និងប្រកបរបររកស៊ីចិញ្ចឹមជីវិតវិញ ។ ប៉ុន្តែ សភាពការណ៍ពេលនោះក៏មិនទាន់មានស្ថិរភាព ហើយការរស់នៅក៏មិនទាន់ពិតប្រាកដដែរ ។ ចំណែកការបង្កបង្កើនផលក៏មិនទាន់បានប្រមូល និងហូបចុកទៀត ព្រោះត្រូវចល័តចុះឡើង ប្តូរតំទៅនៅលើភ្នំដងរែក ដោយសារតែការវាយប្រយុទ្ធគ្នា ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ឆិល បានបញ្ជាក់ថា ការរស់នៅក្រោមការដឹកនាំរបស់ តាម៉ុក នៅតំបន់អន្លង់វែងប្រជាជនទទួលបានភាពកក់ក្តៅខ្លាំង និងមានរបបហូបចុកគ្រប់គ្រាន់ ។ តាម៉ុក បានអប់រំប្រជាជនឲ្យស្រឡាញ់សម្បត្តិធម្មជាតិ ដូចជា ព្រៃឈើ និងសត្វព្រៃ ព្រមទាំងបំផុសផ្នត់គំនិតប្រជាជនឲ្យបេះដាំដុះ និងធ្វើស្រែចម្ការ ។ តាម៉ុក បាននិយាយពាក្យមួយឃ្លាថា ជើងជាប់ដីក្បាលមិនជាប់មេឃ គឺគាត់ចង់បំផុសស្មារតី និងផ្នត់គំនិតប្រជាជនឲ្យស្គាល់ដី ត្រូវបេះដាំដុះ កុំទម្លាប់ខ្ជិលច្រអូស និងចាំតែហូបស្រាប់ ។ ឆិល ក៏បានបញ្ជាក់ទៀតថា នៅពេលដែលតំបន់អន្លង់វែងមិនទាន់ធ្វើសមាហរណកម្ម គាត់និងក្រុមគ្រួសារមានអាហារហូបចុកគ្រប់គ្រាន់ និងបានរស់នៅជួបជុំគ្រួសារ ។ ទោះយ៉ាងណានៅពេលនោះ គាត់ចង់ឲ្យ តាម៉ុក ចុះចូលជាមួយរដ្ឋាភិបាល ដោយមិនចង់ឲ្យតំបន់អន្លង់វែងនៅតែជាតំបន់តស៊ូ និងជាតំបន់ស្វយ័តបន្តទៀតទេ ។

ក្រោយពេលដែលតំបន់អន្លង់វែងធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ឆិល និងក្រុមគ្រួសារ និងអ្នកភូមិដទៃទៀតក្នុងស្រុកអន្លង់វែង ពេញចិត្តយ៉ាងខ្លាំង ពីព្រោះលែងមានការព្រួយបារម្ភពីបញ្ហាអសន្តិសុខ និងបង្កលក្ខណៈឲ្យគាត់ងាយស្រួលក្នុងការធ្វើដំណើរពីតំបន់មួយទៅកាន់តំបន់មួយទៀត ការប្រកបមុខរបររកស៊ី និងការទៅសួរសុខទុក្ខបងប្អូនដែលរស់នៅខេត្តឆ្ងាយៗជាដើម ។

សព្វថ្ងៃនេះ ឆិល មិនអាចប្រកបមុខរបររកស៊ីអ្វីបានឡើយ ក្រៅអំពីនៅផ្ទះ និងមើលចៅៗ ។ ដោយសារតែឥទ្ធិពលសង្គ្រាមបានធ្វើឲ្យគាត់ពិការកាយសម្បទា មិនអាចធ្វើការងារបាន ។ ឆិល បាននិយាយទៀតថា ពេលខ្លះគាត់ក៏មានអារម្មណ៍តូចចិត្តនឹងវាសនារបស់ខ្លួនឯងដែរ ក្នុងនាមជាមេគ្រួសារ មិនអាចប្រកបមុខរបររកស៊ីដើម្បីផ្គត់ផ្គង់ដល់ជីវភាពគ្រួសារបាន ថែមទាំងនាំឲ្យប្រពន្ធកូននឿយហត់នឹងខ្លួនឯងទៀត ។ តែ ឆិល ចាត់ទុកថាក៏ជាសំណាងរបស់គាត់ដែរ ដែលនៅមានជីវិតរស់នៅជួបជុំគ្រួសាររហូតដល់បច្ចុប្បន្ននេះ ។

**សាំង ចុង**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

**(តពីលេខមុន)**

*ជំពូក៧ សំណួរទាក់ទងនឹងអំពើភេរវកម្ម*

ជំពូកនេះពិនិត្យមើលលើអំពើភេរវកម្មអ៊ីស្លាមនៅកម្ពុជា ។ ជំពូកនេះមានគោលបំណងឆ្លើយតបទៅនឹងសំណួរថាតើជនជាតិចាមបានប្រព្រឹត្តឬចូលរួមក្នុងសកម្មភាពភេរវកម្មអ៊ីស្លាមដែរឬទេ ជាពិសេសទំនាក់ទំនងជាមួយអង្គការភេរវកម្មថ្នាក់តំបន់ និងសកលលោក ។ ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ ជំពូកនេះនឹងត្រឡប់ទៅពិនិត្យមើលទៅលើផលប៉ះពាល់នៃការវាយប្រហារភេរវកម្មថ្ងៃទី១១ កញ្ញា នៅសហរដ្ឋអាមេរិក និងផលប៉ះពាល់នៃការវាយប្រហារនេះមកលើជនជាតិចាម ព្រមទាំងការផ្ទុះគ្រាប់បែកនៅកោះបាលីនៅខែតុលា ឆ្នាំ២០០២ ។ បន្ទាប់មក ជំពូកនេះនឹងផ្តើការវិភាគទៅលើផលប៉ះពាល់នៃការវាយប្រហារទាំងពីរនេះ ដែលបានចាប់ផ្តើមពីចម្ងាយ ហើយខិតកាន់តែជិតមកកម្ពុជា មកលើប្រជាជនចាម និងរូបភាពរបស់ជនជាតិចាមនៅប្រទេសកម្ពុជា និងប្រទេសថៃ ។ ជំពូកនេះក៏នឹងពិនិត្យមើលតួនាទីរបស់ជនជាតិចាមនៅក្នុងជម្លោះនៅប្រទេសថៃភាគខាងត្បូងនិងពន្យល់ពីមូលហេតុដែលជនជាតិចាមជាប់ទាក់ទងទៅនឹងអំពើហិង្សានៅតំបន់នោះ ។

### ១) សេចក្តីផ្តើម

ដូចដែលបានបង្ហាញពីខាងលើ ជនជាតិចាមទទួលរងគ្រោះពីអំពើប្រល័យពូជសាសន៍នៅក្រោមរបបខ្មែរក្រហម ។ នៅឆ្នាំ ១៩៧៩ មាន អ៊ីមាំ តែ២០ នាក់ប៉ុណ្ណោះដែលរួចផុតពីសេចក្តីស្លាប់ក្នុងចំណោម អ៊ីមាំ ១០០ នាក់ នៅឆ្នាំ១៩៧៥ ។ ជនជាតិចាមដែលរស់រានមានជីវិតពីរបបខ្មែរក្រហម គ្មានទស្សនៈច្បាស់លាស់អំពីអត្តសញ្ញាណនិងការប្រណិបតន៍និកាយសាសនារបស់ខ្លួននោះ



ជនជាតិចាមដែលនៅរស់ជីវិតពីរបបខ្មែរក្រហម ជួបជុំគ្នានៅវិហារ ក្នុងសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ

ទេ ។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មក ជនជាតិចាមបានព្យាយាមធ្វើការកសាងអត្តសញ្ញាណខ្លួនឡើងវិញ ។ ដោយសារមូលហេតុនេះ ជនជាតិចាមបើកចំហទទួលយកឥទ្ធិពលពីសហគមន៍មូស្លីមសកលលោកយ៉ាងច្រើនលើសលប់ ។ នៅក្នុងកិច្ចសម្ភាសន៍មួយជាមួយកាសែតញូយ៉កថែមស៍ នរវិទូ ប្ជន ប្លិងស្លី (Bjorn Blengsli) បាននិយាយថា ៖

ប្រទេសនេះដល់ពេលវេលាដែលត្រូវផ្សព្វផ្សាយសាសនាអ៊ីស្លាមឡើងវិញហើយ ។ ប្រទេសនេះត្រូវតែចាប់ផ្ដើមសាឡើងវិញទាំងអស់ ។ ក្រុមនេះគ្មានអ្នកដឹកនាំសាសនា គ្មានអ៊ីទាំងអស់ ។ មូស្លីមបាត់បង់អ្វីៗស្ទើរតែទាំងអស់ៈ គម្ពីរ ពិធីបុណ្យសាសនា និងសំណេរផ្សេងៗ ។ មូស្លីមនៅសល់តែរឿងព្រេងមួយចំនួនប៉ុណ្ណោះ ។ ហេតុនេះហើយទើបធ្វើឲ្យចលនាវិសុទ្ធកម្មសព្វថ្ងៃមានភាពងាយស្រួល ។ ក្រុមនេះមានសភាពទន់ខ្សោយ ហើយអ្នកដែលមកប្រទេសកម្ពុជាភាគច្រើនប្រាប់ក្រុមនេះឲ្យធ្វើការផ្លាស់ប្ដូរតាមដែលខ្លួនចង់បាន ។

ការស្វែងរកអត្តសញ្ញាណថ្មី ចំណេះដឹងថ្មីនៃការប្រតិបត្តិសាសនា និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍន៍សហគមន៍របស់ខ្លួន ធ្វើឲ្យជនជាតិចាមបើកទូលាយទទួលយកឥទ្ធិពលអ៊ីស្លាមបែបមូលដ្ឋានតឹងរ៉ឹង ។ ដោយថាហេតុ ឥទ្ធិពលបែបនេះត្រូវទទួលការភ័យខ្លាចថាជាឥទ្ធិពលរបស់ក្រុមភេរវកម្មអ៊ីស្លាម ។ តើជនជាតិចាមបានចូលរួមក្នុងអំពើភេរវកម្មដែរឬទេ ឬក៏គ្រាន់តែត្រូវបានចោទប្រកាន់?

ការស្ដារឡើងវិញនៃសាសនាអ៊ីស្លាមនៅកម្ពុជាត្រូវបានបែងចែកជាពីរដំណាក់កាល ។ ដំណាក់កាលទីមួយ នៅទសវត្សរ៍ឆ្នាំ១៩៩០ ពេលដែលចលនារស់ឡើងវិញចាប់ផ្ដើម យើងឃើញមានការរីកសាយភាយ និងការកំណត់ដំណាក់កាលសម្រាប់ទសវត្សរ៍បន្ទាប់មកទៀត ។ ដំណាក់កាលទីពីរ គិតចាប់ពីឆ្នាំ ២០០១ទៅដល់ឆ្នាំ២០១០ ជាអំឡុងពេលដែលមានភាពជ្រួលច្របល់សម្រាប់ជនជាតិចាម ដោយសារតែជនជាតិចាមត្រូវទទួលរងការចោទប្រកាន់ថាជាប់ពាក់ព័ន្ធទៅនឹងក្រុមជ្រុលនិយមនិងអំពើភេរវកម្ម ។ អំឡុងពេលនេះ ឃើញមានការវាយប្រហារលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក និងមន្ទីរប៉ង់តាហ្គោន នៅសហរដ្ឋអាមេរិក ការផ្ទុះគ្រាប់បែកនៅកោះបាលីឆ្នាំ២០០២ និងការលេចឡើង និងការធ្លាក់ចុះនៃក្រុមបះបោរថៃខាងត្បូង ព្រមទាំងព្រឹត្តិការណ៍ដែល «ទាក់ទងនឹងអំពើភេរវកម្ម» នៅប្រទេសកម្ពុជា ។ បន្ទាប់ពី ដំណាក់កាលទីពីរកន្លងផុតទៅ សហគមន៍មូស្លីមមានស្ថេរភាពជាងមុន ដោយយើងឃើញមានការធ្លាក់ចុះនូវជម្លោះផ្ទៃក្នុង កាត់បន្ថយការភ័យខ្លាចអំពើភេរវកម្ម និងមានឆន្ទៈក្នុងការរួមរស់នឹងគ្នារវាង ក្រុមតាប្លីហ្គីចាម៉ាត់ និង ក្រុមសាឡាហ្វី ។

## ២) ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ វេលាម៉ោង៩យប់ ម៉ោងនៅប្រទេសកម្ពុជា សេី សាយព្យាណា អាយុ២១ឆ្នាំ កំពុងនៅភ្នំពេញមើលអ្នកសារព័ត៌មាន ហ្សាន់ ប៉ូឡា (Paula Zhan) ផ្សាយបន្តផ្ទាល់ពីទូរទស្សន៍ស៊ីអិនអិន (CNN) អំពីព្រឹត្តិការណ៍អគារពាណិជ្ជកម្មពិភពលោកបុកឆេះដោយយន្តហោះដឹកអ្នកដំណើរមួយ ធ្វើឲ្យអគារនេះដួលរលំក្នុងរយៈពេល៣០នាទី ដែលបង្កឲ្យមានផ្សែងខ្មៅក្រាស់គ្របដណ្ដប់ពេញទាំងសង្កាត់ម៉ាន់ហាថាន់ផ្នែកខាងក្រោម (Lower Manhathan) ។ ទោះបីជាទីក្រុងញូវយ៉ក នៅឆ្ងាយពីកន្លែងដែល សាយព្យាណា រស់នៅក្ដី ទិដ្ឋភាពនៅលើទូរទស្សន៍គឺស្ទើរតែមិនគួរឲ្យជឿ ។ នៅកន្លែងផ្សេងទៀតនៅសហរដ្ឋអាមេរិក យន្តហោះដឹកអ្នកដំណើរពីរគ្រឿង បានហោះទៅបុកលើដី និងទីបញ្ជាការដ្ឋានកងទ័ពអាមេរិក មន្ទីរប៉ង់តាហ្គោន ។ ដូចអ្នកតាមដានព្រឹត្តិការណ៍នៅលើទូរទស្សន៍ផ្សេងទៀតដែរ សាយព្យាណា រន្ធត់ចិត្តយ៉ាងខ្លាំង នៅពេលឃើញព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងពេលដំណាលគ្នា ។ សហរដ្ឋអាមេរិកបានធ្លាក់ចូលទៅក្នុងស្ថានភាពវឹកវរជ្រួលច្របល់ ហើយមនុស្សរាប់ពាន់នាក់បានស្លាប់ក្នុងព្រឹត្តិការណ៍នេះ ។ សិក្សាថ្នាក់បរិញ្ញាប័ត្រនៅសកលវិទ្យាល័យជាតិគ្រប់គ្រង សាយព្យាណា ជាជនជាតិចាមម្នាក់ក្នុងចំណោមជនជាតិចាមមួយចំនួនតូចនៅក្នុងប្រទេសកម្ពុជាដែលមានឱកាសសិក្សាដល់ថ្នាក់បរិញ្ញាប័ត្រ ។ សម្រាប់ សាយព្យាណា ទីក្រុងញូវយ៉ក ជាឈ្មោះដែលនាងធ្លាប់ឮ ទោះជានាងមិនដែលបានទៅដល់ទីនោះក៏ដោយ ។ ក្នុងនាមជានិស្សិតថ្នាក់មហាវិទ្យាល័យ សាយព្យាណា បានដឹងខ្លះៗពីបញ្ហា និងកិច្ចការនៅជុំវិញសកលលោក ។ ព័ត៌មានទាក់ទងនឹងព្រឹត្តិការណ៍សកលលោក មិនងាយនឹងទៅដល់ជនជាតិចាមដែលភាគច្រើនរស់នៅតាមជនបទនោះទេ ។

សាយព្យាណា នៅមានចម្ងល់នៅក្នុងខួរក្បាល តើនរណាជា

អ្នកប្រព្រឹត្តរឿងនេះនិងហេតុអ្វី? ពីរបីថ្ងៃក្រោយមក សាយ្យាណា បានឃើញព័ត៌មានដែលរាយការណ៍ថា ក្រុមមួយមានឈ្មោះថា អាល់កៃដា *(Al Qaeda)* គឺជាអ្នកទទួលខុសត្រូវក្នុងព្រឹត្តការណ៍វាយប្រហារនេះ ហើយមេក្រុមនេះមានឈ្មោះថា អូសាម៉ា ប៊ិនឡាដេន *(Osama Bin Laden)* ។ ក្រុមនេះត្រូវបានស្គាល់ថា ជាក្រុមភេរវកម្មអ៊ីស្លាមដែលប្រើប្រាស់សាសនាអ៊ីស្លាមធ្វើជាមនោគមវិជ្ជានយោបាយ ដើម្បីប្រមូលការគាំទ្របុព្វហេតុរបស់ខ្លួន និងដើម្បីជ្រើសរើសសមាជិកមូស្លីមចូលបម្រើក្នុងអំពើភេរវកម្ម ។ អូសាម៉ា ប៊ិនឡាដេន មានមូលដ្ឋាននៅប្រទេសអាហ្គានីស្ថាន ទីតាំងដែលក្រុមអាល់កៃដាត្រូវបានជួយលាក់បំពួនដោយក្រុមប្រដាប់អាវុធអ៊ីស្លាមជ្រុលនិយមមួយទៀតឈ្មោះថា តាលីបាន *(Taliban)* ដែលបានគ្រប់គ្រងប្រទេសអាហ្គានីស្ថានកាលពីប្រាំពីរឆ្នាំមុន ។ ព្រឹត្តិការណ៍ទាំងអស់នេះហាក់ដូចជានៅឆ្ងាយ ហើយមិនទាក់ទងនឹងប្រទេសកម្ពុជា ជាពិសេសជាមួយជនជាតិចាមដែលរស់នៅតំបន់ជនបទ ។ សាយ្យាណា មិននឹកស្មានថា អ្វីដែលនាងបានឃើញនៅលើទូរទស្សន៍កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ បង្កឲ្យមាចលាចលមកដល់សហគមន៍នាង នៅពេលក្រោយមកទៀតនោះទេ ។

នៅឆ្នាំ២០០១ ចលនារស់ឡើងវិញនៃសាសនាអ៊ីស្លាមមានសន្ទុះខ្លាំងក្លានៅកម្ពុជា ។ សន្ទុះនេះគ្មានទិសដៅ និងការគ្រប់គ្រងច្បាស់លាស់ ។ ថ្នាក់ដឹកនាំជនជាតិចាមគ្មានគោលនយោបាយច្បាស់លាស់ដើម្បីគ្រប់គ្រងប្រភេទ និងនិកាយអង្គការសប្បុរសធម៌មូស្លីមដែលចូលមកប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាមើលទៅពួកបរទេសថាជាមនុស្សល្អមានចិត្តសប្បុរសរួមចំណែកជួយក្នុងការកសាងសង្គមតាមរយៈការនាំចូលមកនូវចំណេះដឹង និងជំនួយផ្សេងៗ ។ ហេតុនេះ គ្រូបង្រៀនជនជាតិមូស្លីមមកពីបរទេសច្រើនមើលឃើញថា ជាមនុស្សសន្តិភាពនិងមានចំណេះដឹងក្នុងសាសនាអ៊ីស្លាមហើយពេលខ្លះអ្នកទាំងអស់នោះគឺជាប្រភពធនធាន ។ ជនជាតិចាមស្វាគមន៍អ្នកទាំងអស់នោះគ្រប់ពេលវេលា និងពីគ្រប់ទីកន្លែងទាំងអស់ ។ គ្រូបង្រៀនមូស្លីមបរទេសទាំងអស់នេះ អាចចូលក្នុងប្រទេស និងធ្វើដំណើរពីសហគមន៍ចាមមួយទៅសហគមន៍មួយទៀតដោយសេរី ដើម្បីផ្សព្វផ្សាយសាសនាអ៊ីស្លាម ។

ក្រោយព្រឹត្តិការណ៍ថ្ងៃ១១ ខែកញ្ញា ក្តីព្រួយបារម្ភបានចាប់ផ្តើមឡើង ។ អត្ថបទសារព័ត៌មានមួយចំនួន ចាប់ផ្តើមធ្វើការរិះគន់អំពីការស្តារឡើងវិញនូវសាសនាអ៊ីស្លាមរបស់ជនជាតិចាម ដោយគ្មានគោលដៅច្បាស់លាស់ ក្រោយពីឆ្លងកាត់សង្គ្រាមស៊ីវិលអស់ជាច្រើនឆ្នាំ ។ ជនជាតិចាមយល់ពីទស្សនៈរបស់ខ្មែរពុទ្ធសាសនិកភាគច្រើនមកលើខ្លួន ហើយព្រឹត្តិការណ៍ថ្មីៗនេះធ្វើឲ្យខ្មែរមានទស្សនៈចង្អៀតចង្អល់កាន់តែស៊ីជម្រៅមកលើជនជាតិចាម ក្នុងនោះរួមមានការព្រួយបារម្ភ ការរើសអើង និងកង្វះខាតការយោគយល់គ្នា ។ ជនជាតិចាមចាមផ្តើមឆក់យកគ្រប់ឱកាសដែលខ្លួនមាន ដើម្បីបំបែកខ្លួនចេញពីក្រុមភេរវកម្ម ដោយធ្វើការថ្កោលទោសក្រុមភេរវកម្មចូលរួមជាមួយក្រុមជនជាតិមូស្លីមបរទេសប្រឆាំងនឹងក្រុមភេរវកម្ម សម្តែងការអាណិតអាសូរជនជាតិមូស្លីមដែលត្រូវបានចាប់ខ្លួននៅក្នុងសង្គ្រាមប្រឆាំងនឹងអំពើភេរវកម្មនៅសហរដ្ឋអាមេរិក និងស្វែងរកការទុកចិត្តពីរដ្ឋាភិបាលនូវភាពស្មោះត្រង់របស់ខ្លួនចំពោះប្រទេសកម្ពុជា ។ ប្រធានសហគមន៍ចាមមួយចំនួន បានក្រោកឡើងបញ្ចេញគំនិតយោបល់របស់ខ្លួនទាក់ទងនឹងបញ្ហានេះ ។

អ៊ីស្មាអែល ឧស្មាន (Ismael Osman) អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា បាននិយាយថា “ខុសពីមូស្លីមនៅប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀត ជនជាតិចាមនៅកម្ពុជានឹងមិនធ្វើការតវ៉ាជំទាស់ទៅនឹងវិធានការយោធាដឹកនាំដោយសហរដ្ឋអាមេរិកប្រឆាំងនឹងក្រុមភេរវកម្ម និងក្រុមដែលផ្តល់ការជ្រកកោនដល់ពួកភេរវករទេ ។ យើងចាំបាច់ត្រូវតែរកមធ្យោបាយពន្យល់ប្រជាជនមូស្លីមនៅកម្ពុជាឲ្យយល់ថា សហរដ្ឋអាមេរិកស្វែងរកតែក្រុមភេរវកម្មអន្តរជាតិ មិនមែនអ្នកកាន់សាសនាអ៊ីស្លាមទាំងអស់នោះទេ” ។ អាម៉ាត់ យ៉ះយា *(Ahmad Yahya)* និយាយថា “បញ្ហានេះមិនគួរជាប់ពាក់ព័ន្ធទៅនឹងប្រជាជនអ៊ីស្លាមនៅកម្ពុជានោះទេ ។ ប្រសិនបើសហរដ្ឋអាមេរិកប្រយុទ្ធ នោះការប្រយុទ្ធនឹងស្ថិតនៅប្រទេសអាហ្គានីស្ថាន មិនមែននៅកម្ពុជានោះទេ” ។ ឧស្មាន ហាសាន់ *(Osman Hassan)* និយាយថា “ជនជាតិចាមសព្វថ្ងៃ ផ្តោតទៅលើបញ្ហាឲ្យកូនចៅរៀនសូត្រ និងការធ្វើជំនួញ ជាជាងចូលរួមសកម្មភាពជាមួយនយោបាយ ។ រីឯអ្នកដែលរស់នៅតំបន់ជនបទភាគច្រើនមិនទាំងដឹងពីព្រឹត្តិការណ៍អន្តរជាតិផង” ។

បន្ទាប់ពីសហរដ្ឋអាមេរិក ចាប់ផ្តើមធ្វើសង្គ្រាមនៅអាហ្គានី

ស្ថាន និងសង្គ្រាមប្រឆាំងនឹងអំពើភេរវកម្មទូទៅមក ក្រុមមូស្លីមមួយចំនួននៅអាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងៗទៀត បានធ្វើការតវ៉ាប្រឆាំងនឹងការវាយប្រហារទៅលើជនជាតិអាហ្គានីស្ថាន និងប្រឆាំងនឹងសង្គ្រាមដែលគេជឿជាក់ថា ជាសង្គ្រាមប្រឆាំងនឹងអ្នកកាន់សាសនាអ៊ីស្លាម ។ ប៉ុន្តែជនជាតិចាមនៅរក្សាភាពស្ងៀមស្ងាត់ ។ គ្មានការប្រមូលផ្តុំណាមួយធ្វើឡើងប្រឆាំងនឹងសហរដ្ឋអាមេរិកនោះទេ ។

សុះ កាំរី (Soh Kamry) ដែលជាចាងហ្វាងនៃគណៈចាងហ្វាងជាន់ខ្ពស់នៃសាសនាអ៊ីស្លាមនៅកម្ពុជា បានគូសបញ្ជាក់ថា "ខ្ញុំគិតថាខ្មែរមូស្លីមសុខចិត្តរស់នៅដោយសន្តិភាព ជាជាងបង្កើតនូវបញ្ហាដោយសារតែគាត់ក្រីក្រ ហើយចំណេះដឹងនៅមានកម្រិតទាបមិនទាន់អាចយល់ពីបញ្ហាពិភពលោក" ។ ចំណុចនេះហាក់ដូចជាមិនសូវទំនងនៅពេលដែលយើងសង្កេតឃើញថា ជនជាតិចាមមិនមានសកម្មភាពនិងមតិយោបល់ទាក់ទងនឹងបញ្ហានេះ ខណៈដែលខ្លួនត្រូវបានជឿជាក់ថា បានទទួលនូវការឧបត្ថម្ភយ៉ាងច្រើនពីស្ថាប័នមូស្លីមអន្តរជាតិ ហើយនឹងក្រុមភ្នាក់ងាររដ្ឋាភិបាលប្រទេសអ៊ីស្លាម ។ ប្រសិនបើជនជាតិចាម មានទំនាក់ទំនងជិតដិតជាមួយនឹងអ៊ីស្លាមនៅលើសកលលោក ជនជាតិចាមគួរតែមានភាពសកម្មជាងនេះក្នុងការបញ្ចេញក្តីព្រួយបារម្ភរបស់ខ្លួនប្រឆាំងនឹងសកម្មភាពយោធារបស់សហរដ្ឋអាមេរិក ។

នៅពេលសហរដ្ឋអាមេរិក និងក្រុមសម្ព័ន្ធមិត្តលោកខាងលិចចាប់ផ្តើមធ្វើសង្គ្រាមនៅអាហ្គានីស្ថាន នៅដើមខែតុលា ឆ្នាំ ២០០១ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដាក់ចុះនូវជំហរមួយច្បាស់លាស់របស់រដ្ឋាភិបាលកម្ពុជាចំពោះបញ្ហានេះ ។ គាត់ក៏បានបែងចែកមូស្លីមនៅកម្ពុជាឲ្យខុសពីក្រុមភេរវកម្មអ៊ីស្លាម ដោយធ្វើការថ្កោលទោសព្រឹត្តិការណ៍វាយប្រហារថ្ងៃ១១ កញ្ញា និងស្ម័គ្រចិត្តផ្តល់នូវការគាំទ្រផ្នែកស្មារតីចំពោះការធ្វើសង្គ្រាមនេះ ។ ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗក្នុងសន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី៖

◆ គាំទ្រការវាយប្រហារប្រឆាំងនឹងប្រទេសអាហ្គានីស្ថាន ដឹកនាំដោយសហរដ្ឋអាមេរិក

◆ គាំទ្រវិធានការប្រឆាំងនឹងអំពើភេរវកម្មជាទូទៅ

◆ មានឆន្ទៈក្នុងការផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដោះគ្រាប់មិនទាន់ផ្ទុះទៅដល់រដ្ឋាភិបាលកាប៊ុល

◆ អំពើភេរវកម្មមិនមែនសាសនាអ៊ីស្លាម សាសនាគ្រីស្ត ឬសាសនាព្រះពុទ្ធនោះទេ ។

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០១ ក្រសួងមហាផ្ទៃបានហាមឃាត់ការពាក់អាវយឺតដែលមានរូបភាព ប៊ិនឡាដេន ដោយលើកឡើងថា ការហាមឃាត់នេះគឺស្របទៅនឹងគោលនយោបាយប្រឆាំងអំពើភេរវកម្មរបស់កម្ពុជា ហើយការពាក់អាវយឺតបែបនេះជំរុញឲ្យមានភេរវករ ។ អាវយឺតទាំងអស់នេះ ដែលបាននាំចូលមកពីប្រទេសថៃ ត្រូវបានដកហូតចេញពីហាងសម្លៀកបំពាក់ និងហាងលក់វត្ថុអនុស្សាវរីយ៍ ។ គ្មានការចោទប្រកាន់ព្រហ្មទណ្ឌណាមួយត្រូវបានធ្វើឡើងប្រឆាំងនឹងម្ចាស់លក់ទំនិញទេ ។ មូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងៗទៀតគឺថា ប្រទេសកម្ពុជាព្យាយាមបង្ហាញនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះរដ្ឋាភិបាលអាមេរិកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ។ នេះជាបញ្ហាមួយក្នុងចំណោមបញ្ហាមួយចំនួនតូចប៉ុណ្ណោះដែលរដ្ឋាភិបាលទាំងពីរយល់ស្របគ្នា ។ ការគាំទ្របែបនេះមានប្រយោជន៍ចំពោះកម្ពុជា ពេលដែលជនជាតិចាមនិងមូស្លីមអន្តរជាតិត្រូវបានចាប់ខ្លួននៅកម្ពុជា នៅឆ្នាំ២០០៣ ហើយសហរដ្ឋអាមេរិកបានអនុវត្តនូវគោលនយោបាយ (Persistent



ជនជាតិចាមជួបជុំធ្វើសំពះយ៉ាង នៅវិហារ

*presence)* ជាមួយជនជាតិចាម ។ ទន្ទឹមគ្នានឹងគាំទ្រសហរដ្ឋអាមេរិក រាជរដ្ឋាភិបាលកម្ពុជាមានការប្រុងប្រយ័ត្នមិនធ្វើឲ្យសហគមន៍ចាមមានការថ្នាក់ថ្នាំងចិត្តដោយប្រការណាមួយឡើយ ។

ដោយមានកង្វះខាតផ្នែកទំនាក់ទំនង ក្រសួងធម្មការ និងសាសនា បានចាត់វិធានការណ៍យ៉ាងតឹងរ៉ឹងប្រឆាំងនឹងជនជាតិចាម និងក្រុមមូស្លីមបរទេស ។ នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០១ ក្រសួងបានប្រកាសសារាចរណែនាំដាក់ចុះនូវបម្រាមសំខាន់ៗ ផ្សេងៗ ប្រឆាំងនឹងជនជាតិចាម ។ សារសំខាន់ទាក់ទងនឹងច្បាប់នេះមានដូចតទៅ ៖

◆ សុំការអនុញ្ញាតពីរដ្ឋាភិបាលនៅពេលមានជំនួបជាមួយមូស្លីមបរទេស

◆ សុំការអនុញ្ញាតពីរដ្ឋាភិបាលនៅពេលរៀបចំពិធីបុណ្យសាសនាផ្សេងៗ

◆ ជនជាតិចាមមិនត្រូវសំណូមពរអ្វីដែលអាចនាំឲ្យខូចដល់សណ្តាប់ធ្នាប់សង្គម និងសាធារណៈ

◆ ជនជាតិចាមមិនត្រូវបានអនុញ្ញាតឲ្យផ្តល់ការជ្រកកោន និងសហការជាមួយមូស្លីមបរទេសដែលដើរផ្សព្វផ្សាយសាសនា

◆ ជនជាតិចាមមិនត្រូវបានអនុញ្ញាតឲ្យជួយមូស្លីមបរទេសដែលសង្ស័យថា ជាប់ពាក់ព័ន្ធទៅនឹងក្រុមភេរវកម្ម

◆ ជនជាតិចាមត្រូវបានហាមឃាត់មិនឲ្យប្រើប្រាស់វិហារអ៊ីស្លាមធ្វើជាទីកន្លែងដើម្បីប្រមូលផ្តុំពិភាក្សារឿងនយោបាយ

◆ ការិយាល័យរបស់មូស្លីមបរទេសគួរដាក់តែទង់ជាតិកម្ពុជាតែមួយប៉ុណ្ណោះ ។

គោលបំណងមួយរបស់សារាចរនេះគឺដើម្បីទប់ស្កាត់ជនជាតិចាមមិនឲ្យមានការប្រមូលផ្តុំណាមួយប្រឆាំងនឹងសហរដ្ឋអាមេរិក ។ មានការរាយការណ៍ថា មន្ត្រីស្ថានទូតអាមេរិកបានជួបជាមួយឯកឧត្តម ជា សារឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា មុនពេលសារាចរនេះត្រូវបានប្រកាសឲ្យប្រើប្រាស់ ។ ទោះជាយ៉ាងនេះក៏ដោយគ្មានការអះអាងច្បាស់លាស់ថា ក្រសួងធម្មការ និងសាសនាបានទទួលការណែនាំពីមន្ត្រីស្ថានទូតប៉ុណ្ណោះទេ ។ ការដាក់ចុះនូវការណែនាំនេះ ហាក់ដូចជាធ្វើឡើងយ៉ាងឆាប់រហ័ស ហើយហាក់ដូចជាមិនទាន់បានពិភាក្សាជាមួយការិយាល័យគណៈរដ្ឋមន្ត្រីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលធ្លាប់តែគាំទ្រដល់ការអភិវឌ្ឍន៍របស់ជនជាតិចាម និងបានមានជំហរវិជ្ជមានចំពោះជនជាតិចាមនោះទេ ។

មានកំណើតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយម្ខាងទន្លេមេគង្គនៃស្រុកក្រូចឆ្មារ ជាស្រុកដែលមានជនជាតិចាមរស់នៅច្រើន លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តែងមានទំនាក់ទំនងជិតដិតនឹងជនជាតិចាម ។ លោកនាយករដ្ឋមន្ត្រីយល់ថា ព្រឹត្តិការណ៍ថ្ងៃ១១ កញ្ញា គឺជាបន្ទុកមួយទៅលើជនជាតិចាម ហើយច្បាប់ដែលបានបង្កើតឡើងបង្កើតឲ្យមានសម្ពាធមិនសមហេតុផលទៅលើជនជាតិចាម ។ លោកនាយករដ្ឋមន្ត្រីបានដកសារាចរនោះចេញនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០០១ ។

លោក ហ៊ុន សែន បាននិយាយថា “ជនជាតិមូស្លីមនៅប្រទេសនានាកំពុងតែធ្វើបាតុកម្មនៅមុខស្ថានទូតអាមេរិក ។ ទោះជានៅប្រទេសថៃក៏មានបាតុកម្មរបស់ក្រុមមូស្លីមដែរ ។ នៅប្រទេសកម្ពុជា គ្មានការធ្វើបាតុកម្មបែបនេះកើតឡើងទេ ។ ហេតុនេះ វាមិនសមហេតុផលដែលត្រូវធ្វើរឿងនេះឲ្យធំឡើយ ។ ព្រឹត្តិការណ៍ដែលបានកើតឡើងនៅកន្លែងផ្សេងសោះ យើងបែរជាដាក់សម្ពាធមកលើជនជាតិចាមនៅកម្ពុជា ដែលបានរងគ្រោះយ៉ាងធ្ងន់ធ្ងរពីរបប ប៉ុល ពត” ។ លោក ហ៊ុន សែន ស្នើថា គ្មានការចាំបាច់ណាមួយដែលត្រូវហាមឃាត់ជនជាតិចាមមិនឲ្យធ្វើការជួបប្រជុំប្រមូលផ្តុំនៅកម្ពុជានោះទេ ។ ប៉ុន្តែ លោក ហ៊ុន សែន ជឿថា សារាចរនេះដែលដាក់កម្រិតទៅលើសាសនាអ៊ីស្លាម និងអ្នកកាន់សាសនាអ៊ីស្លាមអាចបង្កឲ្យមានការធ្វើបាតុកម្ម ។ គាត់និយាយថា “ជនជាតិមូស្លីមនៅតំបន់ខ្លះមានការព្រួយបារម្ភថា សារាចរនេះជាគោលនយោបាយរបស់រដ្ឋាភិបាល និងជាគោលនយោបាយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ រឿងនេះគ្រោះថ្នាក់ណាស់ ។ ខ្ញុំរំពឹងថា នឹងមានបាតុកម្មកើតឡើងនៅទីក្រុងភ្នំពេញ ក្នុងពេលឆាប់ៗនេះ ។ ដូច្នេះខ្ញុំត្រូវតែដកសារាចរណែនាំនេះចេញ” ។ ទោះបីជាលោកមានជំហររឹងមាំប្រឆាំងនឹងអំពើភេរវកម្ម លោក ហ៊ុន សែន បញ្ជាក់ថា គោលនយោបាយរបស់លោកមិនមែនមានន័យថារដ្ឋាភិបាលរបស់លោកប្រឆាំងនឹងប្រជាជនចាមនោះទេ ។ លោក ហ៊ុន សែន សង្កត់ធ្ងន់ថា “សូមកុំបញ្ចូលមូស្លីមនៅកម្ពុជាចូលទៅក្នុងកញ្ចប់តែមួយ

ជាមួយមូស្លីមនៅប្រទេសផ្សេងៗ ។ ការគាំទ្ររបស់យើងប្រឆាំងនឹងអំពើភេរវកម្មមិនមែនមានន័យថាជាការប្រឆាំងនឹងជាតិសាសន៍ ឬសាសនាណាមួយឡើយ» ។ មន្ត្រីរដ្ឋាភិបាលផ្សេងទៀតបានធ្វើការដកស្រង់សម្តីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីដាក់សារាចរ ដោយក្រសួងធម្មការ និងសាសនានេះជាមោឃៈ៖

◆ សេចក្តីថ្លែងការណ៍នេះមិនស្របគ្នាទៅនឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះក្រុមជាតិពន្ធុភាគតិចនៅកម្ពុជា

◆ ជនជាតិចាមបានរួមរស់ជាមួយសង្គមកម្ពុជាយ៉ាងពេញទំហឹង

◆ គ្មានមូលហេតុណាមួយដែលជនជាតិចាមធ្វើការគាំទ្រដល់អំពើភេរវកម្មអន្តរជាតិ ហើយជនជាតិចាមគ្រាន់តែសុំរស់នៅដោយសន្តិភាព

◆ រាជរដ្ឋាភិបាលកម្ពុជាមិនប្រឆាំងនឹងសកម្មភាពសាសនាផ្សេងៗ

◆ សេចក្តីថ្លែងការណ៍នេះអាចធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ទំនាក់ទំនងកម្ពុជាជាមួយប្រទេសមូស្លីមផ្សេងៗទៀត

◆ សេចក្តីថ្លែងការណ៍នេះមិនគោរពតាមរដ្ឋធម្មនុញ្ញ និងជាការរំលោភលើសេរីភាពក្នុងការបញ្ចេញមតិ

◆ សេចក្តីថ្លែងការណ៍នេះជាការដាក់សម្ពាធលើជនរួមជាតិមូស្លីម

### ៣) ការផ្ទុះគ្រាប់បែកនៅកោះបាលី និងអង្គការ អ៊ុំ អាល់ គូរ៉ា (Om al-Quara)

ព្រឹត្តិការណ៍ថ្ងៃ១១ កញ្ញា ធ្វើឲ្យជនជាតិចាមក្លាយជាចំណុចផ្តោតក្នុងចំណាប់អារម្មណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើភេរវកម្មសកលលោក និងដោយប្រតិកម្មរបស់ជនជាតិចាម ។ ព្រឹត្តិការណ៍នេះក៏ធ្វើឲ្យចាមក្លាយជាប្រធានបទនៃការពិភាក្សាក្នុងចំណោមប្រជាជនកម្ពុជាជាទូទៅ ។ ការផ្ទុះគ្រាប់បែកនៅកោះបាលីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០២ នៅប្រទេសឥណ្ឌូនេស៊ី ដែលបានសម្លាប់ភ្ញៀវទេសចរណ៍អស់ជាង២០២នាក់ នាំឲ្យក្រុមជ្រុលនិយម និងក្រុមភេរវកម្មអ៊ីស្លាមពិភពលោក ខិតចូលមកកាន់តែជិតកម្ពុជា ។ កត្តានេះមានផលប៉ះពាល់ទៅលើជនជាតិចាមខ្លាំងជាងព្រឹត្តិការណ៍ថ្ងៃ១១កញ្ញា ។ នៅខែកញ្ញា ឆ្នាំ២០០២ បន្ទាប់ពីទទួលបានរបាយការណ៍ភ្នាក់ងារសម្ងាត់ពីក្រុមភេរវករអាស៊ីដែលកំពុងជាប់ឃុំឃាំង និងសួរចម្លើយមកថា ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសដទៃទៀតដែលជាគោលដៅវាយប្រហារអំពើភេរវកម្ម ស្ថានទូតសហរដ្ឋអាមេរិក អង់គ្លេស និងអូស្ត្រាលី បានបិទទ្វាររយៈពេលពីរសប្តាហ៍ និងបានពង្រឹងសន្តិសុខបន្ទាប់ពីបើកឡើងវិញ ។ ការផ្ទុះគ្រាប់បែកនៅបាលីបញ្ជាក់កាន់តែច្បាស់ថា របាយការណ៍នេះពិតជាត្រឹមត្រូវ ។

ក្រោយមក ជនជាតិចាមបានជួយរំលែកទុក្ខជាមួយក្រុមគ្រួសារជនរងគ្រោះដែលបានស្លាប់ក្នុងព្រឹត្តិការណ៍ផ្ទុះគ្រាប់បែកនោះ ។ មួយសប្តាហ៍បន្ទាប់ពីការផ្ទុះគ្រាប់បែក ជនជាតិចាមពីរបីរយនាក់បានធ្វើការជួបជុំគ្នាធ្វើពិធីថ្វាយបង្គំថ្ងៃសុក្រនៅវិហារអ៊ីស្លាម ណូរុល អេស្សាណ (Norul Eshan) នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ អ្នកថ្វាយបង្គំបានសូត្រឧទ្ទិសដល់ជនរងគ្រោះក្នុងព្រឹត្តិការណ៍ផ្ទុះគ្រាប់បែក ហើយអ្នកចូលរួមក្នុងពិធីថ្វាយបង្គំបានសុំព្រះអល់ឡោះឲ្យជួយក្រុមគ្រួសារជនរងគ្រោះក្នុងអំឡុងពេលកាន់ទុក្ខនេះ ។ នៅពេលជាមួយគ្នានោះ ចាមបានឆ្លៀតឱកាសនេះ បំបែកខ្លួនចេញ និងធ្វើការថ្កោលទោសក្រុមភេរវករ ។ មូហាម៉ាត់ អាលី មូសាដ (Mohammad Ali Musad) អ្នកស្រុកចាមម្នាក់នៅខណ្ឌឫស្សីកែវ និងធ្លាប់បានធ្វើធម្មយាត្រាទៅទីក្រុងម៉ាកាសពីរដងបាននិយាយថា «សាសនាអ៊ីស្លាមមិនអនុញ្ញាតឲ្យក្រុមនោះធ្វើដូច្នេះឡើយ ។ ទោះជាក្រុមភេរវករជាមូស្លីមដូចយើង ក៏យើងមិនគាំទ្រក្រុមនោះដែរ ។ ក្រុមមូស្លីមនេះប្រើប្រាស់សាសនាអ៊ីស្លាមដើម្បីបង្កជាសោកនាដកម្ម សម្លាប់មនុស្ស ធ្វើឲ្យមានការជ្រួលច្របល់ក្នុងពិភពលោក ។ យើងមិនគាំទ្រពួកនេះឡើយ» ។ ក្រោយពីសហរដ្ឋអាមេរិកចាប់ផ្តើមប្រតិបត្តិការ បេសកកម្មសេរីភាពអ៊ីរ៉ាក់ ជនជាតិចាមក៏ធ្វើដូចគ្នានេះដែរ ។ ជនជាតិចាមប្រមាណ៣០០នាក់ បានជួបជុំគ្នានៅវិហារអ៊ីស្លាមមួយនៅភ្នំពេញដើម្បីបន់ស្រន់សុំសេចក្តីសុខដល់ជនជាតិអ៊ីរ៉ាក់ ដែលកំពុងស្ថិតនៅកណ្តាលការប្រយុទ្ធគ្នារវាងកងទ័ពអ៊ីរ៉ាក់ និងកងកម្លាំងដឹកនាំដោយសហរដ្ឋអាមេរិក ។

ទន្ទឹមនឹងនេះ ប្រទេសកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៨ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០២ ។ សំណួរចម្បងមួយបានលើកឡើងទាក់ទងនឹងសមត្ថភាពរបស់ប្រទេស

កម្ពុជាក្នុងការផ្តល់នូវការរក្សាសន្តិសុខដល់មេដឹកនាំថ្នាក់ជាតិ និង ឥស្សរៈជនជាន់ខ្ពស់មកពីប្រទេសចំនួន១៥ ។ កាលនោះ ប្រទេសកម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសដែលកង្វះខាតការគ្រប់គ្រងលើការប្រើប្រាស់អាវុធខុសច្បាប់ ព្រំដែនមានភាពធូររលុង និង បញ្ហាទាក់ទងនឹងវប្បធម៌និទណ្ឌភាព ដែលនាំឲ្យមន្ត្រីការទូតបរទេស ជឿថានឹងមានចន្លោះប្រហោងក្នុងបញ្ហាសន្តិសុខ ។ ទោះជាយ៉ាង នេះក៏ដោយ មន្ត្រីនៅកម្ពុជាខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាព ដើម្បីធានាក្រុមមន្ត្រីទូតបរទេសថា ប្រទេសកម្ពុជានឹងអាចរក្សា សន្តិសុខដល់ភ្ញៀវ និងមន្ត្រីទាំងអស់ដែលមកចូលរួមក្នុងកិច្ចប្រជុំកំពូលនេះ ។ ទោះជាមានការព្រួយបារម្ភបែបនេះក៏ដោយ មន្ត្រីនៅ កម្ពុជាតែងតែមានទំនុកចិត្តថា ខ្លួននឹងអាចផ្តល់ការរក្សាសន្តិសុខ នៅក្នុងប្រទេសបាន ។ រដ្ឋមន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង បានចេញមកបញ្ជាក់ដើម្បីបំបាត់ការភ័យខ្លាចថា "ខ្ញុំអាច ជម្រាបលោកអ្នកថា យើងខ្ញុំមានការជឿជាក់ថា នៅក្នុងកិច្ចប្រជុំ កំពូលនេះ នឹងគ្មានបញ្ហាណាមួយកើតឡើង និងគ្មានបញ្ហាទាក់ទង នឹងសន្តិសុខកើតឡើងឡើយនៅក្នុងពេលប្រជុំ" ។

កិច្ចប្រជុំកំពូលនេះ ប្រព្រឹត្តទៅយ៉ាងរលូនដោយគ្មានហេតុការណ៍ណាមួយកើតឡើងទេ ។ កិច្ចប្រជុំនេះក៏បានអនុម័តិសេចក្តីថ្លែងការណ៍ប្រឆាំងនឹងអំពើភេរវកម្មដើម្បីថ្កោលទោសការវាយប្រហារអំពើភេរវកម្ម ជាពិសេសការផ្ទុះគ្រាប់បែកនៅកោះបាលី ។

ហាំបាលី នាំមកនូវភេរវកម្មអ៊ីស្លាមពិភពលោកមកកម្ពុជា និងជនជាតិចាម យ៉ាងហោចក៏ដោយប្រយោលដែរ ។ ហាំបាលី ជាបុរសម្នាក់ដែលត្រូវបានជឿជាក់ថាជាអ្នកទទួលខុសត្រូវលើការផ្ទុះគ្រាប់បែកនៅកោះបាលី ពិតជាស្ថិតនៅក្នុងប្រទេសកម្ពុជាពេលដែលមានកិច្ចប្រជុំកំពូលមែន ។ ហាំបាលី ត្រូវបានចាប់ខ្លួននៅទីក្រុង អាយុធ្យា ប្រទេសថៃ នៅថ្ងៃទី១៤ សីហា ឆ្នាំ២០០៣ បន្ទាប់ពីបានឆ្លងព្រំដែនពីប្រទេសកម្ពុជា ។ ក្រុមភ្នាក់ងារសម្ងាត់សហរដ្ឋ អាមេរិកជឿជាក់ថា ហាំបាលី កំពុងតែលាក់ខ្លួនឬរៀបផែនការ វាយប្រហារនៅប្រទេសកម្ពុជា ដោយមានជំនួយសហប្រតិបត្តិការ ពីមូស្លីមក្នុងស្រុក និងបរទេស នៅចុងឆ្នាំ២០០២ និងដើមឆ្នាំ ២០០៣ ។ បច្ចុប្បន្ន ហាំបាលី កំពុងជាប់ពន្ធនាគារសហរដ្ឋអាមេរិក នៅខ្វាន់តាណាម៉ូ (Guantanamo) ។

ភេរវកម្មអ៊ីស្លាមបានមកដល់ប្រទេសកម្ពុជា យ៉ាងហោចណាស់ក៏ជានិមិត្តរូបដែរ នៅពេលដែលសាលារៀនសាសនា អ៊ុំ អាល់ គូរ៉ា (Om al-Qura) នៅខេត្តកណ្តាលត្រូវបានបង្ក្រាប និង បិទទ្វារនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៣ ក្រោមការចោទប្រកាន់ថាមានការទំនាក់ទំនងជាមួយនឹងក្រុមភេរវកម្ម អ៊ីស្លាម ជាពិសេស គឺក្រុម ចេម៉ាស អ៊ីស្លាមីយ៉ះ (Jemaah Islamiyah) ។ គ្រូបង្រៀនសាសនាជនជាតិថៃពីរនាក់ និងជនជាតិអេហ្ស៊ីបម្នាក់ ត្រូវបានចាប់ខ្លួនពីបទប៉ុនប៉ងប្រព្រឹត្តអំពើភេរវកម្មនៅកម្ពុជា ។ គ្រូបង្រៀនបរទេសទាំងអស់ និងក្រុមគ្រួសារនៅសាលារៀននេះ ត្រូវបានតម្រូវឲ្យចាកចេញពីប្រទេសកម្ពុជាក្នុងរយៈពេល៧២ ម៉ោង ។ គ្រូបង្រៀនជនជាតិកម្ពុជាលែងមានការងារធ្វើ ហើយកូនសិស្សទាំងអស់ត្រូវត្រឡប់ទៅផ្ទះវិញ និងព្យួរការសិក្សា ។ បន្ទាប់ពី មានការចោទប្រកាន់នេះ ក្រុម អ៊ុំ អាល់ គូរ៉ា ត្រូវបានដាក់ឲ្យនៅក្រោមច្បាប់នៅកម្ពុជា ។ ជាលទ្ធផល សាលារៀនផ្សេងៗទៀតនៅ ខេត្តកំពង់ឆ្នាំងក៏បានបិទទ្វារដែរ ។ ទ្រព្យសម្បត្តិរបស់អង្គការនេះ ត្រូវបានរឹបអូស និងប្រគល់ទៅឲ្យរដ្ឋាភិបាលកម្ពុជារង់ចាំច្បាប់ថ្មី ដើម្បីបញ្ជូនទៅដាក់កន្លែងថ្មី ។ ខុសពីសាលារៀនផ្សេងៗទៀត អ៊ុំ អាល់ គូរ៉ា ជាអង្គការសាលាហ្វីដែលមានមូលដ្ឋាននៅប្រទេសអារ៉ាប់ ។ សកម្មភាពយ៉ាងរហ័សរបស់រដ្ឋាភិបាលកម្ពុជាត្រូវបានរាយការណ៍ មកថា បានទទួលព័ត៌មានពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ។

ពីរសប្តាហ៍ក្រោយមក នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ មានការចាប់ខ្លួនមួយទៀតបានកើតឡើង ។ លើកនេះ ជនជាតិមូស្លីម កម្ពុជាម្នាក់ឈ្មោះ ស្មាន អ៊ីស្មាអែល (Sman Ismael) ធ្វើការនៅ មណ្ឌលកុមារកំព្រាចោមចៅ ស្ថិតនៅខាងលិចទីក្រុងភ្នំពេញ ត្រូវបាន ចាប់ខ្លួនពីបទជាប់ពាក់ព័ន្ធនឹងហាំបាលី ។ មណ្ឌលកុមារកំព្រាចោម ចៅនេះ ជាសាលារៀនដែលឧបត្ថម្ភដោយអង្គការសាលាហ្វីមួយ ឈ្មោះថា RIHS ដែលមានមូលដ្ឋាននៅប្រទេសគុយវ៉ែត ។ មាន ការរាយការណ៍មកថា ភស្តុតាងដើម្បីធ្វើការចាប់ខ្លួននេះ បានផ្តល់មក ដោយរដ្ឋាភិបាលអាមេរិក ទោះបីជាភស្តុតាងនោះមិនដែលបាន លាតត្រដាងទៅសាធារណៈជន ឬនៅក្នុងការសាលាក្តីកម្ពុជាណា មួយនាពេលអនាគតក៏ដោយ ។ **(តទៅលេខក្រោយ)**

**អេង កុកថាយ**

# អាជីកំបាំងរបស់ ប៉ុល ពត

**(តពីលេខមុន)**

បន្ទាប់ពីមានការតស៊ូនយោបាយជាចំហដែលគ្មានបានផលមួយរយៈកន្លងមក "ក្រុមប្រជាជន" បានងាកទៅធ្វើសកម្មភាពជាសម្ងាត់វិញ ។ ពីថ្ងៃ២៨-៣០ កញ្ញា ១៩៦០ ទូ សាមុត, សាឡុត ស, អៀង សារី និងដៃដើងរបស់គេមួយក្រុមតូចទៀត បានរួមប្រជុំធ្វើមហាសន្និបាតសម្ងាត់នៅចំណតអយស្ម័យយានក្រុងភ្នំពេញ ដើម្បីកំណត់មាគ៌ានយោបាយ និងប្រហែលជាបានផ្លាស់ប្តូរឈ្មោះបក្សរបស់ខ្លួនទៅជា "បក្សពលករ" វិញ ហើយបានជ្រើសតាំងគណៈកម្មាធិការមជ្ឈិមមួយ ដែលមានសមាជិក៨រូប ទូ សាមុត បានទទួលតំណែងជាអគ្គលេខាបក្ស ។ សាឡុត ស បានឡើងជាសមាជិកម្នាក់ ក្នុងចំណោមសមាជិកការិយាល័យនយោបាយទាំង៣រូប ។ ២ឆ្នាំក្រោយមក ការបាត់ខ្លួនដ៏អាថ៌កំបាំងរបស់ ទូ សាមុត នៅថ្ងៃទី២០ កក្កដា ១៩៦២ ដែលប្រហែលជាត្រូវសម្លាប់ដោយពួកប៉ូលីសនោះ តាមឯកសារមួយចំនួនរបស់គណបក្សប្រជាជនកម្ពុជាបញ្ជាក់ថា ទូ សាមុត ទំនងជាត្រូវ ប៉ុល ពត (សម្លាប់) បាននាំឲ្យ សាឡុត ស ចូលកាន់កាប់កន្លែងកំពូលបាន ។ នៅថ្ងៃទី២០ មេសា ១៩៦៣ ក្នុងមហាសន្និបាតលើកទី២ នៃបក្សពលករ គេបានសម្រេចជ្រើសតាំង សាឡុត ស ជាអគ្គលេខាបក្សជំនួស ទូ សាមុត ។ បញ្ហាដែលថា ប៉ុល ពត មានលូកដៃក្នុងរឿងឃាតកម្ម ទូ សាមុត ឬក៏អត់នោះ គឺនៅមិនទាន់ច្បាស់លាស់នៅឡើយ ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៣ បាតុកម្មប្រឆាំងនឹងរដ្ឋាភិបាល និងការបះបោររបស់ប្រជាជនបានផ្ទុះឡើង ។ រដ្ឋាភិបាលបានចោទប្រកាន់ទៅលើបុគ្គលិកសិក្សាមួយចំនួនមាន សុន សេន និង កេង



ប៉ុល ពត បងធំទី១

វ៉ាន់សាក់ ជាដើម ។ លន់ នល់ ដែលពេលនោះជាមេប៉ូលីស បាន ដាក់ថ្វាយសម្តេចនូវបញ្ជីឈ្មោះមួយដែលសុទ្ធតែជាឈ្មោះឥស្សរជនមានគំនិតវិទ្ធង្សនាចំនួន៣៤រូប ក្នុងនោះ ក៏មានឈ្មោះ សាឡុត ស និង អៀង សារី ដែរ ។ បន្ទាប់ភ្លាមនោះ អ្នកទាំងពីរត្រូវបង្ខំចិត្តរត់ភៀសខ្លួនទៅព្រៃម៉ាគីនៅភាគខាងកើតប្រទេស ។ មុខរបរ គ្រូសារ បណ្តាសម្ព័ន្ធមិត្តនយោបាយ បានត្រូវរលាយបាត់បង់ ។ សាឡុត ស បានក្លាយទៅជាជនបដិវត្តន៍យ៉ាងពេញលេញនាពេលនោះ ។ ក្នុងឆ្នាំបន្តបន្ទាប់មកទៀត ស និងបក្សរបស់គាត់បានសម្រេចថា ការរៀបចំចលនាកុម្មុយនីស្តឲ្យមានទម្រង់ត្រឹមត្រូវដោយគ្មានគ្រោះថ្នាក់ក្នុងរាជធានីនោះ គឺត្រូវតែបញ្ចប់ត្រឹមនេះ ព្រោះប៉ូលីសរបស់សម្តេចសីហនុ បានស្រាវជ្រាវរកឃើញឈ្មោះបណ្តាអ្នកដឹកនាំបក្សនៅភ្នំពេញអស់ទៅហើយ ។ ដូច្នេះ ពួកជនកុម្មុយនីស្តដែលធ្វើសកម្មភាពក្នុងរាជធានីទាំងប៉ុន្មាន ប្រហែល៩០ភាគរយ បានបង្ខំចិត្តចាកចេញពីទីក្រុងយ៉ាងស្ងាត់កំបាំងបន្តកន្ទុយគ្នាឆ្ពោះទៅទិសខាងកើតដែរ ដើម្បីបង្កើតក្រុមតស៊ូមួយនៅទីនោះទៀត ។

ក្នុងរយៈពេល១៣ឆ្នាំក្រោយមក ដោយបក្សពលករកម្ពុជាហាក់ដូចជាកាន់តែដកខ្លួនឆ្ងាយទៅៗ ចេញពីក្រុងហាណូយនោះ សាឡុត ស និងកម្មាភិបាលថ្នាក់លើជាច្រើននាក់របស់បក្សស្ទើរតែបាត់មុខពីក្រសែភ្នែករបស់សាធារណជនដែរ ។ អំណើះពីនោះមក ភូមិឋានរបស់គាត់ គឺព្រៃភ្នំ ។ គាត់បានបោះទីតាំងសំខាន់របស់បក្សទៅនៅក្នុងព្រៃដាច់ស្រយាលមួយនាខេត្តរតនគិរីវិញ ព្រោះនៅតំបន់វាលរាបខាងកើតប្រទេសនោះសត្រូវងាយវាយប្រហារមកលើណាស់ ។ គាត់ក៏បានរៀបចំ "ការិយាល័យលេខ១០០" មួយកន្លែងក្នុងមូលដ្ឋានមួយដែលត្រួតត្រាដោយពួកវៀតណាមជាមួយបណ្តាសមមិត្តគាត់១២នាក់ទៀត ។ ពួកគេនៅពុំទាន់មានអាវុធកាន់ទេ ។ ថ្វីបើមានជំងឺរាកមួល និងជំងឺគ្រុនចាញ់ ក៏ សាឡុត ស ខំប្រឹងអូសក្រដាស "រ៉ូណេអូ" ដោយគ្មានសំចៃ ដើម្បីផ្តល់សន្ទុះដល់បុព្វហេតុបដិវត្តន៍របស់គាត់ ។ ក្នុងអំឡុងពេលនោះ ស មិនត្រឹមតែបានពង្រឹងជំហរដឹកនាំរបស់ខ្លួនក្នុងផ្ទៃបក្សពលករប៉ុណ្ណោះទេ គាត់ថែមទាំងបានប្រកួតប្រជែងជាបន្តបន្ទាប់ និងទទួលបានជោគជ័យលើបណ្តាសមាសភាពស្និទ្ធហាណូយក្នុងក្រុមចលនាតស៊ូប្រឆាំងសម្តេចសីហនុ ទៀតផង ។ ទោះជាយ៉ាងនេះក្តី នៅពេលនោះ ស បានប្រុងប្រយ័ត្នជាប់ជានិច្ច ជៀសវាងការផ្តាច់ចេញដោយចំហពីពួកកុម្មុយនីស្តវៀតណាម ដែលកំពុងពង្រឹងជំហររបស់ពួកគេ តាមមាគ៌ា ហូជីមិញ នៅតាមតំបន់នានាក្នុងបូរណភាពទឹកកម្ពុជា ។ ប៉ុន្តែ ទស្សនកិច្ចរបស់ ប៉ុល ពត នៅក្រុងហាណូយ ឆ្នាំ១៩៦៥ ដែលមានគោលបំណងដើម្បីស្វែងរកការទទួលស្គាល់ជាមេដឹកនាំកំពូលនោះ ត្រូវបានធ្លាក់ទៅក្នុងភាពខ្មៅងងឹតមួយនៃការមិនទុកចិត្តគ្នាទៅវិញទៅមក ព្រោះក្រុងហាណូយបានបញ្ជាក់ប្រាប់គាត់ឲ្យដឹងដោយគ្មានការយោគយល់ថា "គាត់ត្រូវតែដើរតាមមាគ៌ា ដែលសម្រេចឡើងដោយពួកវៀតណាម" ។ បន្ទាប់មក សាឡុត ស បានធ្វើដំណើរទៅកាន់ប្រទេសចិនទៀត នៅពេលដែលចិនកំពុងធ្វើបដិវត្តន៍វប្បធម៌យ៉ាងខ្លាំងក្លា ។ គាត់បានស្នាក់នៅទីនោះអស់រយៈពេល៧ខែ ហើយទំនងជាគាត់បានសិក្សាពីការរៀបចំអង្គការចាត់តាំង និងផ្នែកមនោគមន៍វិជ្ជាទៀតផង ។ ការផ្លាស់រេរបស់ ប៉ុល ពត ទៅកាន់ប្រទេសចិន កាន់តែលេចរូបរាងច្បាស់ឡើង នៅពេលដែលគាត់ត្រឡប់មកកាន់កម្ពុជាវិញនាខែកញ្ញា ឆ្នាំ១៩៦៦ ។

នៅទីសេនាធិការរបស់ខ្លួនក្នុងខេត្តរតនគិរី សាឡុត ស បានប្រឹងប្រែងប្រមែប្រមូលប្រជាជននៅមូលដ្ឋាននោះបានជាច្រើនឲ្យចូលរួមជាមួយបុព្វហេតុរបស់គាត់ ។ ពួកគេ គឺជាបណ្តាកុលសម្ព័ន្ធខ្មែរលើដែលគោរពអបិយជំនឿ ហើយរស់នៅដោយគ្មានប្រាក់កាសចាយ និងស្អប់ខ្ពើមការជឿនលឿន ។ គាត់បានរៀបចំអ្នកស្រុកទាំងនោះឲ្យទៅជាកងទ័ពមួយមានទម្រង់ដូចជនិទាន់ "សម័យកុម្មុយនីស្តបុព្វកាល" ដែរ ។ នៅអំឡុងពេលនោះហើយដែលសម្តេចសីហនុ បានបង្កើតឈ្មោះមួយសម្រាប់ហៅកងទ័ពរបស់ ស ថា "ពួកខ្មែរក្រហម" ។ ជាមួយគ្នានោះ បាតុកម្មនានាដែលផ្តើមគំនិតឡើងដោយបក្សប្រជាជនបដិវត្តន៍ប្រឆាំងនឹងរបបសម្តេច សីហនុ បានផ្ទុះឡើងយ៉ាងគគ្រឹកគគ្រេង ។ ការបកអាក្រាត និងការដាក់ទោសប្រហារជីវិតដល់អ្វីដែលរដ្ឋាភិបាលព្រះអង្គហៅថា ខ្មែរក្រហម នោះ កាន់តែពង្រឹងគណបក្សប្រឆាំងឲ្យរឹតតែមានឥទ្ធិពលខ្លាំងឡើងថែមទៀត ។ ទន្ទឹមនឹងនោះ ក៏បានធ្វើឲ្យគណបក្សប្រឆាំងកាន់តែគួរឲ្យភ័យខ្លាចលើសពីធាតុពិតរបស់ខ្លួនទៅទៀត ។ នៅខែធ្នូ ១៩៦៩ និងខែមករា ១៩៧០ ប៉ុល ពត និងថ្នាក់ដឹកនាំជាន់ខ្ពស់បក្ស បានទៅធ្វើទស្សនកិច្ចនៅក្រុងហាណូយ និងក្រុងប៉េកាំងម្តង

ទៀត ដើម្បីរៀបចំយុទ្ធនាការផ្តាច់ព្រ័ត្រមួយដើម្បីផ្តួលរំលំរបប សម្តេច សីហនុ ។ ប៉ុន្តែ គម្រោងការនេះ ពុំបានអនុវត្តឡើយព្រោះ នៅថ្ងៃទី១៨ មីនា ១៩៧០ រដ្ឋប្រហារស្តាំនិយមមួយនៅភ្នំពេញ បានទម្លាក់សម្តេច សីហនុ ពីអំណាច និងលើក លន់ នល់ ឲ្យកាន់ តំណែងជាប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរស្រេចទៅហើយ ។

ក្នុងឆ្នាំ១៩៦៩នោះ ប្រទេសកម្ពុជាបានត្រូវអូសទាញឲ្យធ្លាក់ទៅក្នុងសង្គ្រាមវៀតណាមដែរ ។ ការចូលលុកលុយកាន់តែជ្រៅឡើងៗ នៅភាគខាងកើតកម្ពុជាដោយពួកវៀតណាម និងការប្រឆាំងលក្ខណៈអាមេរិកាំងនិយមរបស់សម្តេច សីហនុ បាននាំគ្នាឲ្យសហរដ្ឋអាមេរិកធ្លាក់ទម្លាក់គ្រាប់បែកតាមព្រំដែនជាញឹកញាប់ ។ សេដ្ឋកិច្ចប្រទេសត្រូវដួលរលំ ។ ក្រោយដណ្តើមបានអំណាច លន់ នល់ ខិតខំដេញកម្ចាត់ពួកវៀតណាមចេញពីប្រទេសភ្លាម ។ ជាប្រមុខរដ្ឋដែលត្រូវនិរទេស សម្តេច សីហនុ បានរកឃើញផ្លូវឡើងវិញ ដោយព្រមធ្វើជាមេដឹកនាំបក្សសម្ព័ន្ធមួយ គឺរណសិរ្សរួបរួមជាតិកម្ពុជា ។ ប៉ុន្តែ អំណាចពិតប្រាកដ គឺស្ថិតនៅក្នុងកណ្តាប់ដៃគណៈកម្មាធិការមួយយ៉ាងច្បាស់ក្រឡែត ដែលមានសមាជិក៥រូប ដឹកនាំដោយ ប៉ុល ពត ដោយកាន់តំណែងមិនចេញមុខដើម្បីធានាសុវត្ថិភាពរបស់ខ្លួន ។ ទោះបីជាសមាជិកខ្លះនៃចលនាកុម្មុយនីស្តកម្ពុជា និងថ្នាក់ដឹកនាំផ្សេងទៀត រួមមានទាំងសហការីរបស់ ប៉ុល ពត ដែលជាអនាគតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យសុខចិត្តចូលរួមតាមសេចក្តីអំពាវនាវរបស់ សម្តេច សីហនុ បង្កើតរណសិរ្សរួបរួមមួយប្រឆាំងរបប លន់ នល់ ក៏ដោយ ក៏ខ្លួន ប៉ុល ពត ផ្ទាល់ នៅដាច់តែឯងមិនព្រមចូលរួមជាមួយគេឯងឡើយ ។ បន្ទាប់ពីការរលំរលាយនៃរបបសម្តេច សីហនុ ក្រុងហាណូយបានចាប់ផ្តើមបញ្ជូនបណ្តាជនកុម្មុយនីស្តខ្មែរ ដែលបានទទួលការបណ្តុះបណ្តាលនៅវៀតណាមខាងជើងតាំងពីឆ្នាំ១៩៥៤នោះ មកកាន់កម្ពុជាចំនួន១.០០០នាក់ ជនទាំងនេះជាអ្នកតស៊ូខ្មែរដែលបានប្រមូលផ្តុំទៅភាគខាងជើងវៀតណាម (ពេលដែលសង្គ្រាមឥណ្ឌូចិនលើកទី១ បានបញ្ចប់ដោយកិច្ចព្រមព្រៀងក្រុងហ្សឺណែវ) ។ ប៉ុន្តែ តាមបញ្ជារបស់ ប៉ុល ពត ភាគច្រើននៃពួកអ្នកដែលពួកវៀតណាមបញ្ជូនមកនេះ បានត្រូវតាមដានកត់សម្គាល់ និងសម្លាប់ចោលជាបន្តបន្ទាប់ ។ សាឡុត ស ពុំដែលចេញពីទីលាក់ខ្លួនរបស់គាត់ដើម្បីជួបអ្នកណាម្នាក់ឡើយ ។ ខៀវ សំផន គឺជាមន្ត្រីជាន់ខ្ពស់មួយរូប ដែលគេអាចទៅរកជួបបាននៃចលនាមួយដែលប្រមូលផ្តុំមនុស្ស៣.០០០នាក់ ហើយដែលមិនទាន់មានការហ្វឹកហ្វឺនត្រឹមត្រូវ ។ អៀង សារី ទៅប្រចាំការនៅក្រុងហាណូយ ដើម្បីបំពេញមុខងារជាខ្សែរយៈទាក់ទងជាមួយមេដឹកនាំវៀតណាម ។ ទោះបីមានការកាប់សម្លាប់ពួកកុម្មុយនីស្តខ្មែរដែលមកពីវៀតណាមខាងជើង និងមានការប៉ះទង្គិចគ្នាជាមួយបក្សពួក ប៉ុល ពត ក្នុងខេត្តកំពង់ធំ ក៏ដោយ ក៏ក្រុងហាណូយខំជៀសវាងមិនឲ្យមានការបែកបាក់គ្នាឡើយ គឺក្នុងគោលបំណងដណ្តើមយកជ័យជម្នះផ្តាច់ព្រ័ត្រជាលើកដំបូងមួយនៃលទ្ធិកុម្មុយនីស្តនៅទូទាំងឥណ្ឌូចិន ។ គ្រោះអាក្រក់កាន់តែខិតជិតមកដល់ប្រទេសជាតិត្រូវដាច់ដោចចេញពីគ្នា ។ ពួកខ្មែរក្រហមកំពុង "ត្រូវក្តៅង" យ៉ាងខ្លាំង ។ ពួកគេសម្រុកធ្វើការវាយប្រហារទៅលើភូមិនានា ដែលគេត្រូវឆ្លងកាត់ ដោយពុំមានការយោគយល់នរណាឡើយ ។ ក៏ប៉ុន្តែ ការប្រើអំណាចសង្កត់សង្កិន ភាពតឹងរ៉ឹងជ្រុល និងភាពមោះមុតរបស់ពួកគេ ទៅជាទាក់ទាញបានទឹកចិត្តកូនចៅប្រជាកសិករដែលហិនហោចទ្រព្យសម្បត្តិ ដោយសារសង្គ្រាមឲ្យចូលធ្វើកងទ័ពមួយចំនួនយ៉ាងធំ ។

នៅពាក់កណ្តាលខែកញ្ញា ១៩៧១ មហាសន្និបាតថ្មីមួយរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជាបានបោះឆ្នោតម្តងទៀតជ្រើសរើស ប៉ុល ពត ធ្វើជាអគ្គលេខាធិការបក្ស និងជាមេបញ្ជាការកងទ័ពបដិវត្តន៍ ។ ភាពតានតឹងរវាងក្រុងហាណូយ និងក្រុងភ្នំពេញ កាន់តែធ្ងន់ឡើងៗ គឺនៅពេលដែលបក្សប្រជាជនបដិវត្តន៍កម្ពុជាបដិសេធសំណើមួយរបស់វៀតណាម ដែលសុំឲ្យបក្សចរចាជាមួយរបប លន់ នល់ និងសហរដ្ឋអាមេរិក ដែលក្នុងពេលនោះ វៀតណាម និងសហរដ្ឋអាមេរិកក៏កំពុងជួបចរចាគ្នានៅទីក្រុងប៉ារីសដែរ ។ ដោយអនុលោមតាមកិច្ចព្រមព្រៀងប៉ារីស នៅដើមឆ្នាំ១៩៧៣ ពួកវៀតណាមបានដកទ័ពចេញពីទីតាំងខ្លះៗរបស់ "កងទ័ពបដិវត្តន៍" ដែលស្ថិតនៅក្នុងទឹកដីខ្មែរ ។ ជាបន្ទាន់ កងទ័ពបដិវត្តន៍កម្ពុជាបានចូលទៅជំនួសកន្លែងនោះវិញ ប៉ុល ពត ក៏ខំពង្រឹងមូលដ្ឋានអំណាចរបស់ខ្លួនឲ្យកាន់តែខ្លាំងឡើងថែមទៀតដែរ ។ ទោះជាយ៉ាងណាក៏ដោយ ការប៉ះទង្គិចរវាងកងទ័ព លន់ នល់ និងក្រុមទ័ពព្រៃ ប៉ុល ពត ការវាយសម្រុករបស់កងទ័ពបដិវត្តន៍កម្ពុជាទៅលើក្រុមចលនាតស៊ូខ្មែរដែលគាំទ្រក្រុងហាណូយ និងទៅលើបក្សពួក "រដ្ឋាភិបាល

ចម្រុះនិរទេស» របស់សម្តេច សីហនុ នោះ ចេះតែកើនច្រើនឡើងជាបន្តបន្ទាប់ ។ ក្នុងឆ្នាំ១៩៧៣ដដែល ចលនាកុម្មុយនីស្តដែលចាប់ពីពេលនោះមក គេហៅថា "អង្គការ" នោះ មានកម្លាំងសរុបជិត៦ម៉ឺននាក់ ហើយមានសមត្ថភាពប្រយុទ្ធដូចកងទ័ពស្រួចមួយដែរ ។ ក្នុងបណ្តាតំបន់រំដោះនានា ប៉ុល ពត បានចាប់ផ្តើមដាក់ចេញកម្មវិធីសង្គមកិច្ចរបស់គាត់ ការគាបសង្កត់ទៅលើសាសនា ការបង្កើតកងចល័តយុវជនដោយបំបែកឲ្យរស់នៅដាច់ពីគ្រួសាររបស់គេ ការផ្លាស់ប្តូរកន្លែងរស់នៅរបស់ប្រជាជនដោយបង្ខំ ការស្លៀកពាក់ខោអាវពណ៌ខ្មៅដោយខានមិនបាន និងការលុបបំបាត់ពិធីបុណ្យប្រពៃណីផ្សេងៗ ។

ទោះជាមានអរិភាពជាមួយវៀតណាមក៏ដោយ ក៏ក្នុងសារលិខិតទាំងឡាយដែលផ្ញើទៅមេដឹកនាំក្រុងហាណូយ និងមេដឹកនាំបក្សវៀតណាម ព្រមទាំងសេចក្តីថ្លែងការណ៍ជាសាធារណៈ ប៉ុល ពត នៅតែអះអាងពីចំណងមិត្តភាព និងកតញ្ញូតាធម៌របស់ខ្លួនចំពោះវៀតណាមដដែល ។

របប លន់ នល់ ដែលពុករលួយដល់ឆ្អឹង ហើយដែលសហរដ្ឋអាមេរិកគាំទ្រចុងដៃចុងជើងនោះ បានស្រុតដួលបន្តិចម្តងៗក្នុងពេលដំណាលគ្នានឹងពួកយុទ្ធជនខ្មែរក្រហមដណ្តើមបានការត្រួតត្រាតំបន់ជនបទស្ទើរតែទាំងស្រុង ។ ចាប់ពីឆ្នាំ១៩៧៣មក ការវាយប្រហារធំៗដែលរៀបចំឡើងដោយ "បងលេខ១" គឺ សាឡុត ស មានគោលដៅតម្រង់ទៅរកទីក្រុងភ្នំពេញច្បាស់ណាស់ ។ នៅឆ្នាំ១៩៧៤ ក្រុងភ្នំពេញបានទទួលការផ្គត់ផ្គង់ស្បៀង សម្ភារសឹកតែតាមផ្លូវអាកាសប៉ុណ្ណោះ ។ បន្ទាប់មក គឺ ស្គរ "សញ្ញាទាល់ច្រក" បានលាន់ឮឡើងពាសពេញរដ្ឋធានី ។ នៅថ្ងៃទី១៧ មេសា ១៩៧៥ ពួកកងទ័ពក្មេងៗស្លៀកពាក់ខ្មៅបានដើរចូលមកដល់ទីក្រុងភ្នំពេញ ដែលត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃបណ្តាក្រុមកុម្មុយនីស្តផ្សេងៗគ្នា និងបក្សពួកសីហនុនិយម ។ បន្តិចម្តងៗ បក្សប្រជាជនបដិវត្តន៍កម្ពុជា និង សាឡុត ស ផ្ទាល់ បានព្យាយាមពុះពារខបសគ្គផ្សេងៗរហូតដល់បានសម្រេចដាក់នឹមអនុត្តរភាពលើរដ្ឋធានីទាំងមូល ។ ក្នុងរយៈពេល២៤ម៉ោង ក្រោយជ័យជម្នះ ពួកខ្មែរក្រហមបានបណ្តេញប្រជាជនទាំងអស់ចេញពីទីក្រុង ។ ៦ថ្ងៃក្រោយមក សាឡុត ស បានធ្វើដំណើរមកដល់ទីក្រុងខ្មោចនេះ ។

ដោយគ្មានបទពិសោធន៍ក្នុងការកាន់អំណាចបន្តិចសោះនោះ ពួកខ្មែរក្រហមបានរៀបចំអស់រយៈពេលមួយ១ឆ្នាំ ដើម្បីបង្កើតរដ្ឋាភិបាលមួយជារបស់ខ្លួនផ្ទាល់ ។ ក្នុងការរង់ចាំនោះ ពួកគេបានបិទទ្វារប្រទេសទាំងស្រុង ហើយបែងចែកប្រជាជនជា២ប្រភេទ គឺ "ពួកអ្នកចាស់" និង "ពួកអ្នក១៧ មេសា" ដែលគ្មានសិទ្ធិអ្វីទាំងអស់ និងត្រូវដាក់ឲ្យធ្វើការជាទម្ងន់ ។ ត្រឡប់មកវិញក្នុងខែកញ្ញា ១៩៧៥ ក្នុងឋានៈជាប្រមុខរដ្ឋ សម្តេច សីហនុ បានសុំលាលែងពីតំណែងនៅ៧ខែក្រោយមកទៀត ។ ភ្លាមនោះ សម្តេច បានត្រូវ "អង្គការ" យកទៅដាក់ឲ្យរស់នៅក្នុងវាំងរបស់ព្រះអង្គផ្ទាល់ ដោយមានការឃ្លាំមើលថែមទៀត ដែលក្នុងរយៈពេលនោះ ព្រះអង្គបានសរសេរកំណត់ហេតុដ៏ល្បីល្បាញមួយឈ្មោះ "អ្នកទោសខ្មែរក្រហម" ។

មិនយូរប៉ុន្មានក្រោយថ្ងៃជ័យជម្នះ ការប៉ះទង្គិចគ្នាបានកើតឡើងជាបន្តបន្ទាប់រវាងកងទ័ពបដិវត្តន៍ និងកងទ័ពវៀតណាមនៅតាមតំបន់នានាជាប់ព្រំដែនព្រមទាំងនៅតាមបណ្តាកោះក្នុងឈូងសមុទ្រសៀមទៀត ។ នៅដើមខែមិថុនា ១៩៧៥ មានការជួបគ្នាមួយរវាង ប៉ុល ពត និង ង្វៀង វ៉ាន់លិញ នៅព្រំដែន វៀតណាម-កម្ពុជា ។ តាមសេចក្តីរាយការណ៍ថា ប៉ុល ពត បានសុំអភ័យទោសវៀតណាមដោយសម្អាងថា ទាហានរបស់ខ្លួន "មើលផែនទីភូមិសាស្ត្រច្រឡំ" ។ ប៉ុន្តែ ទោះបី ប៉ុល ពត បានទៅធ្វើទស្សនកិច្ចម្តងទៀត ក្នុងខែមិថុនានៅក្រុងហាណូយដើម្បីស្នើចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពក៏ដោយ ក៏ភាពតានតឹងរវាង ប៉ុល ពត និងសហការីខ្លួនជាមួយវៀតណាម នៅតែមិនបានធូរស្រាលឡើយ ។

អស់រយៈជិតមួយឆ្នាំ ប៉ុល ពត និងបណ្តាសមមិត្តកុម្មុយនីស្តខ្មែរដទៃទៀត ក៏ដូចជាសម្តេច សីហនុ ដែលកំពុងស្ថិតនៅក្នុង "មុខដង្កាប់" សត្រូវនោះ បានតស៊ូដណ្តើមអំណាចគ្នាក្នុងរដ្ឋមួយដែលទើបនឹងប្រកាសថ្មីថា "កម្ពុជាប្រជាធិបតេយ្យ" ។ នៅដើមខែមករា ១៩៧៦ មហាសន្និបាតលើកទី៤ របស់បក្សប្រជាជនបដិវត្តន៍កម្ពុជា បានប្រារព្ធឡើងដើម្បីអះអាងបញ្ជាក់ពីតំណែង ប៉ុល ពត ម្តងទៀតថា ជាអគ្គលេខាបក្សដដែល ប៉ុន្តែក៏បានលើកឡើងពីការបែកបាក់រវាង ប៉ុល ពត និងអង្គការចាត់តាំងតាមតំបន់មួយចំនួនធំដែរ ។

បន្ទាប់ពីថ្ងៃជ័យជម្នះ ប៉ុល ពត នៅតែបាត់មុខរហូត ប៉ុន្តែ

នៅថ្ងៃ ១៤ មេសា ១៩៧៦ ក្រោយពីមានការបោះឆ្នោតជ្រើសរើសសភាតំណាងប្រជាជន២៥០រូប ដែលត្រួតត្រាដោយបក្សកុម្មុយនីស្តកម្ពុជា និងក្រោយពីការលាលែងពីតំណែងរបស់សម្តេចសីហនុ ពីកៅអីប្រមុខរដ្ឋមក រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្មីមួយបានត្រូវប្រកាសឡើង ។ ប៉ុល ពត ដែលគេបោះឆ្នោតជាផ្លូវការជាប់ជាតំណាងសភាប្រជាជន តំណាងឲ្យ «អង្គភាពកម្មករចម្ការកៅស៊ូ» នោះ បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី ។ គាត់ជាមនុស្សម្នាក់ ដែលគេមិនធ្លាប់ដែលឃើញមុខ និងស្គាល់ទាល់តែសោះ ។ ពិភពលោកខាងក្រៅ បានប្រទះឃើញគាត់ជាលើកដំបូងក្នុងឱកាសទស្សនកិច្ចមួយនៅក្រុងប៉េកាំង ក្រោយរយៈពេលជាង២ឆ្នាំ នៃការគ្រប់គ្រងប្រទេសរបស់គាត់ ។ ទោះជាយ៉ាងណាក៏ដោយរដ្ឋអំណាចរបស់គាត់នៅតែត្រូវប្រឈមមុខនឹងការប្រកួតប្រជែងពីសំណាក់កម្មាភិបាលស្និទ្ធហាណូយ ដែលមាននៅក្នុងជួរបក្ស និងពីសំណាក់មេតំបន់មួយចំនួនដែរ ។ នៅដើមខែវិច្ឆិកា ១៩៧៦ ប៉ុល ពត បានបើកយុទ្ធនាការដ៏ធំមួយដើម្បីបោសសម្អាតបណ្តាគូប្រជែងរបស់គាត់ រួមមានទាំងមន្ត្រីខុទ្ទកាល័យ និងមេដឹកនាំបក្សថ្នាក់លើដទៃទៀតផង ដែលតាមរបាយការណ៍ជាច្រើនបានបញ្ជាក់ពីតួនាទីយ៉ាងសំខាន់របស់ ខៀវ សំផន ក្នុងការសម្រេចទិសដៅនេះ ។ សកម្មភាពនេះ បានបណ្តាលឲ្យមានភាពវឹកវរ ជ្រួលច្របល់នៅកំពង់ធំ និងឧត្តរមានជ័យយ៉ាងគួរឲ្យព្រឺខ្លាច ។

ប៉ុល ពត បានដាក់ចេញស្នាដៃយ៉ាងធំមួយរបស់គាត់ គឺ «ផែនការ៤ឆ្នាំ» ក្នុងគោលដៅកសាងលទ្ធិសង្គមនិយមលើគ្រប់វិស័យទាំងអស់ តាមកម្មវិធីឯករាជ្យម្ចាស់ការ និងសមូហភាវូបនីយកម្មជាទូទៅ ។ ចាប់ពីឆ្នាំ១៩៧៦មក គ្រោះទុរភិក្សបានរាលដាលពាសពេញប្រទេស បណ្តាលឲ្យ «ពួក១៧ មេសា» បាត់បង់ជីវិតដោយការអត់ឃ្លានអស់៨០០.០០០នាក់ ។ តើ ប៉ុល ពត មានប្រតិកម្មយ៉ាងណា? គឺគ្មានទាល់តែសោះ ។ ជំងឺមិនទុកចិត្តគេឯងរបស់គាត់កាន់តែកើនឡើងដោយការដាក់ឲ្យប្រជាជនរស់នៅដាច់ដោយឡែកពីខ្លួនទាំងស្រុង ។ ប៉ុល ពត បាននិយាយថា «ពួកក្បត់ និងពួកបច្ចាមិត្តកំពុងឃុបឃិតរួមគំនិតគ្នាបំផ្លាញយើង ។ បក្សកំពុងមានជំងឺ យើងត្រូវតែកម្ចាត់ «មេរោគ» ទាំងនោះ និងធ្វើឲ្យអំណាចកំពូលស្អាតបរិសុទ្ធ» ។ ការបោសសម្អាតសមាសភាពមិនល្អជាច្រើនបានចាប់ផ្តើម ។ ក្នុង «បុរីសម្ងាត់» របស់គាត់ដែលរៀបចំនៅកន្លែងពីដើមជាទីដែលគាត់ធ្លាប់រស់នៅឆ្លងកាត់យុវវ័យនោះ មេដឹកនាំរូបនេះ បានបញ្ជាឲ្យគេសម្លាប់ពួកអ្នកបម្រើ និងពួកអង្គរក្សគាត់អស់ជាច្រើន ក្នុងករណីដែលមានការដាច់ទឹក ឬដាច់ចរន្តអគ្គិសនីម្តងៗ ។ ពីកន្លែងគាត់មិនដល់២គីឡូម៉ែត្រផង សុន សេន ក៏កំពុងដឹកនាំគ្រប់គ្រងគុកទួលស្លែងដែរ ។ គឺទីនោះឯងដែលយុទ្ធិកៈរបស់ពួកគេរាប់ពាន់នាក់ បានត្រូវគេធ្វើទារុណកម្ម រហូតទាល់តែពួកគេសារភាពថា ធ្លាប់បានបម្រើផលប្រយោជន៍ឲ្យពួកសេ.អ៊ី.អា ឬពួកវៀតណាម បន្ទាប់មក ក៏ត្រូវគេយកទៅសម្លាប់ចោលអស់យ៉ាងច្រើន ។ ក្នុងចំណោមនោះ មានមិត្តរួមជំនាន់ក្នុង «ការិយាល័យលេខ ១០០» របស់ ប៉ុល ពត និងសមាជិករដ្ឋាភិបាល៥រូប ។ ពួកខ្មែរក្រហមធ្វើដូច្នេះ គឺធ្វើឲ្យអន្តរាយតែខ្លួនឯងប៉ុណ្ណោះ ។ ត្រូវយាយីដោយជំងឺរាកមួល គ្រុនចាញ់ និងលើសឈាម ព្រមទាំងជំងឺមិនទុកចិត្តពេលហៀបបរិភោគអាហារម្តងៗ ប៉ុល ពត ក៏សម្គាល់ឃើញប្រពន្ធរបស់គាត់ធ្លាក់ទៅក្នុងសភាពជាមនុស្សឡប់សតិដែរ ។ ចាប់ពីពេលនេះទៅ គាត់នឹកមមៃតែពីការកម្ចាត់ពួកសត្រូវរបស់គាត់តែប៉ុណ្ណោះ ខាងក្នុងប្រទេស គឺសត្រូវជា «សមាសភាពប្រតិកិរិយាថោកទាបមួយក្តាប់តូច» ខាងក្រៅគឺពួកវៀតណាម ដែលមានកំហុសពីបទធ្វើឲ្យប៉ះពាល់» មោទកភាពរបស់គាត់ ដែលកំពុងដឹកនាំនូវការកកើត និងការរីកលូតលាស់នៃចលនាខ្មែរក្រហម ។ ដោយមានការគាំទ្រយ៉ាងខ្លាំងក្លារបស់ប្រទេសចិន មេដឹកនាំខ្មែរក្រហមរូបនេះបានប្រព្រឹត្តការភ័ន្តច្រឡំមួយក្នុងការបង្កហេតុនឹងសត្រូវស្លូតបូតរបស់ខ្លួន ។

ភាពហិង្សានៅក្នុងនយោបាយកែទម្រង់ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ ប៉ុល ពត នៅចុងបញ្ចប់ បានធ្វើឲ្យឈ្មោះខ្លួនឯងមានន័យថា ជាមហន្តរាយធំមួយក្នុងចំណោមមហន្តរាយក្នុងពិភពលោកសម័យទំនើបយើងនេះ ។ ការបង្ខិតបង្ខំជម្លៀសប្រជាជនចេញពីទីក្រុងនានា និងពីភូមិឋានរបស់ពួកគេ ដោយសម្លាប់រង្គាល ការបង្ខំប្រជាជនរាប់សែននាក់ឲ្យធ្វើការហួសកម្លាំងក្នុងគម្រោងការងារកសិកម្មផ្សេងៗ ការបង្អត់អាហារ ថ្នាំពេទ្យ ការកម្ទេច «រាល់កម្អែលចាស់» ពោល គឺជនដែលជាប់សង្ស័យថា ជាអ្នកមានពាក់ព័ន្ធនឹងរបបមុនៗ បានឆ្លុះបញ្ចាំងឲ្យឃើញនូវបែបផែនមនោគមន៍វិជ្ជារបស់ ប៉ុល

ពត ដែលក្នុងនោះ លទ្ធិវិសុទ្ធកម្មនិយម និងលទ្ធិភេរវកម្មនិយមស្តាលីននីស ត្រូវបានយកមកផ្សំបញ្ចូលគ្នាជាសាច់តែមួយ ។ ចំណុចសង្កត់ធ្ងន់បំផុតមួយ គឺនយោបាយរបស់ ប៉ុល ពត ក្នុងការបង្កើតយុវជន យុវតី និង «ការផលិតមនុស្សថ្មី» នៅកម្ពុជា ។ សូម្បីតែក្រោយរបប ប៉ុល ពត ត្រូវដួលរលំទៅហើយក៏ដោយ ក៏យុវជនយុវតីទាំងនោះ នៅតែតាម ប៉ុល ពត យ៉ាងស្មោះត្រង់ក្នុងជួរ «កងទ័ពបដិវត្តន៍» របស់កម្ពុជាប្រជាធិបតេយ្យដែរ ។ ប៉ុន្តែ ការកាប់សម្លាប់ និងការធ្វើព្រងើយកន្តើយរបស់របប ប៉ុល ពត បានផ្តាច់យកជីវិតប្រជាជនកម្ពុជាអស់ប្រហែលជាង៣លាននាក់ ។

បន្ទាត់នយោបាយ និងការដឹកនាំរបស់របបនេះ បានបង្កឲ្យមានគំនិតប្រឆាំងកាន់តែច្រើនឡើងៗ ក្នុងជួរមេបញ្ជាការកងពល និងកម្មាភិបាលជាន់ខ្ពស់បក្ស ។ ទស្សនកិច្ចរបស់ ប៉ុល ពត ទៅកាន់ប្រទេស ចិន និងកូរ៉េខាងជើងក្នុងខែកញ្ញា និងតុលា ១៩៧៧ បានពង្រឹងជំហររបស់គាត់ក្នុងចំណោមមេដឹកនាំកុម្មុយនីស្តអាស៊ីដទៃទៀត ទោះបីជានៅពេលនោះ មានការវាយប្រហារជាមួយកងទ័ពវៀតណាមនៅតាមព្រំដែនរបស់ខ្លួនដែលកាន់តែមានសភាពធ្ងន់ក៏ដោយ ។ នៅថ្ងៃទី៣១ ធ្នូ ១៩៧៧ រាល់ទំនាក់ទំនងការទូតជាមួយវៀតណាម ត្រូវបានកាត់ផ្តាច់ដោយ ប៉ុល ពត បានចោទប្រកាន់វៀតណាមថា កំពុងដាក់នឹមអនុត្តរភាពមកលើប្រទេសឡាវ និងកម្ពុជា តាមរយៈការបង្កើត «សហព័ន្ធឥណ្ឌូចិន» មួយ ។

ធ្វើអាក្រក់បានអាក្រក់មែន ៖ ចាប់ពីឆ្នាំ១៩៧៨ ពួកវៀតណាមបានបរិហារកេរ្តិ៍ទោសរបបកម្ពុជាប្រជាធិបតេយ្យថាជារបបសាហាវយង់ឃ្នង និងមានបែបផែន «ដូចសម័យយុគកណ្តាល» ហើយបានបើកការវាយលុកជាលើកដំបូងរបស់ខ្លួនចូលក្នុងទឹកដីកម្ពុជា ។ ពីពេលនេះទៅ រូប ប៉ុល ពត ផ្ទាល់ ស្ថិតនៅក្នុងសភាពរវើរវាយផ្តេសផ្តាសហើយ ។ នៅថ្ងៃទី២៦ ឧសភា ១៩៧៨ មេដឹកនាំបក្ស ភូមិភាគបូព៌ា និងបក្សពួករបស់គាត់បានក្រោកឡើងប្រឆាំងនឹង ប៉ុល ពត ។ ប៉ុន្តែ ចលនាបះបោរនេះបានត្រូវបង្ក្រាបឲ្យបរាជ័យទៅវិញ ដែលបណ្តាលឲ្យកម្មាភិបាលរាប់ពាន់នាក់ត្រូវស្លាប់ រីឯអ្នកនៅសល់មួយចំនួនទៀត បានគេចខ្លួនទៅប្រទេសវៀតណាម ។ វៀតណាមបានរៀបចំយ៉ាងវាងវៃក្នុងការគាំទ្រអ្នកប្រឆាំង ប៉ុល ពត ភៀសខ្លួននៅវៀតណាមបង្កើតជា «រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា» ។ នៅចុងឆ្នាំ ១៩៧៨ ការវាយសម្រុក និងការជ្រៀតចូលរបស់វៀតណាមមកក្នុងកម្ពុជាប្រជាធិបតេយ្យ កាន់តែមានសភាពធ្ងន់ និងមានទ្រង់ទ្រាយធំឡើងៗ ប៉ុល ពត បានប្រកាសជាសាធារណៈថា ប្រទេសវៀតណាមច្បាស់ជាប្រឈមមុខនឹងបរាជ័យមួយជាក់ជាមិនខាន ។ តំណែងនាយករដ្ឋមន្ត្រីរបស់ ប៉ុល ពត កាន់តែរង្គោះរង្គើ ហើយរាល់សំណើឲ្យចិនជួយទប់ស្កាត់អន្តរាគមន៍របស់វៀតណាម ក៏មិនសូវបានលទ្ធផលដែរ ។ ដោយសារការវាយលុកផ្តាច់ព្រ័ត្ររបស់វៀតណាម បណ្តាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមួយចំនួន បានត្រូវបង្ខំចិត្តចាកចេញពីភ្នំពេញតាមរថយន្តរថភ្លើងនៅថ្ងៃទី៧ មករា ១៩៧៩ ។ ចំណែក ប៉ុល ពត បានភៀសខ្លួនតាមឧទ្ធម្ភាគចក្រមួយគ្រឿងមួយម៉ោងមុនពេលដែលកងទ័ព១០ម៉ឺននាក់ របស់ក្រុងហាណូយចូលមកដល់ទីក្រុង ។ ក្រោយមក ពួកគេបានប្រមូលផ្តុំកម្លាំងឡើងវិញ និងបានបង្កើតរដ្ឋាភិបាលសម្ងាត់មួយនៅភាគខាងលិចកម្ពុជា និងជួរភ្នំក្រវាញ ។

តុលាការពិសេសមួយ បានប្រកាសសាលក្រមកាត់ទោសប្រហារជីវិត ប៉ុល ពត និងអៀង សារី ដោយកំបាំងមុខពីបទ «ប្រព្រឹត្តអំពើប្រល័យពូជសាសន៍» នៅថ្ងៃទី១៩ សីហា ១៩៧៩ ។ សាលក្រមនេះត្រូវប្រកាសដោយ «តុលាការប្រជាជន» របស់រដ្ឋាភិបាលថ្មីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលកើតឡើងដោយការជ្រោមជ្រែងពីកងទ័ពវៀតណាម ។ ដោយពិភពលោកកាន់តែយកចិត្តទុកដាក់ខ្លាំងឡើងៗចំពោះកម្ពុជាដែលខ្ទេចខ្ទាំដោយសង្គ្រាម និងការបង្ហូរឈាមរបស់របប ប៉ុល ពត ពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុល ពត ខ្លួនឯងកាន់តែក្លាយខ្លួនទៅជាជន «ស៊ីបាយអស់អង្ករ» ឥតបានការនៅចំពោះមុខពួកចិន ដែលជាមេក្លោងទ្រទ្រង់ដ៏សំខាន់ និងឥតបានការចំពោះមុខបណ្តាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យលាក់មុខដទៃទៀត ។ ក្នុងមហាសន្និបាតបក្សចុងក្រោយនាថ្ងៃទី១៧ ធ្នូ ១៩៧៩ ប៉ុល ពត បានលាលែងពីតំណែងនាយករដ្ឋមន្ត្រី ហើយតួនាទីនេះ ត្រូវបានកាន់កាប់ដោយ ខៀវ សំផន វិញ ។

**(តទៅលេខក្រោយ)**

**ឆេព ម៉េងឃាន**

# មន្ទីរសន្តិសុខអូរកន្សែង

នៅថ្ងៃទី២-៣ ខែមីនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការស្តាប់សក្ខីកម្មសាក្សីជន ចុល និង មឿង ចាន់ឌី អំពីមន្ទីរសន្តិសុខអូរកន្សែង ដែលជាទីតាំងឧក្រិដ្ឋកម្មមួយរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារធ្លាប់ជាអ្នកទោស នៅក្នុងមន្ទីរសន្តិសុខអូរកន្សែង អតីតប្តីប្រពន្ធទាំងពីរនេះបានរៀបរាប់យ៉ាងលម្អិតអំពីលក្ខខណ្ឌរស់នៅ ការធ្វើទារុណកម្ម និងការកាប់សម្លាប់អ្នកទោសនៅក្នុងមន្ទីរសន្តិសុខនេះ ។


ជន ចុល

ជន ចុល មានអាយុ ៦៦ឆ្នាំ កើតនៅក្នុងឃុំល្វើន ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ បច្ចុប្បន្នរស់នៅក្នុងសង្កាត់ឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី ។ រីឯ មឿង ចាន់ឌី កើតឆ្នាំ១៩៥៤ នៅភូមិកាស្រោច ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ ។ បច្ចុប្បន្នរស់នៅភូមិដើមឫស្សី ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ អ្នកទាំងពីររៀបការជាមួយគ្នាក្នុងឆ្នាំ១៩៧២ ។ នៅឆ្នាំ១៩៦២ ចុល ចូលបម្រើការជាកម្មករចំការកៅស៊ូក្នុងខេត្តរតនគិរី ។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្នុងឆ្នាំ១៩៧០ ចុល ផ្លាស់ទៅធ្វើស្រែនៅត្រពាំងព្រេះ រហូតដល់របប លន់ នល់ ត្រូវបានដួលរំលំ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជន ចុល និង មឿង ចាន់ឌី ត្រូវអង្គការបញ្ជូនឲ្យធ្វើការនៅចម្ការកៅស៊ូក្នុងខេត្តរតនគិរីវិញ ក្រោមការគ្រប់គ្រងរបស់ ទុំ ប្រធានសហជីពចំការកៅស៊ូ ។ ចុល ទទួលផ្នែកបច្ចេកទេសថែទាំ និងព្យាបាលជំងឺដំណាំកៅស៊ូ ចំណែក ចាន់ឌី ជាកម្មករជៀរជ័រ ។ អ្នកទាំងពីរត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខអូរកន្សែងនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៧ ។ ចាន់ឌី រៀបរាប់ថា ប្រហែលម៉ោង២រសៀល ប្រធានភូមិបានមកហៅប្តីប្រពន្ធគាត់ទាំងពីរឲ្យឡើងឡានដោយប្រាប់ថា ទុំ បញ្ជាឲ្យទៅប្រជុំ ។ ពេលនោះប្តីប្រពន្ធគាត់ក៏ប្រញាប់ប្រញាល់ដើរសំដៅទៅឡានដែលឈប់នៅចម្ងាយប្រមាណ៥០ម៉ែត្រ ពីកន្លែងធ្វើការរបស់គាត់ ។ ពេលទៅដល់គាត់ឃើញប្រជាជនពីរគ្រួសារផ្សេងទៀត និងយោធាខ្មែរក្រហមប្រដាប់ដោយកាំភ្លើងរង់ចាំនៅក្នុងរថយន្តនោះរួចជាស្រេច ។ ប្តីប្រពន្ធគាត់ និងប្រជាជនទាំងពីរគ្រួសារ នោះត្រូវបានដឹកទៅដល់មន្ទីរសន្តិសុខអូរកន្សែងនៅម៉ោងប្រហែល៦ល្ងាច ហើយភ្លាមនោះត្រូវយោធាខ្មែរក្រហមនាំយកទៅឃុំខ្លួននៅក្នុងបន្ទប់ដោយដាក់ខ្នោះ និងចាក់សោពីខាងក្រៅ ។ ចាន់ឌី ត្រូវបានចាប់ខ្លួនទាំងកំពុងមានផ្ទៃពោះបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង ព្រោះតែខ្មែរក្រហមសង្ស័យថាគាត់មានការជាប់ពាក់ព័ន្ធនឹងវៀតណាម ។ ដោយឡែក ចុល ខ្មែរក្រហមចោទប្រកាន់ថាបានប្រើប្រាស់បច្ចេកទេសព្យាបាលជំងឺកៅស៊ូតាមរបៀបសក្តិភូមិ មិនប្រើបច្ចេកទេសរបស់កសិករ ។

### ស្ថានភាពទូទៅនៃមន្ទីរសន្តិសុខអូរកន្សែង

មន្ទីរសន្តិសុខអូរកន្សែងមានទីតាំងនៅក្នុងភូមិ៦ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី ។ តាមការបញ្ជាក់របស់ ជន ចុល មន្ទីរសន្តិសុខអូរកន្សែង ត្រូវបានគេហៅនៅពេលនោះថា "សាលាកែប្រែ" ។ មន្ទីរសន្តិសុខនេះចំណុះកងពល៨០១ ដែលមាន សូ សារឿន ហៅ ០៥ ជាមេបញ្ជាការឈរជើងនៅវីនសៃ ។ បន្ទប់ឃុំខ្លួនអ្នកទោសត្រូវបានសង់ជាប់ៗពីគ្នា ។ បន្ទប់នីមួយៗមានប្រវែងប្រមាណ១២ ទៅ ១៥ម៉ែត្រ ធ្វើពីឈើ ដំបូលប្រក់ស្បូវ ជញ្ជាំងឫស្សី ដែលអ្នកទោសអាចមើលគ្នាឃើញ ។ ក្រៅពីនេះមានបន្ទប់តូចបិទជិតដាច់ដោយឡែកមួយ ប្រើសម្រាប់សួរចម្លើយអ្នកទោស ។ បរិវេណមន្ទីរសន្តិសុខត្រូវបានហ៊ុមព័ទ្ធដោយរបងឫស្សី និងដាក់ចម្រូងព័ទ្ធជុំវិញ ដើម្បីកុំឲ្យអ្នកទោសលួចរត់ ។ បន្លែ ដំឡូង

ពោត ខ្លុះ ត្រូវបានដាំនៅក្បែរៗ នោះ ។ ចាន់ឌី បញ្ជាក់បន្ថែមថា មន្ទីរសន្តិសុខនេះមានសភាពស្ងាត់ជ្រងំ និងនៅដាច់ឆ្ងាយពីអ្នកភូមិ ។

ជន ថុល បញ្ជាក់ថា ឆោម សែ, ឆាង និង ទឹម ជាអ្នកគ្រប់គ្រងផ្ទាល់នៅមន្ទីរសន្តិសុខអូរកន្សែង ។ ប៊ុន វ៉ាន់ថា អតីតអ្នកទោសម្នាក់នៅមន្ទីរសន្តិសុខអូរកន្សែង ធ្លាប់បានផ្តល់បទសម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារនៅក្នុងខែធ្នូ ឆ្នាំ១៩៩៩ ថា ឆោម សែ ជាប្រធានទទួលផ្នែកកិច្ចការនយោបាយ ចំណែក ឆាង ជាអនុប្រធានទទួលខុសត្រូវផ្នែកកិច្ចការយោធា ។ តាមការបញ្ជាក់របស់ ជិន គឹមថុង ប្រធានមន្ទីរសន្តិសុខអូរកន្សែងមុនដំបូងឈ្មោះ ឆេង ។ គឹមថុង បានផ្តល់បទសម្ភាសន៍ដល់មជ្ឈមណ្ឌលឯកសារនៅថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ។ គឹមថុង បញ្ជាក់ថា ឆោម សែ ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរសន្តិសុខអូរកន្សែងបន្ទាប់ពី ឆេង ត្រូវឈ្មោះ សាន ហៅ ០៦ ដែលជាមិត្តភក្តិនឹងគ្នា ដកឲ្យទៅកាន់ភ័ស្តុភារនៅកងពល៩២០ សាន ជាប្រធានកងពល៩២០ ឈរជើងនៅខេត្តមណ្ឌលគិរី ។ ចំណែក ទឹម ដែលធ្លាប់ជាអ្នកបើកឡានឲ្យ ឆេង ត្រូវបានចាត់តាំងឲ្យធ្វើជាសមាជិកនៃមន្ទីរសន្តិសុខអូរកន្សែង ។


ជិន គឹមថុង

ជិន គឹមថុង ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលស្និទ្ធនឹង សូ សារឿន (ហៅ ០៥) ប្រធានកងពល ៨០១ ។ មុនឆ្នាំ១៩៧៧ គឹមថុង មានឋានៈជាប្រធានផ្នែកវិទ្យុទាក់ទងរបស់កងពល៨០១ ដែលជាកន្លែងសម្រាប់ទាក់ទងទៅវរសេនាធំក្រោមឱវាទ និងអគ្គសេនាធិការកងទ័ពរបស់ សុន សេន ។ ក្នុងអំឡុងខែមេសា ឆ្នាំ ១៩៧៧ គឹមថុង ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរសន្តិសុខអូរកន្សែង ហើយក្រោយនោះបន្តិចក៏ក្លាយទៅជាអនុប្រធានមន្ទីរសន្តិសុខអូរកន្សែង ដែលមាន ឆោម សែ ជាប្រធាន ។ គឹមថុង បញ្ជាក់ថា ពេលទៅដល់ភ្លាម គាត់ឃើញ ឆេង (ដែលពេលនោះនៅជាប្រធានមន្ទីរសន្តិសុខអូរកន្សែងនៅឡើយ) កំពុងសួរចម្លើយកូនទាហានប្រមាណ១០នាក់ នៅក្នុងរោងឡានមួយក្បែរភ្នំស្វាយ ។ ទៅបានមួយសប្តាហ៍ ឆោម សែ ក៏ទៅដល់ទីនោះដែរ ហើយ ឆេង ត្រូវផ្លាស់ទៅកាន់ភ័ស្តុភារនៅកងពល ៩២០ ។

## ការចាប់ខ្លួន

អ្នកទោសត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែងជាបន្តបន្ទាប់ ។ ជន ថុល បញ្ជាក់ថា ជនជាតិចារាយរាប់រយនាក់មានទាំងកូនក្មេង និងមនុស្សចាស់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង ។ អ្នកទោសទាំងនោះត្រូវបានដឹកតាមឡាន បន្ទាប់មកត្រូវកងសន្តិសុខចងខ្សែជាប់ៗគ្នាបណ្តើរមកដល់មន្ទីរសន្តិសុខ ។ ការចាប់ខ្លួននេះធ្វើក្រោយការចាប់ខ្លួនជនថុល ប្រមាណជា១ខែ ។ ក្រៅពីនេះ គឺមានការចាប់ខ្លួនអ្នកទោសមកពីស្រុកលំផាត់ ស្រុកវើនសៃ កម្មករធ្វើការនៅចម្ការកៅស៊ូ ហើយមួយចំនួនមកពីកងទ័ព ។ ជិន គឹមថុង បញ្ជាក់ថា យោធាខ្មែរក្រហមមួយចំនួននៅក្នុងកងពល៨០១ ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង បន្ទាប់ពីមានការចាប់ខ្លួន ឡាយ សារឹម, ស៊ិន ទី ហៅ ទាញ, និង សោម ។ ចំណែកការចាប់ខ្លួនកម្មករធ្វើការនៅចម្ការកៅស៊ូ គឺធ្វើតាមរយៈឈ្មោះ ទុំ ប្រធានសហជីពចំការកៅស៊ូ ។ គឹមថុង បញ្ជាក់បន្ថែមថា ក្រុម ហ្វូលរ៉ូ រណសិរ្សឯកភាព បណ្តាជនជាតិភាគតិច (រួមមាន ជនជាតិចាម ខ្មែរកម្ពុជាក្រោម និងជនជាតិចារ៉ាយជាដើម ដើម្បីធ្វើការតស៊ូរំដោះខ្លួនចេញពីការជិះជាន់គាបសង្កត់ពីសំណាក់វៀតណាម) ជាង១០០នាក់ក៏ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែងដែរ ហើយខ្លួនបានលើកយកបញ្ហាឃុំខ្លួនអ្នកទាំងនោះប្រាប់ សុន សេន ដោយផ្ទាល់ ។ យើងពុំទាន់មានព័ត៌មានសម្រាប់ផ្ទៀងផ្ទាត់មើលថាតើក្រុម ហ្វូលរ៉ូ ដែល ជិន គឹមថុង បានលើកឡើង គឺជាប្រជាជនចារ៉ាយ ដែល ជន ថុល បានផ្តល់សក្ខីកម្មជូនតុលាការ ឬយ៉ាងណានោះទេ ។

## ការសួរចម្លើយអ្នកទោស

ជន ថុល បញ្ជាក់ថា អ្នកទោសត្រូវកងសន្តិសុខនាំយកទៅសួរចម្លើយម្តងម្នាក់ៗ នៅក្នុងបន្ទប់បិទជិតមួយក្នុងស្ថានភាពជើងជាប់ច្រវ៉ាក់ និងដៃចងជាប់គ្នា ។ អ្នកទោសមួយចំនួនត្រូវបានធ្វើទារុណកម្មយ៉ាងដំណំដោយសារមិនឆ្លើយទៅតាមអ្វីដែលអ្នកសួរ

ចង់បាន ។ ថុល បញ្ជាក់ថា អ្នកទោសម្នាក់មកពីស្រុកបរកែវ ត្រូវអ្នកសួរចម្លើយយកដែកកាប់ចាប់ក្ដៅស្រែករហូតដល់សន្លប់ ។ ស្អែកឡើងអ្នកទោសនោះបាត់ខ្លួនរហូត ។ អ្នកទោសខ្លះទៀតត្រូវគេវាយ ឬឆក់ខ្សែភ្លើង ដើម្បីទទួលបានចម្លើយ ។ បើតាមការបញ្ជាក់របស់ ចាន់ឌី អ្នកទោសស្ត្រីគឺមិនត្រូវបានគេធ្វើទារុណកម្មឡើយ ពោលគឺទារុណកម្មភាគច្រើន ធ្វើតែចំពោះអ្នកទោសដែលជាបុរសប៉ុណ្ណោះ ។

ចម្លើយសារភាពអ្នកទោសត្រូវបាន ជិន គីមថុន ធ្វើរបាយការណ៍បញ្ជូនទៅ សូ សារឿន ប្រធានកងពល ៨០១ ។ ជិនគីមថុន បញ្ជាក់ថា ដោយសារធ្លាប់ធ្វើការនៅមន្ទីររបស់កងពល ដូច្នេះ ខ្លួនធ្វើការរាយការណ៍ផ្ទាល់ៗទៅ សូ សារឿន ។ ឆោម សែ ពុំសូវទៅរាយការណ៍ទេ ព្រោះនិយាយមិនបានក្បោះក្បាយ ។

### ការឃុំឃាំងអ្នកទោស

ជន ថុល បញ្ជាក់ថា អ្នកទោសត្រូវបានដាក់ខ្នោះជើង ដោយប្រើប្រវាក់ (ឬដែកសសៃ) ឲ្យដេកតម្រៀបគ្នានៅលើគ្រែឬស្សី ហើយខ្លះត្រូវដេកផ្ទាល់នឹងដី ។ ចំពោះអ្នកទោសជាស្ត្រី ឬកុមារ គឺមិនត្រូវបានគេដាក់ខ្នោះនោះទេ ប៉ុន្តែត្រូវបានដាក់ក្នុងបន្ទប់មួយដោយចាក់សោ និងមានកងសន្តិសុខយាមពីខាងក្រៅ ។ បើអ្នកទោសចង់បន្ទោរបង់ ត្រូវបន្ទោរបង់ដាក់បំពង់ឬស្សីដែលត្រូវបានដាក់នៅក្បែរខ្លួន ពោលគឺមិនអាចចេញទៅបន្ទោរបង់នៅក្រៅបន្ទប់ឃុំឃាំងបានឡើយ ។ អ្នកទោសមួយចំនួនមានជំងឺរាករូសស្លាប់នៅក្នុងមន្ទីរឃុំឃាំងទាំងជើងជាប់ខ្នោះ ។

### ការសម្លាប់អ្នកទោស

ជន ថុល បញ្ជាក់ថា បន្ទាប់ពីសួរចម្លើយរួច អ្នកទោសមួយចំនួនត្រូវសម្លាប់ចោល ដោយគេចោទថាជាភ្នាក់ងារ សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ។ អ្នកទោសខ្លះទៀតត្រូវគេសម្លាប់ចោលដោយសារមិនបានគោរពតាមវិន័យរបស់មន្ទីរសន្តិសុខ ។ វិន័យដ៏ម៉ឺងម៉ាត់នោះគឺ មិនឲ្យលួចរត់ ឬលួចអាហារបរិភោគ ។ ថុល នៅចាំថាអ្នកទោសម្នាក់ត្រូវឈ្មោះ ទីន បាញ់សម្លាប់ដោយសារគាត់បានលួចចេញទៅរកបាយអ្នកភូមិហូប ។ អ្នកទោសម្នាក់ទៀតត្រូវគេសម្លាប់ដោយសារគាត់បានលួចគ្រាប់ធូរ៉េនមកដុតហូប ។ រីឯអ្នកទោសស្ត្រីម្នាក់ទៀតត្រូវកងសន្តិសុខឈ្មោះ ញ៉ុក សម្លាប់វះយកប្រម៉ាត់ ដោយរងការចោទប្រកាន់ថាបានប្រព្រឹត្តខុសសីលធម៌ពេលធ្វើការនៅសហជីពចម្ការកៅស៊ូ ។


មឿង ចាន់ឌី

មឿង ចាន់ឌី បញ្ជាក់បន្ថែមថា តាអួយ ក៏ជាកងសន្តិសុខ និងជាជនដៃដល់ម្នាក់ក្នុងការសម្លាប់អ្នកទោសដែរ ។ គាត់ឃើញតាអួយវាយអ្នកទោសស្ត្រីម្នាក់នឹងត្បូងចបរហូតដល់ស្លាប់ ។ ទាក់ទងនឹងអ្នកទោសជនជាតិចារ៉ាយវិញ ចាន់ឌី រៀបរាប់ថា ក្រោយពីការសួរចម្លើយបានមួយសប្ដាហ៍ អ្នកទោសទាំងនោះត្រូវកងសន្តិសុខមកប្រាប់ថាឲ្យទៅស្រុកកំណើតវិញ ។ កងសន្តិសុខចាប់ចងអ្នកទោសទាំងនោះបន្តៗគ្នា ហើយបណ្ដើរយកចេញទៅបាត់រហូត ។ ចាន់ឌី ជឿថាជនជាតិចារ៉ាយទាំងនោះត្រូវគេសម្លាប់ចោល នៅក្នុងចម្ការខ្នុរក្បែរមន្ទីរសន្តិសុខអូរកន្សែង ព្រោះរបស់របរប្រើប្រាស់ និងសម្លៀកបំពាក់របស់ជនជាតិចារ៉ាយទាំងនោះត្រូវគេឃើញនៅមាត់រណ្ដៅកប់សាកសពរួមដែលទើបត្រូវគេលុបថ្មីៗ ។ ថុល ក៏បានបញ្ជាក់ស្រដៀងគ្នានេះដែរ ។

ជិនគីមថុន បញ្ជាក់ថា ក្រុម ហ្វូលរ៉ូ ដែលចាប់មកឃុំនៅមន្ទីរសន្តិសុខអូរកន្សែង គឺត្រូវបានសម្លាប់ចោលទាំងអស់ ។ គីមថុន ឃើញ ឆោម សែ វាយសម្លាប់អ្នកទោសដោយប្រើដំបង ។ ចំពោះអ្នកទោសមួយចំនួនទៀតត្រូវកងសន្តិសុខបាញ់សម្លាប់ចោលក្នុងអំឡុងពេលកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា ។ ជន ថុល បញ្ជាក់ថា បន្ទាប់ពីទទួលដំណឹងថាកងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា អ្នកទោសនៅមន្ទីរសន្តិសុខអូរកន្សែងត្រូវបានខ្មែរក្រហមជម្លៀសយកទៅជាមួយ ។ អ្នកទោសដែលមានជំងឺធ្វើដំណើរមិនកើតត្រូវកងសន្តិសុខ "កម្ទេច" ចោល ។ ជនថុល ត្រូវកងសន្តិសុខជម្លៀសយកទៅដល់ទន្លេសេសានក្នុងខេត្តស្ទឹងត្រែង ហើយត្រូវបានដោះលែងឲ្យរួចខ្លួននៅពេលកងសន្តិសុខទាំងនោះទទួលដំណឹងថាកងទ័ពវៀតណាមស្នាក់ចាំនៅមុខទន្លេនោះ ។ **ចាន់ ប្រាថ្នា**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

**សេចក្តីថ្លែងការណ៍**
**របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤**

នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍លើជនជាតិចាម
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ"ប្រជាជន ១៧ មេសា" អតីតទាហានលន់ នល់ កម្មាភិបាលភូមិភាគកណ្តាល (ឧត្តរចាស់) គ្រួសាររបស់ពួកគេ អ្នកក្រោមបង្គាប់របស់ពួកគេ ប្រជាជនមកពីភូមិភាគបូព៌ា "សមាសភាពមិនល្អ" និង"ខ្មាំងផ្ទៃក្នុង" ការធ្វើទុក្ខបុកម្នេញមកលើប្រជាជនចាម និងប្រជាជនវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត រួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភលើផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ ការធ្វើបាបរាងកាយ ពលកម្មដោយបង្ខំ និងការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌
- ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ រួមមាន មនុស្សឃាតដោយចេតនា។

ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានចោទថាបានប្រព្រឹត្តឡើងនៅការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ ទីកន្លែងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប(គរ) មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សទួលបេង និងវត្តអង្គញជីមន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ ទីកន្លែងសម្លាប់មនុស្សភ្នំប្រុស មន្ទីរសន្តិសុខវត្តតាមះ មន្ទីរសន្តិសុខចម្ការស្វាយចន្ទី មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក មន្ទីរសន្តិសុខវត្តស្រង៉ែ និងទីតាំងផ្សេងៗនៅក្នុងខេត្តកំពង់ចាម។

បទចោទប្រកាន់ដែលបានប្រកាសនៅថ្ងៃនេះ រាប់បញ្ចូលទាំងបទចោទប្រកាន់ថ្មី ទាំងបទចោទប្រកាន់ពីមុនដែលបានធ្វើឡើងរួចហើយនៅពេលដែល អោ អាន ចូលបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។ ចាប់តាំង

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ
www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

ពីការ បង្ហាញខ្លួនលើកដំបូងមក អោ អាន តាមរយៈសហមេធាវីរបស់គាត់ ត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន** **លោក នេត្រ ភក្ត្រា**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់ មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរសព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩ទូរសព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
**សារអេឡិចត្រូនិក:** olsenl@un.org **សារអេឡិចត្រូនិក:** neth.pheaktra@eccc.gov.kh

# ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង៖ ការជំរុញឱ្យមានការផ្សះផ្សានៅក្នុងសហគមន៍

ក្រុមទីមួយនៃសិស្ស-និស្សិត ដែលបានទៅទស្សនាសហគមន៍អន្លង់វែង គឺជាផ្នែកមួយនៃកម្មវិធីដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានចាប់ផ្ដើមដំបូងពីថ្ងៃ១៥ -១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញឲ្យមានការផ្សះផ្សាតាមរយៈការយល់ដឹងពីប្រវត្តិសាស្ត្រ និងការអត់ឱន ។ កម្មវិធីទស្សកិច្ចរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលមានសិស្សជាច្រើនក្រុមមកពីសាកលវិទ្យាល័យនានានៅទូទាំងប្រទេសកម្ពុជា ត្រូវបានរៀបចំដើម្បីតភ្ជាប់ឡើងវិញនូវការបែងចែក និងភាពឯកោ រវាងអតីតសមាជិកក្រុមខ្មែរក្រហម និងក្មេងជំនាន់ក្រោយ ។ អ្នកចូលរួមកម្មវិធីដំណើរទស្សនកិច្ចនេះ ត្រូវធ្វើដំណើរក្នុងប្រវែងផ្លូវដ៏វែងឆ្ងាយពីភ្នំពេញ ទៅខេត្តបាត់ដំបង រួចបន្តទៅអតីតតំបន់រឹងមាំនៃចលនាខ្មែរក្រហម ជាទីកន្លែងដែលមនោគមវិជ្ជា ចិត្តគំនិត និងការកើតឡើងជាថ្មីនៃចលនាខ្មែរក្រហម ដែលគួរតែត្រូវបានពិនិត្យមើលឲ្យទូលំទូលាយ ឆ្លុះបញ្ចាំង និងវិភាគឲ្យបានស៊ីជម្រៅ ។

របាយការណ៍នេះ នឹងផ្ដោតទៅលើការគិតពិចារណា និងការរំពឹងទុកដែលអ្នកចូលរួមត្រូវចងចាំមុនពេលដំណើរទស្សនកិច្ចសិក្សា ។ បន្ទាប់មក របាយការណ៍នេះនឹងផ្ដោតទៅលើសារសំខាន់នៃការធ្វើបទបង្ហាញផ្សេងៗនៅក្នុងថ្ងៃបន្តបន្ទាប់ ដែលក្នុងនោះអ្នកចូលរួមទទួលបាននូវមេរៀនមួយចំនួន ដូចជា មូលហេតុដែលនាំឲ្យកើតជម្លោះ, អំពើហិង្សា, សន្តិភាព និងការផ្សះផ្សា, ប្រវត្តិនៃចលនាខ្មែរក្រហម និងសហគមន៍អន្លង់វែងតែម្ដង ។ ទ្រឹស្ដីដែលបានបង្ហាញនៅក្នុងមេរៀននេះ បានជួយលើកកម្ពស់សមត្ថភាពអ្នកចូលរួមទាំងអស់ដើម្បីឲ្យមានការពិភាក្សាក្នុងចំណោមមនុស្សពីមួយជំនាន់ទៅមួយជំនាន់ ពីសហគមន៍មួយទៅសហគមន៍មួយទៀតជាមួយអតីត




សិស្ស-និស្សិត មកជួបជុំ និងទទួលការណែនាំបន្ថែមពីក្រុមការងារគម្រោងដំណើរទស្សកិច្ចសិក្សាទៅតំបន់អន្លង់ នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលដើម្បីការអភិវឌ្ឍន៍ជានិរន្តភាព ស្ថិតនៅភូមិអូរគគីកណ្ដាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ មុនចេញទៅទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែង

សមាជិកខ្មែរក្រហម និងជនរងគ្រោះ ។ ការពិភាក្សារបស់អ្នកចូលរួមម្នាក់ៗ នឹងត្រូវបានកត់ត្រានៅក្នុងទម្រង់ជាបទសម្ភាសន៍ដូច្នេះហើយ អត្ថបទមួយគួរត្រូវបានសរសេរឡើងដើម្បីបោះពុម្ពផ្សាយ ។ ក្រៅពីកិច្ចការទាំងនេះ សិស្ស និស្សិត ត្រូវបានលើកទឹកចិត្តឲ្យធ្វើការផ្ទាល់ខ្លួនដើម្បីឆ្លុះបញ្ចាំងទៅលើប្រធានបទទាក់ទងនឹងរបបខ្មែរក្រហម មានដូចជា អំពើប្រល័យពូជសាសន៍ សង្គ្រាមស៊ីវិល កេរដំណែលវប្បធម៌ និងកម្មវិធីធ្វើធម្មយាត្រាសន្តិភាព ។

## អ្នកចូលរួម

អ្នកចូលរួមមានចំនួន១៣នាក់ ដែលមកពីប្រវត្តិគ្រួសារខុសៗគ្នា និងកម្រិតសិក្សាខុសគ្នា ។ អ្នកចូលរួមខ្លះ គឺជាកូនរបស់អតីតសមាជិកខ្មែរក្រហម ដូច្នេះហើយ របាយការណ៍នេះផ្តោតទៅលើការឆ្លើយតបរបស់អ្នកចូលរួមទៅនឹងសំណួរស្ទាបស្ទង់ទី៤ (ក្នុងចំណោមសំណួរស្ទាបស្ទង់ចំនួន៧) ទៅលើគំនិតរបស់សិស្ស និស្សិតទាំងនោះទៅលើពាក្យអតីតសមាជិកខ្មែរក្រហម និងថាតើពួកគេរើសអើងចំពោះកូនៗរបស់អតីតសមាជិកខ្មែរក្រហមឬទេ? អ្នកចូលរួមចំនួន៥នាក់បានឆ្លើយថា ពួកគេមានអារម្មណ៍ធម្មតាជាមួយអតីតសមាជិកខ្មែរក្រហម ។ រីឯអ្នកចូលរួមចំនួន៥នាក់ផ្សេងទៀត បានរៀបរាប់នូវពាក្យ "ភ័យខ្លាច" ។ មានអ្នកចូលរួមតែម្នាក់ប៉ុណ្ណោះ បានសង្កត់ធ្ងន់ថា នាងមិនចង់រំឭករឿងនេះឡើងវិញទេ ហើយអ្នកចូលរួមម្នាក់ទៀតសរសេរថា នាងប្រាថ្នារៀនសូត្រឲ្យបានកាន់តែច្រើនពីរឿងរ៉ាវសម័យខ្មែរក្រហម ។ ទោះបីយ៉ាងណា អ្នកចូលរួមទាំងអស់មិនបានផ្តល់អនុសាសន៍លើសំណួរទាក់ទងនឹងរបបខ្មែរក្រហមទេ ។ អ្នកចូលរួមបានផ្តល់នូវគំនិតរៀងខ្លួនដើម្បីពន្យល់ថា ហេតុអ្វីបានជាពួកគេគិតដូច្នេះ ទាក់ទងនឹងរឿងរ៉ាវខ្មែរក្រហម ។

ទី១) អ្នកចូលរួមចំនួន៣នាក់ ក្នុងចំណោមអ្នកចូលរួមទាំងអស់ដែលបានឆ្លើយថា "ពួកគេមានអារម្មណ៍ធម្មតា" មកពីសហគមន៍អន្លង់វែងផ្ទាល់ ដែលឪពុកម្តាយរបស់ពួកគេជាអតីតខ្មែរក្រហម ឬមិត្តភក្តិរបស់ពួកគេជាកូនរបស់អតីតខ្មែរក្រហម ។ ពួកគេជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យអន្លង់វែង ។ ស៊ុម វីរៈ អាយុ១៨ឆ្នាំ បានលើកឡើងនូវគំនិតពីអតីតសមាជិកខ្មែរក្រហមថា ជាប្រភពឯកសារដ៏មានតម្លៃដើម្បីសិក្សាពីរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-៧៩) និងសង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧៩ - ១៩៩៨) ។ ទោះបីយ៉ាងណា ញ៉ែម បរមី ដែលមិត្តភក្តិរបស់នាងជាកូនរបស់អតីតសមាជិកខ្មែរក្រហម បានសម្តែងនូវការកោតសរសើរចំពោះការតស៊ូខិតខំប្រឹងប្រែងរបស់ពួកគាត់ដើម្បីរស់ក្នុងសម័យកាលវឹកវរដែលប្រទេសយើងបានឆ្លងកាត់ ។ ឈឿន ឆៃលីន អាយុ១៨ឆ្នាំ បានសរសេរថា ការរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហមធ្វើឲ្យនាងជឿជាក់ថា អតីតសមាជិកខ្មែរក្រហមជាច្រើន បានសម្តែងចេញក្នុងភាពជាមនុស្សដល់អ្នកដទៃ ។ គំនិតរបស់នាង គឺថា មិនមែនខ្មែរក្រហមទាំងអស់សុទ្ធតែអាក្រក់នោះទេ ។ អ្នកចូលរួមពីនាក់ទៀតក៏លើកឡើងដូចទៅនឹងការសរសេររបស់ ឆៃលីន ដែរ ដោយសង្កត់ធ្ងន់ថា ពួកគេមិនភ័យខ្លាច និងចងកំហឹងជាមួយអតីតខ្មែរក្រហមទេ បន្ទាប់ពីពួកគេបានសិក្សា និងពិភាក្សាលើប្រធានបទជាច្រើនជាប់ទាក់ទងនឹងខ្មែរក្រហម ។ ពួកគេចាប់ផ្តើមដឹងអំពីកាលៈទេសៈដែលនាំឲ្យអតីតសមាជិកខ្មែរក្រហមទាំងនោះ សម្តែងចេញនូវការប្រឆាំងជាមួយឆន្ទៈផ្ទាល់ខ្លួន នៅត្រង់ចំណុចមួយចំនួន ។ ពួកគេបាននិយាយនៅក្នុងអារម្មណ៍ស្រដៀងគ្នាថា ពួកគេមិនមានហេតុផលអ្វីដើម្បីរើសអើងចំពោះកូនៗរបស់អតីតខ្មែរក្រហមទាំងអស់នោះទេ ។

ទី២) ចំពោះអ្នកដែលបានឆ្លើយថា "ភ័យខ្លាច" គឺចេញពីទម្លាប់នៃការគិតរបស់ពួកគេដែលថា អតីតខ្មែរក្រហមទាំងអស់បានទាក់ទងនឹងការសម្លាប់រង្គាលក្នុងសម័យខ្មែរក្រហម ។ ទាំងឡាយ កក្កដា ដែលមានអាយុ២២ឆ្នាំ ជានិស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង សាំង ចុង អាយុ២៥ឆ្នាំ ជានិស្សិតសាកលវិទ្យាល័យបាត់ដំបងបានសម្តែងចេញនូវយោបល់ដូចនេះ ប៉ុន្តែបានបង្ហាញពីការត្រៀមខ្លួនរបស់ពួកគេដើម្បីសិក្សាពីរឿងរ៉ាវកាប់សម្លាប់របស់ខ្មែរក្រហមថែមទៀត ។ អ្នកចូលរួមពីនាក់ផ្សេងទៀត គឺកញ្ញា ហិន ចិត្រា អាយុ២៤ឆ្នាំ និងកញ្ញា សុក គឹមសី អាយុ២២ឆ្នាំ ដែលទាំងពីរនាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានលើកឡើងនូវពាក្យ "ភ័យខ្លាច និងស្អប់" ចំពោះអតីតសមាជិកខ្មែរក្រហម ។ ក្រោយមកពួកគេបានផ្លាស់ប្តូរនូវការគិតបន្ទាប់ពីពួកគេទទួលបាននូវការបណ្តុះបណ្តាល និងបានស្តាប់នូវការធ្វើបទបង្ហាញជាបន្តបន្ទាប់អំពីរបបខ្មែរក្រហម ។ យី ភត្រ្តា អាយុ២២ឆ្នាំ មកពីវិទ្យាស្ថានភាសាបរទេស បានលើកឡើងនូវទស្សនៈស្រដៀងគ្នាជាមួយកញ្ញា ហិន ចិត្រា និង សុក គឹមសី ដែរ ។ ទោះបី

យ៉ាងណា កញ្ញា ជិម សុកហៀប អាយុ១៩ឆ្នាំ មកពីសាកលវិទ្យាល័យបាត់ដំបង បានពន្យល់ថា "ខ្ញុំមានអារម្មណ៍ថា ពួកគេ (អតីតសមាជិកខ្មែរក្រហម) គឺសាហាវឃោរឃៅ រួមមាន ធ្វើបាប, ធ្វើទារុណកម្ម និងសម្លាប់ប្រជាជនដោយមិនរើសមុខ និងដោយគ្មានការពិចារណា ។ ចេញពីប្រវត្តិគ្រួសារ និងទស្សនៈផ្សេងគ្នា កម្មវិធីទស្សនកិច្ចសិក្សាទៅកាន់តំបន់អន្លង់វែង ត្រូវបានរៀបចំឡើងដើម្បីផ្តល់ឲ្យសិស្ស និងនិស្សិតនូវឱកាសដើម្បីបង្ហាញ និងបញ្ចេញនូវគំនិតផ្ទាល់ខ្លួន ។

## ***សកម្មភាពដំណើរទស្សនកិច្ច***

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ កម្មវិធីទស្សនកិច្ចសិក្សាទៅកាន់តំបន់អន្លង់វែង បានចាប់ផ្តើម ។ កញ្ញា មីន សាណាស់ អ្នកសម្របសម្រួលកម្មវិធីបានផ្តល់នូវការណែនាំខ្លីអំពីកម្មវិធីទៅដល់អ្នកចូលរួមម្នាក់ៗ និងបានណែនាំពួកគេឲ្យស្គាល់គ្នា ។ នៅខេត្តបាត់ដំបង សាណាស់ បាននាំអ្នកចូលរួមទៅទស្សនាប្រាសាទឯកភ្នំ ។ នៅថ្ងៃទីពីរ គឺថ្ងៃទី១៦ ខែកុម្ភៈ បទបង្ហាញជាច្រើនត្រូវបានរៀបចំឡើងដើម្បីផ្តល់ដល់អ្នកចូលរួមនូវចំណេះដឹងជាមូលដ្ឋាននៃមូលហេតុដែលនាំឲ្យកើតមានជម្លោះ អំពើហិង្សា និងសន្តិភាព ។ អ្នកចូលរួមក៏បានរៀនសូត្រពីរបៀបសម្ភាសន៍ សរសេរអត្ថបទ និងរៀនសូត្រអំពីទីតាំងប្រវត្តិសាស្ត្រចំនួន១៨កន្លែង នៅតំបន់អន្លង់វែង និងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងតំបន់អន្លង់វែង ក្នុងរបបខ្មែរក្រហម និងសង្គ្រាមស៊ីវិល ។ ទោះបីជាយ៉ាងណា ដោយសារកម្មវិធីច្រើន ហើយត្រូវចំណាយពេលច្រើនដូច្នេះយើងបានសង្ខេបដោយផ្តោតតែទៅលើរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-៧៩) និងកម្មវិធីទស្សនកិច្ចសិក្សាទៅកាន់តំបន់អន្លង់វែង នៅថ្ងៃអនាគតដែលនឹងត្រូវរៀបចំឲ្យបានគ្រប់ជ្រុងជ្រោយលម្អិតជាងនេះ ដើម្បីផ្តល់ឲ្យអ្នកចូលរួមនូវរូបភាពទាំងមូលនៃតំបន់ប្រវត្តិសាស្ត្រអន្លង់វែង មុននឹងទៅទស្សនាសហគមន៍អន្លង់វែង ។

វាគ្មិនពីរនាក់ដែលរស់នៅក្នុងសហគមន៍អន្លង់វែង ត្រូវបានអញ្ជើញឲ្យមកនិយាយប្រាប់ទៅដល់អ្នកចូលរួម ទី១) លោក ថូ លន់ អាយុ៥៦ឆ្នាំ ជាអតីតយោធា និងជាមេភូមិ បន្ទាប់ពីខ្មែរក្រហមបានធ្វើសមាហរណកម្មក្នុងឆ្នាំ១៩៩៨ ។ សព្វថ្ងៃគាត់រស់នៅភូមិអូរគគីរកណ្តាល ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ លន់ បាននិយាយផ្តោតសំខាន់ទៅលើហេតុផលដែលនាំឲ្យគាត់ចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម, ការចូលបម្រើចលនាខ្មែរក្រហមស្ទើរតែអស់មួយជីវិតរបស់គាត់, ការក្លាយទៅជាមេភូមិ និងការរស់នៅដោយជីវិតសាមញ្ញជាមួយក្រុមគ្រួសារ ។ លន់ បានរៀបរាប់ដូចខាងក្រោមៈ

នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំនៅក្មេងនៅឡើយ ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានទម្លាក់ពីអំណាចដោយរដ្ឋប្រហាររបស់ លន់ នល់ ។ ការឈឺចាប់ និងបទពិសោធន៍របស់ខ្ញុំបានកើតឡើងភ្លាមៗចាប់តាំងពីពេលនោះមក ។ នៅសម័យនោះ ក្មេងដែលមានអាយុដូចខ្ញុំ មិនមានឱកាសដូចសព្វថ្ងៃទេ ។ នៅពេលខ្ញុំនៅក្មេង ខ្ញុំបានត្រឹមតែកាន់អាវុធប៉ុណ្ណោះ ។ ប្រជាជនត្រូវបានបែងចែកទៅក្រុមផ្សេងៗ ។ ឃុំរបស់ខ្ញុំរស់នៅ ត្រូវបានចាត់ទុកថាជាតំបន់ដែលបានរំដោះដោយខ្មែរក្រហម ។ ដោយសារសង្គ្រាមឆាបឆេះឡើង និងការទម្លាក់គ្រាប់បែក ប្រជាជនមានការភិតភ័យយ៉ាងខ្លាំង ។ នៅក្នុងអំឡុងឆ្នាំ១៩៧៣-៧៤ ខ្ញុំបានក្លាយទៅជាយោធាខ្មែរក្រហមដោយទទួលខុសត្រូវការពារភូមិឃុំ ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមឡើងកាន់អំណាច ។ ជីវិតបានត្រឡប់ទៅភាពទុរ្ភិក្ស ។ ប្រជាជនគ្មានសិទ្ធិសេរីភាព និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ នៅក្នុងរបបនោះមានវិន័យតឹងរ៉ឹង ។ ការអប់រំត្រូវបានផ្តល់ឲ្យជាមួយភាពភ័យខ្លាច ។ ការប្រជុំប្រចាំថ្ងៃ បានធ្វើឡើងជាប្រចាំ ។ នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅស្រុកពួក ។ ដោយសារការអត់ឃ្លាន នៅទីនោះ ខ្ញុំបានភៀសខ្លួនទៅខេត្តឧត្តរមានជ័យ ជាទីកន្លែងដែលខ្ញុំបានចូលបម្រើជានីរសារ ចន្លោះពីស្រុកបន្ទាយអំពិល អន្លង់វែង និង ចុងកាល់ ។ ខ្ញុំបានជិះកង់ ជិះសេះ និងក្រោយមកបានជិះម៉ូតូ នៅពេលរត់សំបុត្រ ។ នៅក្នុងឆ្នាំ១៩៧៨ មានប្រជាជន៥០០នាក់ រួមទាំងខ្ញុំ ត្រូវបានជ្រើសរើសឲ្យទៅដាំបន្លែ ។ ប្រធានកងបានណែនាំដល់ប្រជាជនទាំងនេះឲ្យដាំស្ពៃដែលជាតម្រូវការពេញមួយឆ្នាំ ។ នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ សភាពការណ៍មានការតឹងតែង ។ កងទ័ពវៀតណាម ដែលសហការជាមួយកងទ័ពដែលរត់គេចខ្លួន បានរៀបចំបណ្តេញខ្មែរក្រហមពីអំណាច ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ នៅពេលកងទ័ពវៀតណាមទៅដល់សំរោង មេបញ្ជាការកងទ័ពទាំងអស់

ត្រូវបានរៀបចំជាក្រុម និងបានបំពាក់អាវុធឡើងវិញ នៅក្នុងស្រុកបន្ទាយអំពិល ។ ក្រោយឆ្នាំ១៩៧៩ ខ្ញុំបានបម្រើជាយោធាខ្មែរក្រហម ។ ជីវិតរបស់ខ្ញុំ គឺស្ថិតនៅក្រោមបញ្ជារបស់មេបញ្ជាការកងទ័ព ។ នៅឆ្នាំ១៩៨០ ខ្ញុំបានផ្លាស់ទៅមុំបី តំបន់ត្រីកោណ (រួមមានខ្មែរ ថៃ និង ឡាវ) ។ នៅក្នុងឆ្នាំ១៩៨១ ខ្ញុំបានផ្លាស់ទៅខេត្តកំពង់ចាម និងបានរស់នៅទីនោះរហូតដល់ឆ្នាំ១៩៨៦ ។ រយៈពេល៦ឆ្នាំក្រោយមក ខ្ញុំបានដើរត្រឡប់មកអន្លង់វែងវិញ ។ នៅពេលវៀតណាមដកកងទ័ព នៅឆ្នាំ១៩៨៩ ខ្មែរក្រហមចាប់ផ្តើមវាយប្រហារគ្រប់គ្រងតំបន់អន្លង់វែង និងតំបន់ខ្មែរក្រហមផ្សេងទៀត ។ គ្រប់ពេលនៃជីវិតរបស់ខ្ញុំត្រូវស្តាប់តាមបញ្ជា ។ ជីវិតនៅពេលនោះ ពោរពេញទៅដោយភាពភ័យខ្លាច និងតក់ស្លុត ។ នៅក្នុងឆ្នាំ១៩៩០ ខ្ញុំបាត់បង់ដៃស្តាំម្ខាង ។ នៅក្នុងឆ្នាំ១៩៩៦ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិ ។ តាមការយល់ឃើញរបស់ខ្ញុំ អតីតសមាជិកខ្មែរក្រហមមានការរួបរួម និងសហការគ្នាណាស់ ។ នៅសម័យនោះមិនមានចោរលួច អំពើពុករលួយ និងការកេងប្រវ័ញ្ចទេ ។ ប្រជាជនបានជួយគ្នាទៅវិញទៅមក ដោយចែកម្ហូបអាហារគ្នា ។ ប្រសិនបើនរណាម្នាក់ឈឺ ប្រជាជនបានសែងអ្នកជំងឺនោះទៅមន្ទីរពេទ្យ ។ ទាក់ទងទៅនឹងការត្រឡប់ទៅភូមិកំណើតរបស់ខ្ញុំ អ្នកភូមិមិនបានស្វាគមន៍ និងរាក់ទាក់ខ្ញុំទេ ។ បន្ទាប់ពីសមាហរណកម្ម យើងមានសន្តិភាព សេរីភាព និងឯករាជ្យភាព ។ ខ្ញុំសម្រេចចិត្តរស់នៅទីនេះ ។ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ មូលហេតុសន្តិសុខបានគំរាមកំហែងប្រជាជន ។ ការប្លន់ប្រដាប់អាវុធ និងចោរកម្ម បានកើតឡើងនៅក្នុងភូមិ ។

នៅពេលរសៀល បទបង្ហាញពីទីតាំងប្រវត្តិសាស្ត្រទាំង១៤កន្លែងត្រូវបានធ្វើឡើង ហើយបន្ទាប់មក អ្នកស្រី សាន រ៉ែន ក៏ឡើងមកនិយាយ ។ រ៉ែន មានអាយុ៥៦ឆ្នាំ ជាអតីតយោធាខ្មែរក្រហម បាននិយាយពីជីវិត និងការតស៊ូស្លាប់រស់ជាមួយខ្មែរក្រហមពិសេសបន្ទាប់ពីឆ្នាំ១៩៧៩ ។ រ៉ែន បានពន្យល់ថា ៖

នៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានដើរទៅស្រុកស្នួល ។ ខ្ញុំដេកនៅតាមព្រៃ ។ វិន័យផ្តាច់ការបានបន្តអនុវត្តនៅពេលនោះ ។ យើងបានលាក់ខ្លួននៅក្នុងព្រៃ ។ មានស្ត្រីចំនួន៣០នាក់ប៉ុណ្ណោះ ក្នុងចំណោមស្ត្រីរាប់រយនាក់ ដែលនៅរស់រានមានជីវិត ។ យើងហូបបបរលាយជាមួយល្ពៅ និងដើមចេក ។ យើងបានជីកលេណដ្ឋានដើម្បីការពារទីតាំងរបស់យើងនៅក្នុងព្រៃ ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ការបែងចែករវាងស្រី និងប្រុសនៅតែអនុវត្ត ។ ក្រោយឆ្នាំ១៩៧៩


(រូបកណ្តាល) លោក លី សុខឃាង ប្រធានគម្រោងដំណើរទស្សនកិច្ចសិក្សាទៅតំបន់ប្រវត្តិសាស្ត្រអន្លង់ វៀបរាប់ប្រាប់សិស្ស-និស្សិតពីប្រវត្តិមេដឹកនាំខ្មែរក្រហម សុន សេន អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-១៩៧៩) ដែលត្រូវបានសម្លាប់ទាំងគ្រួសារនៅផ្ទះរបស់គាត់នៅភូមិស្រះឈូក ឃុំត្រពាំងប្រិយ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

យោធាខ្មែរក្រហមចំនួន៦០០ បានធ្វើដំណើរទៅភ្នំដងរែក ។ ពួកគេគ្មានកន្លែងស្នាក់នៅសមរម្យទេ ។ យើងបានចំណាយពេលប្រមាណមួយខែដើម្បីដើរទៅដល់កន្លែងនោះ ។ អ្នកដែលមានជំងឺនៅពេលនោះបានស្លាប់ ។ ប៉ុន្តែដោយសារការតាំងចិត្តរបស់ខ្ញុំ ខ្ញុំបានដើរទៅដល់ទីនោះ ។ បើសិនជាខ្ញុំស្លាប់ក៏ស្លាប់ទៅចុះនៅពេលនោះ ។ ស្ត្រីមួយចំនួនបានស្លាប់ភ្លាមៗដោយសារអស់កម្លាំង ។ ខ្លួនខ្ញុំពាក់កណ្ដាលបានហើម ។ ដាញឹកញាប់ ខ្ញុំបានចេញដើរនៅពេលយប់ដើម្បីជៀសវាងការជួបប្រទះកងកម្លាំងរដ្ឋាភិបាល ឬវៀតណាម ។ នៅអំឡុងពេលទៅដល់ភ្នំ ប្រជាជនអាចទទួលបានអាហារហូបគ្រប់គ្រាន់បន្ទាប់ពីឃើញប្រជាជនមួយទៀត បានស្លាប់ដោយសារហូបច្រើនពេក ។ ខ្ញុំបានរៀបការនៅចុងឆ្នាំ១៩៧៩ និងមានកូនម្នាក់នៅឆ្នាំ១៩៨០ ។ ប្ដីរបស់ខ្ញុំបានស្លាប់នៅ១៩៩៨ បន្ទាប់ពីចូលសមាហរកម្មបានមួយរយៈ ។ នៅដើមទសវត្សរ៍៨០ ខ្ញុំធ្វើការក្នុងកងដឹកជញ្ជូន បន្ទាប់មកខ្ញុំបានផ្លាស់ទៅរស់នៅភូមិជើងភ្នំ ស្រុកអន្លង់វែង ។ មានប្រជាជនជាច្រើនបានស្លាប់ដោយសារជាន់មីន ។ ទីបំផុត អ្នកដែលដាក់មីនក៏បានស្លាប់ដែរ ។ បទពិសោធន៍ដែលខ្ញុំចងចាំមិនភ្លេចនោះ គឺប្រជាជនត្រូវបានដកហូតសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ខ្លួន ។ វិន័យផ្ដាច់ការបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំទៅជាមនុស្សផ្ដាច់ការ ។ បើគ្មានការវាយប្រហាររបស់កងទ័ពវៀតណាមនោះប្រជាជនកាន់តែច្រើនឡើងៗនឹងត្រូវបានសម្លាប់មិនខាន ។ ករណីមួយដែលបានកត់សម្គាល់ គឺការសម្លាប់ប្រជាជនមកពីភូមិភាគបូព៌ា ។ វាជាការលើកឡើងទាំងភ័ន្តច្រឡំនៅគ្រប់ទីកន្លែង ។ ប្ដីរបស់ខ្ញុំស្លាប់នៅពេល តាម៉ុក បាត់តាំងគាត់ឲ្យទៅវាយប្រយុទ្ធនៅសមរភូមិនៅគោកស្រុក ។

ថ្ងៃទី៣ គឺថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ អ្នកចូលបានធ្វើដំណើរទៅទស្សនាទីតាំងប្រវត្តិសាស្ត្រមួយចំនួននៅអន្លង់វែង ជាលើកដំបូង ដូចជា ផ្ទះតាម៉ុក, ទីតាំងបូជាសព សុន សេន, ទីតាំងបូជាសព ប៉ុល ពត, កន្លែងកាត់ទោស ប៉ុល ពត, ចេតិយ តាម៉ុក, ការិយាល័យប្រជុំរបស់ តាម៉ុក នៅលើភ្នំដងរែក ។ នៅពេលរសៀល អ្នកចូលរួមទាំងអស់ត្រូវបានបែងចែកទៅជាបីក្រុមខុសគ្នា ដើម្បីចុះទៅជួប និងពិភាក្សាផ្ទាល់ជាមួយអ្នកភូមិនៅមូលដ្ឋាន ។ អ្នកចូលរួមម្នាក់ៗ តម្រូវឲ្យយករឿងរ៉ាវដែលគាត់បានជួបពិភាក្សាមួយអ្នកភូមិសរសេរចេញជាអត្ថបទដើម្បីបោះពុម្ពផ្សាយ ។ ឃុំទឹកជុំ គឺជាទីកន្លែងដែលអ្នកចូលរួមចុះទៅដើម្បីជួបប្រជាជននៅតាមផ្ទះក្នុងភូមិ ដែលបានស្ម័គ្រចិត្តចែករំលែកនូវរឿងរ៉ាវផ្ទាល់ខ្លួន ។

## ការផ្លាស់ប្ដូរឥរិយាបទទៅលើអតីតសមាជិកខ្មែរក្រហម

ដោយបានស្ដាប់ការធ្វើបទបង្ហាញ និងបានជួបជាមួយអតីតសមាជិកខ្មែរក្រហមជាច្រើនរូប ឧទាហរណ៍ ភ្ញៀវដែលមកនិយាយ អ្នកដែលផ្ដល់បទសម្ភាសន៍ អ្នកចូលរួមម្នាក់ៗបានសរសេរនៅក្នុងសំណួរស្ទាបស្ទង់មតិក្រោយទស្សនកិច្ចដែលបង្ហាញពីអាកប្បកិរិយារបស់គាត់ចំពោះអតីតសមាជិកខ្មែរក្រហមមានការផ្លាស់ប្ដូរ ។ ពួកគេបានធ្វើការពន្យល់ស្រដៀងៗគ្នា ។ ការលើកឡើងរបស់កញ្ញា សុក ហៀប និង ចុង បានជាប់ទាក់ទងនៅក្នុងករណីសំខាន់មួយចំនួន ។ សុក ហៀប បានសង្កត់ធ្ងន់ថា ដំបូងនាងមានគំនិតគុំគួនជាមួយអតីតសមាជិកខ្មែរក្រហម តែគំនិតទាំងនេះត្រូវបានផ្លាស់ប្ដូរ ហើយការផ្លាស់ប្ដូរនេះគឺចេញមកពីការដែលនាងបានជួបសន្ទនាផ្ទាល់ជាមួយអតីតខ្មែរក្រហម ។ នាងឲ្យដឹងថា អតីតខ្មែរក្រហមមានការលំបាកក្នុងការអនុវត្តតាមបញ្ជាពីថ្នាក់លើ ។ នៅខណៈនោះដូចដែលនាងបានសង្កេតនៅអំឡុងពេលចុះធ្វើទស្សនកិច្ចសិក្សានៅតំបន់អន្លង់វែង នាងរកឃើញថា លន់ ជាអតីតយោធាខ្មែរក្រហម ដែលបានឡើងរៀបរាប់ពីប្រវត្តិនៅក្នុងរបបខ្មែរក្រហមបានផ្ដល់ដីមួយផ្នែកដើម្បីសាងសង់សាលារៀនសម្រាប់ក្មេងៗនៅក្នុងសហគមន៍ ។ ស្របពេលជាមួយគ្នានេះ ចុង បានបង្ហាញនូវទស្សនៈថា ដំណើរទស្សនកិច្ចនេះគឺជាឱកាសដើម្បីយល់ដឹងច្បាស់លាស់ទៅក្នុងបញ្ហាពិតប្រាកដដែលប្រឈមចំពោះអតីតសមាជិកខ្មែរក្រហម ។ អ្វីដែលគាត់បានគិតនៅក្នុងចិត្តគឺថា អតីតខ្មែរក្រហមទាំងនោះគ្មានជម្រើស ប៉ុន្តែត្រូវតែធ្វើក្នុងករណីនេះ ខ្មែរក្រហមទាំងនោះបានធ្វើដោយប្រឆាំងនឹងឆន្ទៈផ្ទាល់ខ្លួនរបស់ពួកគេ ។

នៅពេលដំណើរទស្សនកិច្ចបានមកដល់អន្លង់វែង អ្នកចូលរួមមួយចំនួនបានសន្មតទុកជាមុនថា ការបង្កើតទំនាក់ទំនងជាមួយអតីតសមាជិកខ្មែរក្រហមមានការលំបាក ឬមិនអាចទៅរួច ព្រោះថា ការទំនាក់ទំនងរបស់អតីតសមាជិកខ្មែរក្រហមជាមួយអ្នកដែលមិនធ្លាប់ស្គាល់នៅក្នុងសហគមន៍របស់ពួកគេ គឺមិនមែនជារឿងល្អនោះទេ ។ ទោះបីយ៉ាងណា គឹមសី បានសរសេរថា "ខ្ញុំបានគិតថា

វាមិនមានទំនាក់ទំនងរវាងអតីតសមាជិកខ្មែរក្រហម អ្នកភូមិ និង អ្នកមកដល់ថ្មីនោះទេ ។ តែការពិតវាមិនដូច្នេះទេ ។ ពួកគេមានទំនាក់ទំនងជាមួយគ្នាល្អណាស់ ។

## ការយល់ឃើញទូទៅចំពោះកម្មវិធីដំណើរទស្សនកិច្ចសិក្សា

អ្នកចូលរួមភាគច្រើនបានគិតថាកម្មវិធីមានសារសំខាន់ខ្លាំងណាស់ ទាំងការធ្វើបទបង្ហាញ ការធ្វើទស្សនកិច្ចទៅកាន់ទីតាំងប្រវត្តិសាស្ត្រ ហើយនិងការជួបពិភាក្សាផ្ទាល់ជាមួយអតីតសមាជិកខ្មែរក្រហម ។ កញ្ញា បូរ៉ាន បានសរសេរក្នុងតារាងឆ្លុះបញ្ចាំងពីការសង្កេតឃើញប្រចាំថ្ងៃរបស់នាងថា នាងសប្បាយរីករាយដោយបាននិយាយជាមួយអតីតសមាជិកខ្មែរក្រហម និងជនរងគ្រោះ ។ អ្នកចូលរួមទាំងអស់ហាក់ដូចជាឯកភាពជាគោលមួយជាមួយសញ្ញាថា ទោះជាអ្នកភូមិមានសាវតាផ្សេងៗគ្នា តែពួកគាត់មានការរាក់ទាក់និងមានការសហការគ្នា ។ ការជួយជ្រោមជ្រែងរបស់អ្នកភូមិទាំងនេះបាននាំទៅដល់ផ្លែផ្កាក្នុងការសម្ភាសន៍សម្រាប់សរសេរអត្ថបទ ។ នៅក្នុងឱកាសដ៏មានសារសំខាន់នេះ អ្នកចូលរួមនីមួយៗអាចស្វែងយល់ស៊ីជម្រៅអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកដែលផ្តល់បទសម្ភាសន៍នៅក្នុងរបបខ្មែរក្រហម និងសង្គ្រាមស៊ីវិល ។ ការស្វែងយល់ពីគ្នាទៅវិញទៅមកត្រូវបានចាត់ទុកថា ជាបទពិសោធន៍ដែលបានឃើញផ្ទាល់នឹងភ្នែក ។ ដាក់ស្តែង ភក្ត្រា ដែលពីមុនមានទស្សនៈថា អតីតសមាជិកខ្មែរក្រហមទាំងអស់សុទ្ធតែអាក្រក់ និងឃោរឃៅ ។

នៅក្នុងន័យផ្សេងទៀត អ្នកចូលរួមបានយល់ព្រមថា សង្គមនយោបាយសម័យនោះគួរតែត្រូវបានបន្ទោស ។ កញ្ញា សុក ហៀប បានសង្កេតដោយប្រុងប្រយ័ត្នចំពោះអ្នកបានផ្តល់សម្ភាសន៍ដល់នាង និងការសម្តែងនូវចំណាប់អារម្មណ៍ដោយផ្ទាល់ ។ សុក ហៀប បានកត់សម្គាល់ថា អ្នកដែលបានផ្តល់បទសម្ភាសន៍បានបង្ហាញពីការលំបាក និងការតស៊ូដើម្បីបានរស់ជីវិត ។ ទោះបីជាយ៉ាងណា ម៉ី សៀង មានការយល់ឃើញខុសពីនេះបន្តិច ដោយសរសេរថា «ខ្ញុំជឿនូវអ្វីដែលពួកគេបាននិយាយប្រាប់អំពីរឿងរ៉ាវផ្ទាល់ខ្លួន ប៉ុន្តែមិនជឿមួយរយភាគរយនោះទេ» ។ វាជាផ្នែកនៃប្រវត្តិសាស្ត្រទាំងអស់ ។ វាគួរតែមានការជួបគ្នា និងជជែកគ្នាមួយជនរងគ្រោះជាច្រើននាក់ទៀត ដើម្បីឲ្យមានតុល្យភាព និងមានការយល់ដឹងទូលំទូលាយជាងមុន ។ ទស្សនៈរបស់នាងស្របទៅនឹងឃ្លាមួយលើកឡើងថា ការសិក្សាប្រវត្តិសាស្ត្រ គឺទាមទាឲ្យយើងដឹងគ្រប់ផ្នែកទាំងអស់ ។

## សន្និដ្ឋាន

ដំណើរទស្សនកិច្ចសិក្សាលើកទីមួយទៅកាន់តំបន់អន្លង់វែង បានជោគជ័យទាំងស្រុង ។ អ្នកចូលរួមបានបង្ហាញពីគំនិតទៅលើគ្រប់ទិដ្ឋភាពនៃកម្មវិធីនេះ ។ ជាការកត់សម្គាល់ផ្ចត់គំនិតយល់ឃើញរបស់ពួកគេចំពោះអតីតសមាជិកខ្មែរក្រហមថា សាហាវឃោរឃៅនិងកាប់សម្លាប់ បានផ្លាស់ប្តូរបន្តិចបន្តួច ឬទាំងស្រុងតែម្តង ។ អ្នកចូលរួមជាច្រើន បានសម្តែងនូវការអាណិតអាសូរភ្លាមៗ នៅពេលបានសមាជិកខ្មែរក្រហមរៀបរាប់នូវរឿងរ៉ាវជីវិត ។ ទាំងនេះដោយសារតែពួកគេបានពុះអំពីជីវិត និងការស្លាប់ ហើយនិងការតស៊ូដើម្បីរស់ ។ ទោះបីជាយ៉ាងណា អ្នកចូលរួមមួយចំនួនមានការគិតល្អិតល្អន់ និងបានចោទសួរពីការរៀបរាប់នូវរឿងរ៉ាវទាំងនេះ ។ ពួកគេចង់សិក្សាស្វែងយល់ពីខាងជនរងគ្រោះឲ្យកាន់តែច្រើនថែមទៀតដើម្បីទទួលបាននូវការយល់ដឹងទូលំទូលាយអំពីប្រវត្តិសាស្ត្រ ។ ទាំងនេះជាការណែនាំចំពោះការចង់ដឹងរបស់អ្នកចូលរួមមួយចំនួនដែលបានជួបជាមួយជនរងគ្រោះជាច្រើននៅក្នុងរបបខ្មែរក្រហម ។

ទោះយ៉ាងណាក៏ដោយ អ្វីដែលអ្នកចូលរួមជាច្រើនបានគិតឃើញជារួម គឺថាពួកគេមិនបានរើសអើងជាមួយកូនៗរបស់អតីតសមាជិកខ្មែរក្រហមទេ ។ មានករណីជាច្រើនបានចង្អុលបង្ហាញថា របបខ្មែរក្រហមខ្លួនឯងបានដឹកនាំប្រជាជនឲ្យប្រឆាំងនឹងឆន្ទៈរបស់គេផ្ទាល់ ។ បន្ទាប់ពីកម្មវិធីបានបញ្ចប់ អ្នកចូលទាំងអស់បានសាទរចំពោះដំណើរទស្សនកិច្ចសិក្សា ហើយបានស្នើឲ្យមានការរៀបចំសម្រាប់សិស្សផ្សេងទៀត ។ ចំណុចចុងក្រោយ គឺការសម្តែងនូវចំណាប់អារម្មណ៍ដែលពួកគេគិតចំពោះដំណើរទស្សនកិច្ច គឺជាការអប់រំ ការទទួលបានព័ត៌មាន ការពេញចិត្ត និងទទួលបានបទពិសោធន៍ ។

ដំណើរទស្សកិច្ចសិក្សាសន្តិភាពទៅកាន់តំបន់អន្លង់វែង បានបញ្ចប់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នៅពេលដែលយើងបានទៅទស្សនាការតាំងពិព័រណ៍ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅវត្តថ្មី ។ អ្នកចូលរួមក៏បានទៅទស្សនាប្រាសាទអង្គរវត្ត ខេត្តសៀមរាប ដោយផ្សារភ្ជាប់ទៅនឹងប្រទេសកម្ពុជាពីអតីតកាលជាមួយកេរដំណែលវប្បធម៌ ។ **លី សុខឃាង**

# រសាត់តាមខ្យល់

**(តពីលេខមុន)**



ចំណែកពូៗមកពីបូព៌ារាប់រយគ្រួសារ នាំគ្នាឈរមើលពួកគាត់ខ្វាចមិនហ៊ានប៉ះពាល់ស្អីទាំងអស់ ។ ពូម្នាក់បានសួរមកសួរខ្ញុំ "ក្មួយ! ចុះពួកពូតើត្រូវទៅណា?" ខ្ញុំប្រញាប់តបទៅគាត់វិញថា "ពូៗចាំអីទៀត ម៉េចក៏មិននាំគ្នាទៅយកស្រូវអង្ករហ្នឹងគេ ហើយនាំគ្នាត្រឡប់ទៅភូមិកំណើតវិញរៀងៗខ្លួន ព្រោះយួនវាយដាច់ភ្នំពេញហើយ" ។ ខ្ញុំបានប្រាប់ពួកគាត់ប៉ុណ្ណឹង ហើយពូៗអ្នកបូព៌ាហេតុតែបាក់ស្បាត ពួកគាត់នៅតែខ្លាចញញើតញញើមមិនទាន់ស្ទុះស្ទានៅឡើយទេ រហូតទាល់តែបានឃើញអ្នកភូមិខ្មែរកជាច្រើននាក់បររទេះគោ រទេះក្របីមកដឹកជញ្ជូនស្រូវអង្ករពីជង្រុកធំៗទាំងពីរ ចាប់ជ្រូក ចាប់គោ ក្របី មាន់ទា ទើបពួកគាត់ចូលទៅដណ្ដើមហ្នឹងគេបានខ្លះ ។

ពេលដែលខ្ញុំមកដល់ខ្ទម ខ្ញុំឃើញគោទាំងពីរក្បាលនៅជាប់ចំណងឯក្រោយរោងនៅឡើយ តែបាត់មិនឃើញស្រមោល លី សោះ ដោយសង្ស័យខ្ញុំក៏ដើរទៅរក លី នៅរោងក្រុមយុវនារី ដែលពេលនោះពួកគេបាននាំគ្នាចាកចេញស្ទើរតែស្ងាត់រោងទៅហើយ ។ ខ្ញុំបានឃើញ លី និងនារីអ្នកថ្មីម្នាក់ឈ្មោះ វី កំពុងតែរៀបចំអីវ៉ាន់ជាមួយគ្នា ។ លី បានលួចស្រឡាញ់ អាវី យូរហើយ ហើយពួកចុងភៅតែងតែចំអន់រាល់ថ្ងៃ ។ អាវី ជាកូនកំព្រាមានស្រុកកំណើតនៅបន្ទាយលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ពេលដែលត្រូវបែកខ្ញែកវិលត្រឡប់ទៅស្រុកទៅភូមិរៀងៗខ្លួនក្នុងគ្រាអាសន្នបែបនេះ លី និង អាវី ក៏បានចាប់ដៃគ្នាជាគូអនាគតប្ដីប្រពន្ធ ។

មិនមែនមានតែ លី និង អាវី មួយគូនេះទេ ពេលនោះមិត្តឆាន មិត្តភ័ណ មិត្តវិន ក៏បានចាប់គូរៀងៗខ្លួនដែរ ។ មិត្តរៀម ប្រធានកងខ្ញុំចាប់គូនឹង មិត្តនាដ អ្នកស្រុកតាំងក្រសៅ អាយ៉ា ចាប់ដៃគ្នានឹងមិត្តស្រស់ ជាខ្មែរអ៊ីស្លាមដូចគ្នា ។ល ។

លី និង អាវី បាននាំគ្នាចេញដំណើរមុនខ្ញុំឆ្ពោះទៅភូមិព្រៃភ្លូ ខ្ញុំបានត្រឡប់ទៅខ្ទមវិញ ទៅស្រាយចំណងលែងគោទាំងពីរក្បាល ។ ពេលដើរមកដល់ខ្លួងទំនប់ជាមួយបង្ហេចតូចមួយស្ពាយជាប់នឹងស្មា ខ្ញុំឈរទ្រឹងចោលភ្នែកក្រឡេកមើលអង្គភាពចល័តស្រុកជាចុងក្រោយ ខ្ញុំសម្លឹងមើលវាលស្រែដែលសន្ទូងកំពុងតែលាស់សន្លឹកពណ៌បៃតងខ្ចី ខ្ញុំសម្លឹងមើលកូនឃ្មោក កូនត្រឡាចដែលកំពុងតែលូតលាស់ចេញផ្លែផ្កា បោះដៃឡើងទ្រើងព្យួរក្ដិបប៉ុនមេដៃមេជើងរាប់រយឲ្យរណោងតាមបណ្ដោយជើងទំនប់ ។

កែវភ្នែកទាំងគូរបស់ខ្ញុំ បានថតផ្ដិតទស្សនីយភាពជុំវិញអង្គភាពចល័តស្រុកដ៏ស្រស់បំព្រងដែលពេលនោះ មានសភាពស្ងាត់ជ្រងំបន្តិចទៅហើយ ។ គ្រាដែលខ្ញុំបានបោះជំហានចាកចេញពីទីនោះ ខ្ញុំមានអារម្មណ៍យ៉ាងស្រងេះស្រងោចក្ដុកក្ដួល ។ ក្នុងចិត្តខ្ញុំនឹកអាសូរនឹកស្រណោះដល់រូប សេង និងអ្នកផ្សេងមួយចំនួនទៀតដែលពុំមានសំណាងបានឆ្លងផុតមកដល់ថ្ងៃនេះ ហើយដែលពួកគេត្រូវវាសនាអាក្រក់តម្រូវឲ្យនៅវិលវល់ឯកោកណ្ដាលទ្រូងព្រៃស្មសានដ៏ស្ងាត់ជ្រងំងងឹតសូន្យសុងជារៀងរហូត ។

## អរុណោទ័យនៃជីវិតថ្មី

ដើរមកដល់អង្គភាពចល័តវាលត្បែងកោង កម្លាំងយុវជនយុវនារីបានចាកចេញស្ងាត់បាត់អស់ទៅហើយ ខ្ញុំនៅបានប្រទះឃើញអ្នកភូមិបីបួននាក់កំពុងនាំគ្នារត់ដេញតាមចាប់មាន់ទា ជ្រូក យ៉ាង

ប្រញាយ ។ ជ្រូកមួយក្បាលរត់ត្របាញ់ជើងសំដៅចូលព្រៃ អ្នកភូមិពីរនាក់ដេញយ៉ាងប្រកិតពីក្រោយ គ្រាន់តែចាប់ជ្រូកបានភ្លាម ពួកគាត់នាំគ្នាសម្លាប់កណ្តាលព្រៃបែងចំណែកសាច់ចែកគ្នាភ្លាមៗ ។

តាមបណ្តោយផ្លូវលំឆ្ពោះទៅកាន់ភូមិខ្មែរ ខ្ញុំឃើញរថយន្តហ្សេ.អ៊ឹម.សេ ពីរគ្រឿងដឹកកងទ័ពយួនកំពុងតែបើកយឺតៗឆ្ពោះទៅកាន់ក្រយាជង្គារ ។ ដើរឆ្ងាយពីនោះបន្តិច ពេលមកជិតដល់ភូមិឃ្លៃ ខ្ញុំបានជួប អាឈុន កូនរបស់ បងឈុំ បងថ្លៃ មិត្តសាយ កំពុងតែបរទេះក្របីលើខ្នងទំនប់ប្រឡាយផ្លូវលំ ពេលដែលខ្ញុំសួរវាថា “បរទេះទៅណា?” អាឈុន តបមកខ្ញុំវិញថា “ទៅយកជ័យភ័ណ្ឌ” ។

មកដល់ភូមិឈើទាល ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយបានឃើញ មិត្តស៊ិន និង មិត្តបេន ជាអតីតប្រធានភូមិថ្មីធ្លាប់បានសម្លាប់ប្រជាជនថ្មីរាប់សិបនាក់ ស្ពាយកាំភ្លើងម្នាក់មួយដើមនៅនឹងស្មាកំពុងតែដើរជាមួយកងទ័ពយួនពីរនាក់ទៀត ដើរប្រមូលកម្លាំងយុវជន បង្កើតជាកងស្វ័យត្រាណដើម្បីយាមការពារភូមិ ព្រោះពួកខ្មែរក្រហមដែលបាក់ទ័ពទៅហើយ មិនទាន់ទៅណាឆ្ងាយទេ នៅលាក់ខ្លួនក្នុងព្រៃក្បែរៗភូមិនៅឡើយ ។

ខ្ញុំភ្ញាក់ផ្អើលដោយឃើញ មិត្តបេន ចេះនិយាយភាសាយួនយ៉ាងស្ទាត់ (មិត្តបេន ត្រូវជាឪពុកមារបង្កើតរបស់ មិត្តស៊ិន) មានកម្លាំងយុវជនភូមិទាំងអ្នកចាស់ទាំងអ្នកថ្មីជិតដប់នាក់បានចុះឈ្មោះស្ម័គ្រចិត្តចូលបម្រើក្នុងកងស្វ័យត្រាណភូមិ ហើយត្រូវបានបំពាក់អាវុធភ្លាមៗដោយកងទ័ពយួន ក្រោមការគ្រប់គ្រងរបស់ មិត្តស៊ិន និង មិត្តបេន ។

យប់ថ្ងៃរំដោះដំបូងនោះ ឪពុកម្តាយ មិត្តសាយ បងឈុំ និងប្រពន្ធគាត់បានឃាត់ខ្ញុំមិនទាន់ឲ្យទៅណាទេ ។ ខ្ញុំអល់អែកក្នុងចិត្តព្រោះចង់ទៅអើតមើល ពូដន ឈឺនៅឯភូមិទួលសង្កែសិន បន្ទាប់មកទៀតរូបខ្ញុំខ្លួនឯងក៏មិនប្រាកដក្នុងចិត្តថាមានទិសដៅទៅកាន់ទីណាដែរ ។ យប់នោះបងស្រីប្រពន្ធបងឈុំ ម្តាយ មិត្តសាយ និយាយជាមួយខ្ញុំយូរណាស់ ព្រោះតែគាត់មិនចង់ឲ្យខ្ញុំចាកចេញទៅណាឆ្ងាយពីគ្រួសារគាត់ ខ្ញុំបានជម្រាបគាត់តាមត្រង់ថា គ្រាន់តែបានរំដោះភ្លាម ម្នាក់ៗតម្រង់រកភូមិរកស្រុកកំណើតរៀងៗខ្លួន ។ ខ្ញុំចង់ទៅអើតស្រុកកំណើតខាងម្តាយខ្ញុំ ។

ប្រមាណម៉ោងពីររំលងអាធ្រាត្រយប់នោះ បងឈុំ បានមកដាស់ខ្ញុំពីដំណេកដោយបានប្រាប់ខ្ញុំថា ទៅហូបបាយនឹងគេនៅរោងបាយរួម ។ ខ្ញុំក្រោកឡើងទាំងសើងម៉ើង ពេលដែលដើរមកដល់រោងបាយ ខ្ញុំឃើញអ្នកភូមិជាច្រើននាក់កំពុងតែនាំគ្នាដួសបាយពីក្នុងខ្ទះយកមកអង្គុយហូបជារង់ជុំៗគ្នាផ្ទាល់នឹងដីជាមួយនឹងសាច់ជ្រូកលីងក្រោមពន្លឺភ្លើងចន្ទុះដ័រត្បែងដែលកំពុងតែឆេះហុយទ្រលោល ។ ខ្ញុំឈរភាំងដោយឃើញគេទាំងអស់គ្នាកំពុងតែហូបយ៉ាងប្រញាប់ប្រញាល់ដូចដណ្តើមគ្នា ហូបនឹងដៃកាយញាត់ៗ បងឈុំ ហុចបាយមួយចានមកឲ្យខ្ញុំរួចគាត់ហួសទៅដួសសាច់ជ្រូកលីងបានមួយចានធំយកមកដាក់ហូបអង្គុយចោងហោងទល់មុខគ្នាជាមួយអ្នកភូមិបួនប្រាំនាក់ទៀត ។ ហូបបណ្តើរ បងឈុំ បានប្រាប់ខ្ញុំបណ្តើរថា រោងបាយរួម មានចិញ្ចឹមជ្រូកពីរក្បាល យប់មិញចុងភៅកាប់យកសាច់លីងចែកអ្នកភូមិទាំងអស់គ្នាហូប ដោយប្រញាប់ពេកចុងភៅមិនបានកោសរោមឲ្យបានស្អាត ចុងភៅលីងទាំងរោម ទាំងស្បែកតែម្តង ។ ហូបបណ្តើរខ្ញុំខ្វាក់ស្បែក និងរោមជ្រូកចេញពីមាត់បណ្តើរ អ្វីដែលខ្ញុំមិនអាចបំភ្លេចបានក្នុងមួយជីវិតខ្ញុំនោះ គឺទិដ្ឋភាពជុំវិញពេលនេះខ្ញុំទទួលអារម្មណ៍ហាក់ដូចជាកំពុងតែរស់នៅឋានមួយផ្សេង ។

ថ្ងៃទីពីរបន្ទាប់ពីថ្ងៃរំដោះ ខ្ញុំនៅនឹងភូមិឈើទាលនៅឡើយ ។ បងសៃ បងប្រុសបង្កើតរបស់ មិត្តសាយ ខ្វាយខ្វល់យ៉ាងខ្លាំងព្រោះកូនប្រុសច្បងរបស់គាត់ឈ្មោះ អាញាញ់ អាយុប្រហែល១៧-១៨ឆ្នាំ ត្រូវបាន មិត្តអេង ពេលផ្លាស់ពីអង្គភាពចល័តស្រុកទៅធ្វើជាប្រធានឃុំកកោះយកទៅធ្វើជាកងការពារផ្ទាល់ ហើយវាមិនហ៊ានវិលត្រឡប់មកភូមិវិញតែម្នាក់ឯង ព្រោះខ្លាចកងទ័ពយួន ។ បងសៃ បានមកនិយាយឲ្យខ្ញុំជួយទៅយកកូនគាត់ពីឃុំកកោះ មកវិញផង ខ្ញុំក៏បានយល់ព្រម ។

យប់នោះកំពុងតែលក់ស្កប់ស្កល់ក្នុងដំណេក ខ្ញុំភ្ញាក់ដឹងខ្លួននឹងស្នូរកាំភ្លើងបាញ់តគ្នាលាន់យ៉ាងទ្រហឹងពេញភូមិ កងស្វ័យត្រាណការពារភូមិបានពើបប្រយុទ្ធគ្នាជាមួយនឹងយោធា ប៉ុល ពត ដែលសេសសល់ព្យាយាមចូលមកក្នុងភូមិប្លន់យកស្រូវអង្ករ ។ ដោយមានការជួយគាំទ្រពីកងទ័ពយួន យោធា ប៉ុល ពត ក៏បាក់ទ័ពរត់ចូលព្រៃវិញអស់ទៅ បន្ទាប់ពីប្រយុទ្ធគ្នាអស់រយៈពេលជាងមួយម៉ោងក្រោយមក ។

កម្លាំងខាងកងស្វ័យត្រាណមានរបួសម្នាក់ត្រង់ប្រអប់ដៃ

ខាងត្បូងជាយុវជនអ្នក១៧មេសា ឈ្មោះ សៅ សោភា កូនប្រុសរបស់លោកតា យ៉ា អតីតអាចារ្យវត្តប្រយូវង្ស ។ អាភា ត្រូវបានកងទ័ពយួនយកទៅព្យាបាលភ្នំពេញ ។ ចំណែកយោធា ប៉ុល ពត មានស្លាប់ម្នាក់នៅនឹងកន្លែង និងចាប់ខ្លួនបានម្នាក់ ។ អ្នកភូមិឈើទាលទាំងមូលមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះយោធា ប៉ុល ពត ដែលចាប់ខ្លួនបាននោះ អ្នកណាក៏ស្គាល់ដែរ គឺ មិត្តថ្វាង កងការពារមិត្តលឹម អតីតប្រធានឃុំកំពង់ថ្ម ។

ស្អែកឡើងខ្ញុំក៏បានចេញដំណើរតាំងពីព្រលឹមឆ្ពោះទៅកាន់ឃុំកោះរយៈផ្លូវមិនឆ្ងាយប៉ុន្មានទេ ហើយខ្ញុំក៏មិនបានប្រញាប់ប្រញាល់អីដែរ ។ ចេញមកដល់ថ្នល់ជាតិ ខ្ញុំឃើញប្រជាជនច្រើនណាស់ ធ្វើដំណើរទៅមកយ៉ាងពពាក់ពពូនជាមួយនឹងកម្មសិទ្ធិបន្តិចបន្តួចតម្រង់ទៅស្រុកកំណើតរៀងៗខ្លួន ។ ខ្ញុំរំភើបក្នុងចិត្តឥតឧបមាពេលដែលបានឃើញកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាជាលើកដំបូងដែលកំពុងតែធ្វើដំណើរតាមរថយន្តលើកដៃស្វាគមន៍ប្រជាជនទាំងសងខាងផ្លូវជាមួយនឹងសម្រែកជ័យឃោសយ៉ាងសប្បាយរីករាយ ។ បើកបន្តបន្ទាប់គ្នានោះ មានរថយន្តដឹកកងទ័ពយួននិងរថក្រោះចម្បាំងជាច្រើនគ្រឿងទៀត ។ កាលពីពេលមុនដាច់ភ្នំពេញ ខ្ញុំធ្លាប់តែឮវិទ្យុខ្មែរក្រហមស្រែកប្រកាសថ្កោលទោសខ្លាំងៗពីការឈ្លានពានលេបទឹកដីពីសំណាក់កងទ័ពយួន ខ្ញុំមិនដែលបានឮទាល់តែសោះពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាយ៉ាងអង់អាចក្លាហាន ។ កាលពីយប់ថ្ងៃទី៦ ខែមករា ខ្ញុំឮតែតាមរយៈកងទ័ពតំបន់លើខ្នងទំនប់និយាយថា យួនវាយដាច់ភ្នំពេញហើយ ពេលនោះខ្ញុំស្មានតែកងទ័ពយួនសុទ្ធសាធជាអ្នករំដោះ មិននឹកស្មានសោះថាមានកងទ័ពរណសិរ្សខ្មែររួមប្រយុទ្ធវាយកម្ទេចរបបកម្ពុជាប្រជាធិបតេយ្យឲ្យវិនាសខ្ទាត់ខ្ទាយ ។ ខ្ញុំបាននឹកគិតក្នុងចិត្តតែម្នាក់ឯងថាកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាប្រហែលជាអាចបង្កើតដោយកងទ័ពយួនបំពាក់អាវុធសម្លៀកបំពាក់តាំងពីក្បាលដល់ចុងជើង និងហ្វឹកហ្វឺនយុទ្ធសាស្ត្រដោយកងទ័ពយួន ។ តែទោះជាយ៉ាងណាក៏ដោយ ពេលនេះជាមួយនឹងការកោតស្ញើចសរសើរចំពោះវីរភាព ការលះបង់សាច់ស្រស់ឈាមស្រស់របស់កងទ័ពរំដោះទាំងអស់ដែលបានមកជួយរំដោះប្រជាជនទូទាំងប្រទេសយ៉ាងទាន់ពេលវេលា ឲ្យរួចផុតពីការកាប់សម្លាប់ ខ្ញុំជឿថាមិនមែនមានតែខ្ញុំម្នាក់ឯងទេ គឺអ្នកដែលបានរស់រានមានជីវិតទាំងអស់ កំពុងតែមានអារម្មណ៍នឹក "ដឹងគុណ" ដូចខ្ញុំដែរ ។

នៅនឹងទីស្នាក់ការមួយត្រង់ក្បាលស្ពានកំពង់ថ្ម កងទ័ពខ្មែររណសិរ្សកំពុងតែចែកខិតប័ណ្ណនិងប្រកាសតាមមេក្រូ ផ្សព្វផ្សាយជូនប្រជាជនដែលកំពុងតែធ្វើដំណើរទៅមកឲ្យបានជ្រួតជ្រាបពីគោលនយោបាយ១៨ចំណុចរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលក្នុងនោះមានទាំងនយោបាយសន្ដោសលើកលែងទោសដល់កងទ័ពខ្មែរក្រហម ដែលទម្លាក់អាវុធសុខចិត្តចុះចូលមករួមរស់ក្នុងសង្គមជាតិវិញ ។ល ។ ហួសពីនោះបន្តិចខ្ញុំបានជួបជាមួយគ្រួសារអ្នកថ្មីជាច្រើនគ្រួសារដែលកំពុងឈប់ដណ្ដាំស្លតាមចិញ្ចើមថ្នល់ ។

ដើរមកដល់ភូមិព្រៃភ្លូ ខ្ញុំឆ្លៀតចូលទៅរក លី ។ ចៃដន្យថ្ងៃនោះត្រូវចំថ្ងៃ លី និង អាវី រៀបការ ។ ផ្ទះ លី ដែលស្ថិតនៅកណ្ដាលភូមិកំពុងតែមានភ្ញៀវចាស់ទុំជាច្រើន ។ ខ្ញុំត្រេកអរយ៉ាងខ្លាំងពេលដែលបានជួប លី ជាថ្មីនេះ ខ្ញុំនិយាយលេងបែបបន្ទោស លី ថា គ្រាន់តែដាច់ភ្នំពេញភ្លាមរត់រកស្នេហាតែម្ដង គោជាប់ចំណងនៅខាងក្រោយរោងក៏មិនខ្វីស្រាយ បើកុំតែខ្ញុំទៅរកឃើញនៅរោងនារី កុំអីមិនដឹងទៅរក លី ឯងនៅទីណាទេ ។ លី បានប្រាប់ខ្ញុំថា នៅភូមិព្រៃភ្លូថ្ងៃនេះមានរៀបចំគ្រួសារពីរគូ មួយគូទៀតគឺ មិត្តរឿន អតីតប្រធានអង្គភាពចល័តស្រុកចុងក្រោយ ។ ខ្ញុំបានជួប អាពន្លក នៅនឹងភូមិប្រាសាទ ឃុំប្រាសាទ វាកំពុងតែឈរមើលប្រជាជនធ្វើដំណើរទៅមក ។ អាពន្លក បានប្រាប់ខ្ញុំថា អាស្រ៊ុន ជាមួយឪពុកម្ដាយបងប្អូនវាទាំងអស់ បានវិលត្រឡប់ទៅស្រុកកំណើតវិញហើយ គ្រួសារ អាផុន និងម្ដាយក្មេកវា គ្រួសារ អានឿន ក៏ចេញពីឃុំប្រាសាទអស់ហើយដែរ តែវានិយាយគ្នាមិនត្រូវសោះជាមួយឪពុកវា ទោះជាម្ដាយវាខំជួយនិយាយយ៉ាងណាក៏ដោយ ក៏គាត់នៅតែមិនព្រមចេញពីភូមិប្រាសាទនេះដែរ ។ ដល់ពេលដែលវាពន្យល់ហេតុផលថាជាងបីឆ្នាំហើយឃើញតែភូមិហ្នឹង ឃើញតែកំពូលវត្តហ្នឹង ឃើញតែវាលស្រែដើមត្នោតហ្នឹងដដែលៗ ម៉េចក៏មិនវិលត្រឡប់ទៅស្រុកកំណើតយើងវិញ នៅទីនេះធ្វើអីទៀត? អាពន្លក ថា គាត់ខឹងស្ដីឲ្យវា "អ្ហែងក្មេងកុំចេះណែនាំអញ" ។

អាពន្លក បាននាំខ្ញុំឲ្យទៅជួបឪពុក និងម្ដាយវានៅឯផ្ទះ ដើម្បីឲ្យខ្ញុំជួយនិយាយជាមួយឪពុកវា ឆ្លៀតឱកាសមួយភ្លែតនោះខ្ញុំក៏

បានជម្រាបគាត់ថា ពួកខ្មែរក្រហមមិនទាន់ទៅណាឆ្ងាយទេ នៅលាក់ខ្លួនក្នុងព្រៃក្បែរៗភូមិយើងនេះ ។ នៅភូមិឈើទាល ឃុំកំពង់ថ្ម ពួកវាចូលមកប្លន់យកស្រូវអង្ករបាញ់គ្នាយ៉ាងសាហាវ ភូមិប្រាសាទនៅជាប់នឹងថ្នល់ជាតិតែនៅក្រោយភូមិសុទ្ធតែព្រៃ ពួកវាអាចនឹងចូលមកនៅពេលណាមួយ មានតែម្យ៉ាងទេ គឺចេញឲ្យផុតពីទីនេះតម្រង់ទៅរកស្រុកកំណើតយើងវិញ ខ្ញុំនិយាយមិនទាន់ផុតពីមាត់ស្រួលបួលផង ស្រាប់តែគាត់ឮយខ្ញុំយ៉ាងចាស់ដៃថា "ពួកអ្នែងកុំចេះមកពន្យល់ណែនាំអញ អញថាម៉េចគឺអីចឹងហើយ!" ។

ចេញពី អាពន្លក មក ខ្ញុំក៏ស្រូតដំណើរទៅឃុំកកោះតែម្តង ។ មុននឹងទៅរក អាញាញ់ នៅមន្ទីរឃុំ ខ្ញុំបានទៅរក ឆាវ៉ាក់ ដែលរស់នៅនឹងកូនខ្ទមស្លឹកតូចមួយសង់ផុតពីដីប្របនឹងផ្លូវជាតិជាមួយម្តាយនិងប្អូនស្រីពីរនាក់ ។ នៅទីនោះ អ្នកមីងម្តាយ ឆាវ៉ាក់ បាននិយាយនឹងខ្ញុំថា បើខ្ញុំពុំមានទីដៅទៅណាទេនោះ គួរតែរង់ចាំរួមដំណើរទៅជាមួយពួកគាត់ ។ ទៅដល់ស្រុកកំណើតគាត់សិនរួចចាំគិតបន្តទៀត ។ ពួកគាត់មិនដឹងថាត្រូវចេញដំណើរនៅថ្ងៃណាទេ ព្រោះកំពុងរង់ចាំគ្រួសារបងស្រីគាត់មួយគ្រួសារធំទៀត ចាំដល់ពេលចេញដំណើរគាត់នឹងឲ្យ ឆាវ៉ាក់ ទៅរកខ្ញុំនៅភូមិឈើទាល កំពង់ថ្ម ។

ក្រោយពីបានជួប អាញាញ់ នៅមន្ទីរឃុំកកោះរួចមក ខ្ញុំក៏បាននាំ អាញាញ់ ត្រឡប់មកកំពង់ថ្មវិញនារសៀលថ្ងៃនោះ ។ មកដល់ភូមិប្រាសាទខ្ញុំឃើញ អាពន្លក ហាក់ដូចជាកំពុងតែរង់ចាំមើលផ្លូវខ្ញុំ គ្រាន់តែបានឃើញខ្ញុំភ្លាម វារត់តម្រង់មករក អាពន្លក វាបានប្រាប់ខ្ញុំទាំងត្រហេបត្រហបថា ថ្ងៃមិញឪពុកវាត្រូវបានទាហានយួនចាប់ចងស្លាបសេក ខ្ញុំសួរទៅវាវិញថា ម៉េចអីចឹងមកពីហេតុអ្វី? អាពន្លកឆ្លើយមកខ្ញុំវិញថា ពេលហូបបាយថ្ងៃត្រង់រួចគាត់ចុះដើរទៅក្រោយផ្ទះ ស្រាប់តែជួបទាហានយួនពីរនាក់កំពុងតែដើរល្បាត គ្រាន់តែបានឃើញគាត់ភ្លាមទាហានយួនទាំងពីរនាក់ស្រែកយ៉ាងរត់មាត់ "ប៉ុល ពត ប៉ុល ពត!" ហើយក៏ភ្ជង់កាំភ្លើងចងស្លាបសេកបណ្តើរគាត់យកទៅទីស្នាក់ការ ។

សំណាងល្អបានអ្នកភូមិប្រាសាទបីបួននាក់ទៅធានាថាគាត់ជាប្រជាជនធម្មតាមិនមែនពួក "ប៉ុល ពត" ទេ ។ អាពន្លក និយាយបន្តបែបចង់សើចថា ពួកម៉ាកឯងដឹងទេ គ្រាន់តែរួចពីចំណងភ្លាម មិនបាច់បិតសាប៊ូទេ លឿនប្រុយមកដល់ផ្ទះរៀបចំអីវ៉ាន់ហើយ សម្រេចចេញដំណើរទៅស្រុកកំណើតនៅឯទន្លេវិញព្រឹកស្អែកនេះតែម្តង ។ ពេលនោះខ្ញុំ និងអាពន្លក មិនបាននឹកគិតថា យើងអាចនឹងបែកគ្នារហូតឬយ៉ាងណាទេ ប្រការតែម្យ៉ាងគត់ដែលធ្វើឲ្យយើងភ្លេចអ្វីៗទាំងអស់ គឺបានរួចផុតពីការកាប់សម្លាប់ និងបានវិលត្រឡប់ទៅរកភូមិកំណើតជាទីស្នេហារៀងៗខ្លួនវិញ ។

ពេលដែលខ្ញុំ និង អាញាញ់ បានមកដល់ភូមិឈើទាលវិញ ចំពេលដែលអ្នកភូមិកំពុងតែប្រជុំកាត់ទោស មិត្តថ្លាង នៅរោងបាយរួម ខ្ញុំក៏បានចូលទៅមើល ។ ក្នុងចំណោមប្រជាជនក្មេងចាស់ប្រុសស្រីប្រមាណជិត៥០នាក់ អាថ្លាង ដៃទាំងពីរត្រូវបានចងស្លាបសេកនឹងខ្សែអង្រឹងទាញទៅក្រោយយ៉ាងតឹងអង្គុយលុតជង្គង់ចំពីមុខអ្នកភូមិ នៅក្បែរខាងនោះ មិត្តបេន និង មិត្តសិន ស្ពាយកាំភ្លើងម្នាក់មួយដើមនៅនឹងស្នា ស្ត្រីចំណាស់ម្នាក់អង្គុយបត់ជើងផ្ទាល់នឹងដីសំពត់អាវប្រឡាក់ឲ្យស្រមក ដែលអ្នកភូមិស្គាល់ថាជាម្តាយរបស់ អាថ្លាង កំពុងតែស្រែកទ្រហោយំអង្វរល្ហួងលោមលើកដៃទាំងពីរសំពះអ្នកភូមិនិង មិត្តសិន សូមឲ្យគេលើកលែងទោសឲ្យកូនប្រុសគាត់ផង ។

អាថ្លាង ភ័យស្លុតមានទឹកមុខយ៉ាងស្លេកស្លាំង ចោលភ្នែកសម្លឹងមើលម្តាយវាដែលកំពុងតែស្រែកយំអង្វរគេឡើងទន់ខ្លួន ។ ពេលដែលអ្នកភូមិបានមកជុំគ្នាអស់ហើយ មិត្តសិន ក៏បានឡើងប្រកាសពីទោសកំហុសរបស់ អាថ្លាង ដែលបាននាំគ្នាប្រដាប់ដោយអាវុធមកបំផ្លាញការរស់ឡើងវិញរបស់ប្រជាជនក្នុងភូមិឈើទាលកាលពីយប់មិញ ។

ក្រោយពីប្រកាសពីទោសកំហុសរបស់ អាថ្លាង រួចមក មិត្តសិនក៏បានស្រែកសួរយោបល់អ្នកភូមិទាំងអស់ថា បើទោសកំហុសធ្ងន់ធ្ងរបែបនេះ តើបងប្អូនគិតយ៉ាងណា? ត្រូវលើកលែងទោសឲ្យវារួចខ្លួន ឬត្រូវកម្ទេចចោល? បើត្រូវកម្ទេចសូមបងប្អូនទាំងអស់គ្នាលើកដៃឡើង! ។

មិត្តសិន និយាយមិនទាន់ផុតពីមាត់ផង ស្រាប់តែអ្នកភូមិបានលើកដៃឡើងស្រព្រមគ្នា អាថ្លាង ស្លុតរន្ធត់ស្ទើរបាត់ស្មារតីពេលដែលមិត្តសិន ដើរទៅចាប់ទាញដៃវាឲ្យក្រោកឈរឡើង អាថ្លាង ទន់ខ្លួនដូចសំឡីចោលភ្នែកសម្លឹងមើលម្តាយវាជាចុងក្រោយ ពេលដែលគាត់ស្ទុះប្រុងទៅស្រវាឱបកូន មិត្តបេន យកដៃក្រៀសគាត់ចេញទៅម្ខាង ហើយមិត្តសិន ក៏ចាប់អូស អាថ្លាង ទីណាត់ទីណែងបណ្តើរចេញឆ្ពោះ

ទៅកាន់វាលស្រែខាងក្រៅភូមិ ។

អ្នកភូមិប្រុសៗបួនប្រាំនាក់ដើរតាមពីក្រោយ ខ្ញុំក៏ទៅតាមមើលនឹងគេដែរ ផុតពីមាត់ព្រៃប្រហែលបីបួនស្រែ មិត្តសឺនក៏បានស្រាយចំណងចេញពីដៃ អាថ្វាង ហើយនិយាយប្រាប់វាថា រំលងពីរស្រែខាងមុខបើអ្ហែងរត់ផុត អញឲ្យរួចខ្លួន! ។

ភ្លាមនោះខ្ញុំឃើញ អាថ្វាង ខំប្រឹងរត់យកព្រះអាយុ តែមិនទាន់ផុតបានមួយស្រែស្រួលបួលផង មិត្តសឺន លើកកាំភ្លើងអាកាឡើងបាញ់ស្រោចតម្រង់ទៅរកវា អាថ្វាង ត្រូវគ្រាប់ដួលប្រកាច់ស្លាប់មួយរំពេចស្លាប់ក្នុងថ្លុកឈាម កណ្តាលវាលស្រែ ។

ស្អែកឡើងខ្ញុំបានទៅរក ពូផន និង មីងណារុង នៅឯភូមិទួលសង្កែ តែគួរឲ្យសោកស្តាយជាទីបំផុតដោយគាត់បានចេញដំណើរត្រឡប់ទៅស្រុកវិញតាំងពីម្សិលមិញបាត់ទៅហើយ ។ ដោយអាការៈរោគរបស់ ពូផន កាន់តែធ្ងន់ធ្ងរណាស់ទៅហើយ គាត់គិតថាបើស្លាប់ក៏ស្លាប់ទៅចុះឲ្យតែបានទៅដល់ស្រុកកំណើតវិញ ។

មិត្តឈាង ជួយផ្ញើរទេះមួយសម្រាប់អូស ពូផន រួមដំណើរទៅជាមួយគាត់មានគ្រួសារ បងសំអាត ប្តីបងចន្ធូ និងគ្រួសារអ្នកទន្លេបី-បួនគ្រួសារទៀត ។ រំលងពីរថ្ងៃបន្ទាប់មក នាពេលល្ងាចថ្ងៃលិចជិតផុតទៅហើយ មានបងប្រុសម្នាក់បានចូលមករកខ្ញុំដល់ផ្ទះ មិត្តសាយ ភូមិឈើទាល បានប្រាប់ខ្ញុំថា គាត់ឈ្មោះ ប៊ុនរ៉ុង មកពីឃុំកកោះ នៅភូមិជាមួយអ្នកមីងម្តាយ ឆារ៉ាក់ ។ គាត់ចូលមកប្រាប់ខ្ញុំថា កុំអាលចេញដំណើរទៅណា ថ្ងៃស្អែកក្រុមគ្រួសារអ្នកមីងម្តាយ ឆារ៉ាក់ ចេញដំណើរពីកកោះមកហើយ ឲ្យខ្ញុំរង់ចាំរួមដំណើរជាមួយគ្នា ។ ខ្ញុំបានមកឈរវង់ចាំក្រុមគ្រួសារ ឆារ៉ាក់ នៅនឹងថ្នល់ជាតិ ខ្ញុំបានជួបបង ជា ពន្លក (ប្អូនលោក ជា គឹមអេង) ហើយបាននាំគ្នាចូលទៅលេងភូមិទួលសង្កែ ចៃដន្យបានជួប មិត្តឈាង ដែលទើបតែចុះពីចុងត្នោត គាត់បានរើសទឹកត្នោតថ្វាយធំមួយបំពង់ធំឲ្យទៅ បងពន្លក ។

ក្រោយពីបានជួបមីងម្តាយ ឆារ៉ាក់ និងគ្រួសារបងស្រីគាត់រួចមក ខ្ញុំក៏បានត្រឡប់មកភូមិឈើទាលវិញដើម្បីទៅជម្រាបលាម៉ែឡាញ់ ម្តាយ និងប្អូនស្រី បងហឿង ក្រុមគ្រួសារ មិត្តសាយ និងចុងក្រោយទៅលា មិត្តហេង ប្រធានភូមិ ។

ល្ងាចនោះយើងសម្រាកនៅនឹងចិញ្ចើមថ្នល់មុខអនុវិទ្យាល័យកំពង់ថ្មជាមួយនឹងអ្នកដំណើរជាច្រើនរយគ្រួសារទៀត ។ តាំងពីពេលថ្ងៃលិចផុតទៅ យប់ងងឹតបានចូលមកដល់អត់មានអ្នកណាម្នាក់ហ៊ានដុតភ្លើងចន្លុះបំភ្លឺទេ ជាមួយនឹងកម្រាលកៅស៊ូ យើងនាំគ្នាដេកផ្ទាល់នឹងដីក្នុងសភាពយ៉ាងប្រុងប្រយ័ត្ន ។ នៅតាមបណ្តោយផ្លូវជាតិមានកងទ័ពខ្មែររណសិរ្ស និងទាហានយួនដើរទៅមកការពារ នៅឆ្ងាយបន្តិចពីយើងមានឮសូរស្នូរកាំភ្លើងបាញ់តដៃគ្នារប៉េះរប៉ោះ ។ យប់ជ្រៅបន្តិចមេឃកាន់តែងងឹតស្នូរកាំភ្លើងដៃបាញ់តទល់គ្នាពីព្រៃឯនាយខាងមុខលាន់ឮកាន់តែជិតកាន់តែខ្លាំងកាន់តែរន្ធើន ។ ប្រជាជនដែលសម្រាកទាំងសងខាងថ្នល់នាំគ្នាសម្ងំស្ងាត់ជ្រៀប ខ្មែរក្រហមដែលសេសសល់ព្យាយាមវាយបណ្តេញទាហានយួនចេញពីថ្នល់ជាតិ ។ ប្រមាណជិតកន្លះម៉ោងក្រោយមក ការប្រយុទ្ធគ្នាកាន់តែរីកទ្រង់ទ្រាយកាន់តែធំឡើងៗ គ្រាប់កាំភ្លើងក្រហមដូចរងើកភ្លើងហោះហើរយ៉ាងច្របូកច្របល់ពេញផ្ទៃអាកាស ស្នូរកាំភ្លើងធំផ្ទុះថ្លោងលាន់សូរទ្រហឹងស្ទើរបែកក្រដាសត្រចៀក ខ្ញុំក្រាបផ្ទាល់នឹងដីបង្ងើបក្បាលបន្តិចមើលទៅមុខ ឃើញតែផ្សែងខ្មៅទ្រលោម និងអណ្តាតភ្លើងសន្ធោរសន្ធៅ ។ មួយស្របក់ក្រោយមក ការប្រយុទ្ធគ្នាក៏បានស្ងប់ទៅវិញបន្តិចម្តងៗ ប្រហែលជាពួកខ្មែរក្រហមដកថយទៅវិញអស់ហើយ តែទោះជាយ៉ាងណាក៏ដោយ ពេញមួយយប់ទល់ភ្លឺនោះ ម្នាក់ៗស្ថិតក្នុងសភាពប្រុងប្រយ័ត្នរហូត ។

ព្រឹកឡើងប្រជាជនផ្អើលនាំគ្នាទៅមើលទាហានខ្មែរក្រហមពីរនាក់ដែលត្រូវចាប់ខ្លួនបានក្នុងឱកាសប្រយុទ្ធគ្នាកាលពីយប់មិញ ។ ទាំងពីរនាក់ក្នុងវ័យជាង២០ឆ្នាំ ដៃជាប់ចំណងលែងខ្លួនទទេ ស្លៀកតែខោខ្លីពណ៌ខ្មៅម្នាក់ត្រូវបានទាហានយួនយកទៅចងនឹងគល់ឈើធំមួយ អាម្នាក់ទៀតចងនឹងសសរកណ្តាលក្រោលគោ ក្រោមផ្ទះអ្នកស្រុកក្បែរនោះ ដែលមានទាហានយួនពីរនាក់នៅចាំយាមការពារ ។

ពេលដែលប្រជាជននាំគ្នាចោមរោមកាន់តែច្រើន អ្នកខ្លះមានកាន់ទាំងដំបង កាំបិតពូថៅនៅនឹងដៃផងនោះ ពួកវាទាំងពីរនាក់មានទឹកមុខភ័យស្លន់ស្លោយ៉ាងខ្លាំង ។ ឃើញសភាពបែបនេះ ទាហានយួនដែលការពារមិនហ៊ានទៅណាឆ្ងាយទេ ប្រជាជនកំពុងពោរពេញទៅដោយកំហឹង ព្រោះបើតាមអ្នកស្រុកដែលធ្លាប់ស្គាល់បាននិយាយថា អាពីរនាក់នេះធ្លាប់សម្លាប់មនុស្សអស់មិនតិចទេ ។

ទាហានយួនទាំងពីរនាក់ ជាញឹកញយបានលើកដៃជាសញ្ញាសូមឲ្យប្រជាជនថយទៅក្រោយវិញ តែដោយកំហឹងប្រជាជននៅ

តែជម្រុលទៅមុខដដែលម្នាក់ៗ ប្រុងតែសំពងអាទាហានខ្មែរក្រហមទាំងពីរនាក់នេះ សងសឹកឲ្យក្រុមគ្រួសារដោយផ្ទាល់ដៃ ។ ក្នុងខណៈនោះ ខ្ញុំបានឃើញបងប្រុសម្នាក់ មានមាឌធំដំបងខ្ពស់សម្បុរសចេះនិយាយភាសាវៀតណាមយ៉ាងច្បាស់ ឈរនិយាយជាមួយទាហានយួនទាំងពីរនាក់យ៉ាងយូរ ហើយគាត់បានងាកមកនិយាយប្រាប់ហ្វូងប្រជាជនថា ខ្ញុំបានសុំកងទ័ពវៀតណាមយកអាម្នាក់ដែលចងជាប់នឹងគល់ឈើនេះយកទៅសម្លាប់ដោយផ្ទាល់ដៃ ព្រោះវាបានសម្លាប់ឪពុកម្តាយបងប្អូនខ្ញុំ និងអ្នក១៧មេសាអស់ជាច្រើនគ្រួសារទៀត ។ ខ្ញុំឃើញកងទ័ពវៀតណាមទាំងពីរនាក់អល់អែករារែក ។ មិនបង្អង់ឲ្យខាតពេលយូរ គាត់ក៏ស្ទុះចូលទៅអូសអាម្នាក់ដែលចងនៅនឹងគល់ឈើជាមួយនឹងប្អូនប្រុសគាត់ដែលមានស្ពាយកាំបិតផ្គាក់ សំលៀងមុខស្វាច បាននាំគ្នាបណ្តើរវាចូលទៅកាប់សម្លាប់ចោលនៅនឹងព្រៃក្បែរនោះបាត់ទៅ ។ ហ្វូងប្រជាជនរុលឈូតម្រង់ទៅអាម្នាក់ទៀតនៅនឹងក្រោលគោ ។ ពេលនោះវាភ័យខ្លាំងណាស់ ទឹកមុខស្លេកស្លាំងគ្មានឈាមមួយតំណក់ទេ ទាហានវៀតណាមទាំងពីរនាក់ព្យាយាមឃាត់ឃាំងប្រជាជនកុំឲ្យពុះកញ្ជ្រោលខ្លាំងពេក ។ គ្រាន់តែកងទ័ពវៀតណាមងាកខ្លួនចេញតែបន្តិច ក្នុងមួយប៉ប្រិចភ្នែកនោះ អ៊ុំប្រុសម្នាក់ដែលមានវ័យប្រហែលជាជាង៦០ឆ្នាំទៅហើយនោះ ក្រឡេកភ្នែកសឹងតែពុំទាន់រហ័សដូចព្រួញគាត់បានស្ទុះទៅទាញយកចបកាប់កញ្ចាស់មួយពីពំនូកអាចម៍គោក្បែរនោះមកសំពងចំកណ្តាលក្បាលវាយ៉ាងអស់ទំហឹងលាន់ឮសូរតែ «ភូស» ពេលនោះខ្ញុំនៅបានឮសំដីគាត់ដែលបាននិយាយយ៉ាងម៉ាត់ៗ ពោរពេញទៅដោយភ្លើងកំហឹងស៊ើរស្រក់ឈាមថា «អ្អែងបានសម្លាប់កូនប្រុសតែមួយរបស់អញ ពេលនេះឈាមស្រែកស្បែកហៅហើយ» ។ ជាមួយនឹងដៃជាប់ចំណងខ្ញុំឃើញវាដួលប្រកាច់ដោយមានឈាមហូរចេញតាមត្រចៀក ច្រមុះ និងតាមមាត់សស្រាក់ដោតខ្លួន ។ ខណៈដែលកងទ័ពវៀតណាមទាំងពីរដើរចេញពីទីនោះទៅហើយនៅពេលដែលវាកំពុងតែត្រដរខ្យល់ក្នុងថ្លុកឈាម ប្រជាជនទាំងហ្វូងជាមួយនឹងកាំបិត ពូថៅ ដំបងនៅនឹងដៃបានប្រញាយគ្នាចូលទៅកាប់សំពងបន្ថែម ។ ក្នុងចំណោមនោះភាគច្រើនជាស្ត្រីមេម៉ាយដែលយ៉ាងហោចណាស់ក៏បានចូលទៅសំពងមួយដំបង ឬកាប់មួយកាំបិតម្នាក់សងឈាមឲ្យប្តីៗគាត់ដែរ ។

នៅនឹងជំរំកងទ័ពវៀតណាមមុខអនុវិទ្យាល័យកំពង់ថ្ម បងប្អូនប្រជាជនណាដែលមានស្រុកកំណើតនៅកំពង់ចាម ត្រូវបានជួយដឹកជញ្ជូនដោយរថយន្តកងទ័ពវៀតណាម ដែលត្រូវធ្វើដំណើរទៅមកពីរថ្ងៃម្តង ។ ប្រជាជនជាច្រើនគ្រួសារមានសំណាងបានជិះរថយន្តកងទ័ពវៀតណាម អ្នកខ្លះចុះត្រង់ស្ពានបន្តដំណើរទៅភ្នំពេញ អ្នកខ្លះចុះព្រៃទទឹង ។

ពួកខ្ញុំក៏នាំគ្នារង់ចាំជិះរថយន្តកងទ័ពវៀតណាមនឹងគេដែរ តែពួកយើងពុំមានសំណាងសោះ អ្នកមុនៗ ត្រូវបានកងទ័ពវៀតណាមជួយដឹកជញ្ជូនដោយឥតគិតថ្លៃ តែប៉ុន្មានថ្ងៃក្រោយមកទៀត អ្នកបើកបររថយន្តបែកប្រាជ្ញាទារថ្លៃដឹកជញ្ជូនក្នុងមួយគ្រួសារ៥ជី ។

គ្រួសារអ្នកដែលមានមាស ត្រូវបានចេញដំណើរតាមរថយន្តកងទ័ពជាបន្តបន្ទាប់ គ្រួសារដែលគ្មានមាស ក៏រៀបចំដំណើរដោយថ្មើរជើងទៅមុខទៀតដែរ ។ ល្ងាចនោះយើងបាននាំគ្នារៀបចំរទេះរុញអម្រែក ចានឆ្នាំង ដើម្បីនឹងចេញដំណើរនៅព្រឹកព្រលឹមថ្ងៃស្អែក ។ ពេលព្រលប់យប់ងងឹតបានមកដល់ ស្រាប់តែមានការវាយប្រហារគ្នាជាថ្មីម្តងទៀត រវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម ។ ការវាយប្រហារគ្នាលើកនេះពុំមានទ្រង់ទ្រាយធំទេ គ្រាន់តែជាប់ដៃបាញ់គ្នាមួយប្រាវក៏ស្ងាត់បាត់ទៅវិញទៅ ។

ស្ងប់ស្ងួរគ្រាប់កាំភ្លើងបានមួយស្របក់ ស្រាប់តែឮសូរសម្រែករបស់ស្រីចំណាស់ជាងពាក់កណ្តាលអាយុម្នាក់ដែលកំពុងតែដើរកណ្តាលថ្នល់ស្រែកទ្រហោយំដង្ហោយក្តែងៗ ទាំងទឹកភ្នែកហូររហាមគួរឲ្យសង្វេគ «ឯណាម៉ែខ្ញុំ? ឯណាប្តីសម្លាញ់របស់ខ្ញុំ? ឯណាកូនៗខ្ញុំ? ម៉េចក៏មិនឃើញត្រឡប់មកវិញ?» ។

សម្រែកខ្លោចផ្សាយ៉ាងអាណោចអាធ័មរបស់គាត់ បានទាញកន្ត្រាក់អារម្មណ៍អ្នកដំណើរទាំងអស់គ្នាឲ្យចោលភ្នែកផ្តោតទៅរកគ្រាដែល បងសុខា ប្រពន្ធខ្មោចបងមិន លេងហ្គីតាសូឡូនៅវង់តន្ត្រីកងពលធំលេខ១៣ ក្បាលខ្លាដែលរួមដំណើរមកជាមួយក្រុមគ្រួសារបង ម៉ម ប៊ុនណារ៉ៃ សំណាក់តាមចិញ្ចើមថ្នល់ក្បែរខាងនោះ ស្ទុះទៅឱបក្រាប់គាត់ចេញពីថ្នល់ទើបខ្ញុំស្គាល់ច្បាស់ថា គាត់ជាម្តាយរបស់អាណោ ។

**(តទៅលេខក្រោយ)**

**ប៊ុក ប៊ុនសូម៉ាឌ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬥ Preah Sihanouk Blvd ⬥ Phnom Penh ⬥ Cambodia ⬥ Tel: (855) 23 211 875 ⬥ Fax: (855) 23 210 358 ⬥ dccam@online.com.kh ⬥ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ⬥ Number 195, 2016 ⬥ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.